**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៥)

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ អង្គបុរេជំនុំជម្រះ

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៩

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 16-May-2019, 08:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ**
**របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

---

**ដាក់ដោយ÷**

**សហមេធាវី៖**

អាង ឧត្តម
Michael G. KARNAVAS

**ផ្ញើជូន÷**

**ចៅក្រមអង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Olivier BEAUVALLET

ចៅក្រម BAIK Kang Jin

ចៅក្រមបម្រុង Steven J. BWANA

ចៅក្រមបម្រុង ប៉ែន ពេជ្រសាលី

០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៥)

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

# មាតិកា

I. បញ្ហាចោទ និង ចម្លើយ.....2

II. បញ្ហាបឋម.....3

ក. ភាពអាចទទួលយកបាន.....3

ខ. បទដ្ឋាននៃការពិនិត្យឡើងវិញ.....6

១. បទដ្ឋាននៃការពិនិត្យឡើងវិញដែលអនុវត្តចំពោះច្បាប់នីតិវិធី និង ច្បាប់សារធាតុនៃ អ.វ.ត.ក.....6

២. បទដ្ឋាននៃការពិនិត្យឡើងវិញដែលអនុវត្តចំពោះការសម្រេចលើយុត្តាធិការបុគ្គល.....7

គ. គ្មានសម្បទាន និង ការរក្សាសិទ្ធិ.....13

ឃ. សំណើសុំបើកសវនាការសាធារណៈ.....13

III. សាវតារ.....15

ក. កិច្ចស៊ើបសួរ.....15

ខ. ដីកាដំណោះស្រាយ.....23

១. ដីកាសម្រេចលើកលែងចោទប្រកាន់.....25

២. ដីកាបញ្ជូនរឿងទៅជំនុំជម្រះ.....31

IV. ច្បាប់ និង ឧទ្ធរណ៍.....33

ក. ស.ច.ស.អ. មានកំហុសអង្គច្បាប់ដោយបានបកស្រាយវិធាន ៧៧(១៣) នៅក្នុងរបៀបមួយដែលស្មើថា ដីកាដំណោះស្រាយទាំងពីរ ឬ មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ប៉ុណ្ណោះ ដែលមានអានុភាពអនុវត្ត ប្រសិនបើ អ.ប.ជ. មិនអាចសម្រេចតម្កល់ដីកាដំណោះស្រាយណាមួយក្នុងចំណោមដីកាដំណោះស្រាយទាំងពីរនេះ តាមសំឡេងភាគច្រើនលើសលប់.....33

១. ភាគីនៃកិច្ចព្រមព្រៀងមិនមានចេតនាឱ្យរឿងក្តីបន្តទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ នៅពេលដីកាលើកលែងការចោទប្រកាន់ត្រូវបានចេញក្នុងពេលដំណាលគ្នានោះ.....35

២. ការអនុវត្តវិធាន ៧៧(១៣) លើបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយផ្ទុយគ្នាអាចនាំទៅរកលទ្ធផលមិនសមហេតុផល បង្កឱ្យមានព្យសនកម្មដែលមិនអាចកែតម្រូវបានដល់សិទ្ធិរបស់លោក

មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និង រំលោភលើរដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខ័ណ្ឌ អ.វ.ត.ក. ......42

៣. សេចក្តីសន្និដ្ឋាន ......48

ខ. ស.ច.ស.អ. មានកំហុសអង្គច្បាប់ ដោយខកខានមិនបានសន្និដ្ឋានថា ប្រសិនបើ អ.ប.ជ. មិនអាចសម្រេចដោយសំឡេងភាគច្រើនលើសលប់ថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស ឬ ការរំលោភបំពានដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនទេនោះ ដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ ......50

១. អនុលោមតាមគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ ការសង្ស័យចំពោះអង្គហេតុ និង ការបកស្រាយបទប្បញ្ញត្តិច្បាប់ ត្រូវតែដោះស្រាយជាប្រយោជន៍ដល់លោក មាស មុត ......51

២. ស.ច.ស. ទាំងពីររូបបានស៊ើបអង្កេតអង្គហេតុដែលពួកគាត់បានទទួល និង ផ្តល់ការរកឃើញរបស់ខ្លួននៅក្នុងដីកាដំណោះស្រាយដែលមានសំអាងហេតុ ......54

៣. ក្នុងករណីគ្មានកំហុស ឬ ការរំលោភបំពានដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស.ជ. ដែលអាចរារាំងការអនុវត្តគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ ដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ....64

៤. សេចក្តីសន្និដ្ឋាន ......69

**V. សេចក្តីសន្និដ្ឋាន និង ដំណោះស្រាយដែលស្នើសុំ** ......70

*អំណាចតុលាការមិនដែលត្រូវបានប្រើប្រាស់ សម្រាប់គោលបំណងដាក់ឱ្យអនុវត្តឆន្ទៈរបស់ចៅក្រមនោះទេ ជានិច្ចជាកាល គឺសម្រាប់គោលបំណងដាក់ឱ្យអនុវត្តឆន្ទៈរបស់អង្គនីតិបញ្ញត្តិ ឬ និយាយម្យ៉ាងទៀត ឆន្ទៈនៃច្បាប់។*

**ចៅក្រមតុលាការកំពូលសហរដ្ឋអាមេរិក John Marshall**[1]

ការដាក់ដីកាដំណោះស្រាយដាច់ដោយឡែក និង ផ្ទុយគ្នា ដោយសហចៅក្រមស៊ើបអង្កេត ("ស.ច.ស.") មិនមែនជាអ្វីចម្លែកនោះទេ។ មិនមែនត្រឹមតែភាគីនៃកិច្ចព្រមព្រៀង និង អ្នកព្រាងវិធានផ្ទៃក្នុងប្រមើលមើលដឹងជាមុននោះទេ ស.ច.ស. ក៏បានដឹងជាយូរមកហើយថា ពួកគេនឹងឈានទៅរកសេចក្ដីសន្និដ្ឋានផ្ទុយគ្នាលើការស៊ើបអង្កេត។ បញ្ហាចោទជាចម្បងនៅចំពោះមុខអង្គបុរេជំនុំជម្រះ ("អ.ប.ជ.") គឺថាតើ *ដីកាដំណោះស្រាយណាមួយ មានអានុភាពអនុវត្ត៖* ដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ.") ដែលសម្រេចថា លោក មាស មុត មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅទូទាំងប្រទេសកម្ពុជា ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ ១៩៧៩[2] ឬ ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ.") ដែលសម្រេចផ្ទុយពីនេះ[3]? បណ្ដឹងឧទ្ធរណ៍នេះចោទជាសំណួរថា តើនៅពេលដែលមិនអាចរកបានសំឡេងភាគច្រើនលើសលប់ ដើម្បីតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន អ.ប.ជ. អាចទុកដីកាដំណោះស្រាយទាំងពីរចោលមិនសម្រេចជារៀងរហូត ឬ ជាជម្រើសផ្សេងទៀត បញ្ជូនរឿងក្ដីនេះទៅជំនុំជម្រះក្នុងសវនាការ នៅពេលដីកាសម្រេចលើកលែងចោទប្រកាន់ និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានចេញក្នុងពេលដំណាលគ្នាបែបនេះ ឬយ៉ាងណា។ បណ្ដឹងឧទ្ធរណ៍នេះក៏ចោទជាសំណួរផងដែរថា នៅពេលដែលមិនអាចរកបានសំឡេងភាគច្រើនលើសលប់សម្រេចបានថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស ឬ ការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិនោះ តើដីកាបញ្ជូនរឿងទៅជំនុំជម្រះមានអានុភាពលើដីកាសម្រេចលើកលែងចោទប្រកាន់ ឬយ៉ាងណា បើទោះជាមានគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់*

---

[1] រឿងក្ដី *Osborn តទល់នឹង ធនាគារ ស.រ.អា,* 22 U.S. 738, 866 (ឆ្នាំ ១៨២៤)។

[2] ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ ឯកសារ D266 ("ដីកាសម្រេចលើកលែងចោទប្រកាន់")។

[3] ដីកាដំណោះស្រាយ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ ឯកសារ D267 ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")។

*ជនត្រូវចោទ* (in dubio pro reo) នោះ។ ចម្លើយចំពោះសំណួរទាំងនេះ គឺច្បាស់ក្រឡែត។ ភាគីនៃកិច្ចព្រមព្រៀងមិនមានចេតនាឱ្យរឿងក្តីបន្តទៅជំនុំជម្រះក្នុងសវនាការនោះទេ នៅពេលដែលដីកាសម្រេចលើកលែងចោទប្រកាន់ និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានចេញក្នុងពេលដំណាលគ្នាបែបនេះនោះ។ នៅពេលដែល ស.ច.ស. ពីរនាក់ មានអំណាចស្មើគ្នា និង ឯករាជ្យពីគ្នា ចេញដីកាដំណោះស្រាយដែលមានកម្លាំងស្មើគ្នា ដីកាដំណោះស្រាយដែលសម្រេចលើកលែងការចោទប្រកាន់ក្នុងរឿងក្តី មានអានុភាពលើដីកាដំណោះស្រាយដែលសម្រេចបញ្ជូនរឿងទៅជំនុំជម្រះក្នុងសវនាការ។ ត្រូវតែច្រានចោលរឿងក្តីប្រឆាំងនឹងលោក មាស មុត ។

## I. បញ្ហាចោទ និង ចម្លើយ

***សំណួរទីមួយ៖*** *យោងតាម ស.ច.ស. "វិធាន ៧៧(១៣) ដោះស្រាយតែស្ថានភាពដែលមានដីកាលើកលែងការចោទប្រកាន់ ឬ ដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ មិនមែនស្ថានភាពដែលមានដីកាដំណោះស្រាយបែកចេញពីគ្នានោះទេ"។ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ ស.ច.ស.អ. បានដកស្រង់ និងទទួលយកការយល់ឃើញរបស់ ស.ច.ស. ថា "[ដីកាដំណោះស្រាយ] ទាំងពីរអាចនឹងមានអានុភាពអនុវត្ត" ហើយបានយល់ឃើញថា "មិនមានលក្ខណៈច្បាស់លាស់ថា តើដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងមានអានុភាពអនុវត្តឬយ៉ាងណា" តាមវិធាន ៧៧(១៣) ប្រសិនបើ អ.ប.ជ. មិនអាចរកបានសំឡេងភាគច្រើនលើសលប់ដើម្បីសម្រេចតម្កល់ដីកាលើកលែងការចោទប្រកាន់ ឬ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ។ តើ ស.ច.ស.អ. មានកំហុសអង្គច្បាប់ដែរឬទេ នៅក្នុងការបកស្រាយវិធាន ៧៧(១៣) នៅក្នុងរបៀបមួយដែលស្នើថា ដីកាដំណោះស្រាយទាំងពីរ ឬ មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ប៉ុណ្ណោះ ដែលមានអានុភាពអនុវត្ត ប្រសិនបើ អ.ប.ជ. មិនអាចសម្រេចតម្កល់ដីកាដំណោះស្រាយណាមួយក្នុងចំណោមដីកាដំណោះស្រាយទាំងពីរទេនោះ?*

***ចម្លើយ៖*** *ស.ច.ស.អ. ពិតជាមានកំហុសអង្គច្បាប់ ពីព្រោះ ភាគីនៃកិច្ចព្រមព្រៀងមិនមានចេតនាបញ្ជូនរឿងក្តីទៅជំនុំជម្រះក្នុងសវនាការនោះទេ នៅពេលដែលដីកាលើកលែងការចោទប្រកាន់ និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានចេញក្នុងពេលដំណាលគ្នានោះ។ អនុវត្តវិធាន ៧៧(១៣) ចំពោះបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយផ្ទុយគ្នា នឹងនាំឱ្យមានលទ្ធផលដែលមិនសមហេតុផល បង្កព្យសនកម្មដែលមិនអាចកែតម្រូវបានលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ លោក មាស មុត និង រំលោភរដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខ័ណ្ឌ អ.វ.ត.ក.។*

***សំណួរទីពីរ៖*** *យោងតាមគោលការណ៍* វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ *ដែលជាគោលការណ៍មូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ក្របខ័ណ្ឌ អ.វ.ត.ក. និង ច្បាប់អន្តរជាតិ ត្រូវដោះស្រាយវិមតិសង្ស័យឱ្យបានជាប្រយោជន៍ដល់ជនត្រូវចោទ។ ស.ច.ស. ទាំងពីរបានចេញដីកាដំណោះស្រាយផ្ទុយគ្នាស្រឡះ៖ ដីកាមួយសម្រេចលើកលែងការចោទប្រកាន់ក្នុងរឿងក្ដី និង ដីកាមួយទៀតសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ។ សន្មតថា ស.ច.ស.ជ. មិនបានប្រព្រឹត្តកំហុស ឬ ការរំលោភបំពានដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់គាត់ នៅក្នុងការសម្រេចអំពីយុត្តាធិការបុគ្គល តើ ស.ច.ស.អ. មានកំហុសអង្គច្បាប់ដែរឬទេ នៅពេលខកខានមិនបានសន្និដ្ឋានថា ដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប្រសិនបើ អ.ប.ជ. មិនអាចសម្រេចផ្ទុយពីនេះ តាមសំឡេងភាគច្រើនលើសលប់នោះ?*

***ចម្លើយ៖*** *ស.ច.ស.អ. ពិតជាមានកំហុសអង្គច្បាប់ ពីព្រោះ ការស៊ើបអង្កេត ការវាយតម្លៃលើអង្គហេតុ ការអនុវត្តច្បាប់ ឬ ការចេញដីកាដំណោះស្រាយរបស់ ស.ច.ស. ម្នាក់ មិនមានអានុភាពលើ ឬ ចំណុះឱ្យការស៊ើបអង្កេត ការវាយតម្លៃលើអង្គហេតុ ការអនុវត្តច្បាប់ ឬ ការចេញដីកាដំណោះស្រាយរបស់ ស.ច.ស. ម្នាក់ទៀតនោះទេ។ ប្រសិនបើ អ.ប.ជ. មិនអាចសម្រេចតាមសំឡេងភាគច្រើនលើសលប់ថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស ឬ ការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់គាត់ ដែលរារាំងដល់ការអនុវត្តគោលការណ៍* វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ នោះទេ *ដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។*

## II. បញ្ហាបឋម

### ក. ភាពអាចទទួលយកបាន

១. លោក មាស មុត ប្ដឹងឧទ្ធរណ៍ជំទាស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ. អនុលោមតាមវិធាន ៧៤(៣)(ក) និង ២១ នៃវិធានផ្ទៃក្នុង ("វិធាន")។ បណ្ដឹងឧទ្ធរណ៍នេះត្រូវបានដាក់ទាន់ពេលវេលាជាភាសាអង់គ្លេស ហើយសំណៅបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ[4]។

[4] សេចក្ដីសម្រេចលើសំណើរបស់ មាស មុត សុំបន្ថែមពេលវេលា និង បង្កើនចំនួនទំព័រ សម្រាប់បណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ & សុំដាក់បណ្ដឹងឧទ្ធរណ៍របស់គាត់ជាភាសាអង់គ្លេសសិន ឯសំណៅបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៩ ឯកសារ D267/1/3 ទំព័រ ៣។

២. វិធាន ៧៤(៣)(ក) អនុញ្ញាតឱ្យលោក មាស មុត ប្តឹងឧទ្ធរណ៍ជំទាស់សេចក្តីសម្រេចរបស់ ស.ច.ស. "បញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក."។ អ.ប.ជ. បានចាត់ទុកថា បញ្ហាយុត្តាធិការ គឺគ្របដណ្តប់លើទម្រង់ "យុត្តាធិការលើរូបបុគ្គល យុត្តាធិការពេលវេលា និង យុត្តាធិការលើរឿងក្តី" របស់ អ.វ.ត.ក.[5]។ មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ទាក់ទងនឹងការបញ្ជាក់របស់ ស.ច.ស.អ. លើយុត្តាធិការរបស់ អ.វ.ត.ក. តាមរយៈ៖ **ក.** ការបកស្រាយវិធាន ៧៧(១៣) នៅក្នុងរបៀបមួយដែលស្នើថា ដីកាដំណោះស្រាយទាំងពីរ ឬ មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ប៉ុណ្ណោះមានអានុភាពអនុវត្ត ប្រសិនបើ អ.ប.ជ. មិនអាចសម្រេចតម្កល់ដីកាដំណោះស្រាយណាមួយក្នុងចំណោមដីកាដំណោះស្រាយទាំងពីរនេះ ដោយសំឡេងភាគច្រើនលើសលប់នោះ[6] និង **ខ.** ការខកខានមិនបានសន្និដ្ឋានថា ដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ប្រសិនបើ អ.ប.ជ. មិនអាចសម្រេចតាមសំឡេងភាគច្រើនលើសលប់ថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស ឬការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនទេនោះ[7]។

៣. វិធាន ២១ តម្រូវឱ្យបកស្រាយក្របខ័ណ្ឌ អ.វ.ត.ក. ក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់លោក មាស មុត។ ខណៈដែល អ.ប.ជ. បានសម្រេចថា វិធាន ២១ មិនមែនជាផ្លូវតែឯងដែលអាចយកជាមូលដ្ឋានប្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ[8] អ.ប.ជ. បានទទួលយកការបកស្រាយទូលាយនៃសិទ្ធិប្តឹងឧទ្ធរណ៍ តាមវិធាន ៧៤(៣)(ក) ផ្គួបជាមួយវិធាន ២១៖ **ក.** នៅពេល

---

[5] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៤៥ & ១៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D427/2/15 កថាខណ្ឌ ៦៣។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៧។

[6] *សូមមើល* កថាខណ្ឌ ៣២-៤៨ *ខាងក្រោម*។

[7] *សូមមើល* កថាខណ្ឌ ៤៩-៦៦ *ខាងក្រោម*។

[8] *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៨។

ស្ថានភាពដែលជាបញ្ហា មិនមានចែងនៅក្នុងវិធានផ្ទៃក្នុង[9] **ខ.** នៅពេលដែលបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើកឡើងអំពីបញ្ហាដែលមិនអាចកែតម្រូវដោយអង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ.")[10] និង **គ.** នៅពេលកាលៈទេសៈជាក់លាក់នៃរឿងក្តី តម្រូវឱ្យ អ.ប.ជ. អន្តរាគមន៍ ដើម្បីបញ្ចៀសព្យសនកម្មដែលមិនអាចកែតម្រូវបាន លើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនត្រូវចោទ[11]។

៤. សិទ្ធិប្តឹងឧទ្ធរណ៍របស់ មាស មុត សមនឹងទទួលបានការបកស្រាយទូលាយ។ ដំណោះស្រាយលើបណ្តឹងឧទ្ធរណ៍ដែលស្នើដោយ ស.ច.ស.អ. ចំពោះស្ថានភាពដីកាដំណោះស្រាយផ្ទុយគ្នា មិនមានចែងនៅក្នុងវិធានផ្ទៃក្នុងនោះទេ[12]។ បណ្តឹងឧទ្ធរណ៍នេះលើកឡើងពីបញ្ហានានាដែលមិនអាចកែតម្រូវបានដោយ អ.ជ.ស.ដ. ពីព្រោះប្រសិនបើដីកាដំណោះស្រាយទាំងពីរមានអានុភាពអនុវត្ត កិច្ចដំណើរការនីតិវិធីនឹងបញ្ចប់ ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅតែបន្តលងបន្លាចលោក មាស មុត ជារៀងរហូត ពោលគឺ គាត់មិនអាចតវ៉ានឹងបទចោទប្រកាន់បាន ដោយសារគាត់មិនមានយន្តការផ្សេងទៀតសម្រាប់ប្តឹងនោះឡើយ[13]។ ការមិនអនុញ្ញាតឱ្យលោក មាស មុត ប្តឹងឧទ្ធរណ៍

---

[9] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងដីកាសម្រេចចេញសាឡើងវិញ លើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D120/3/1/8 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២៤។ *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៩) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី ១ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D239/1/8 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ១៧។

[10] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៨។

[11] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងដីកាសម្រេចចេញសាឡើងវិញ លើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D120/3/1/8 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២៤។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៨។

[12] *សូមមើល* កថាខណ្ឌ ៣២-៤៨ *ខាងក្រោម*។

[13] *សូមមើល* កថាខណ្ឌ ៤២, ៤៤ *ខាងក្រោម*។

ជំទាស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ នឹងបង្កព្យសនកម្មដែលមិនអាចកែតម្រូវបាន ហើយបានដកហូតពីគាត់ជាអចិន្ត្រៃយ៍ នូវសិទ្ធិដែលរដ្ឋធម្មនុញ្ញធានាឱ្យគាត់៖ **ក.** សិទ្ធិទទួលបានសច្ចធារណ៍និរទោស **ខ.** សិទ្ធិការពារក្តីរបស់គាត់ **គ.** សិទ្ធិឱ្យកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់បញ្ចប់ក្នុងរយៈពេលមួយសមហេតុផល **ឃ.** សិទ្ធិទទួលបានការការពារស្មើភាពនៅចំពោះមុខ អ.វ.ត.ក. និង ជាពិសេស **ង.** វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់គាត់[14]។

## ខ. បទដ្ឋាននៃការពិនិត្យឡើងវិញ

### ១. បទដ្ឋាននៃការពិនិត្យឡើងវិញដែលអនុវត្តចំពោះច្បាប់នីតិវិធី និង ច្បាប់សារធាតុនៃ អ.វ.ត.ក.

៥. អ.ប.ជ. នឹងច្រានចោលដីកាសម្រេចបញ្ជាក់អំពីយុត្តាធិការ នៅពេល ស.ច.ស. មានកំហុសអង្គច្បាប់ជាក់លាក់ ដែលនាំឱ្យមោឃភាពសេចក្តីសម្រេច[15]។ អ.ប.ជ. ក្នុងនាមជាអង្គវិនិច្ឆ័យលើច្បាប់ជាធរមានរបស់ អ.វ.ត.ក. អនុវត្តនៅដំណាក់កាលមុនការជំនុំជម្រះ[16] “ជាគោលការណ៍ ត្រូវបានចងកាតព្វកិច្ចក្នុងការសម្រេចថា តើកំហុសអង្គច្បាប់ត្រូវបានប្រព្រឹត្តឡើងយ៉ាងជាក់ស្តែងទៅ

---

[14] មាត្រា ៣១, ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយព្រះរាជក្រម ចុះថ្ងៃទី ៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើវិសោធនកម្មមាត្រា ១១, ១២, ១៣, ១៨, ២២, ២៦, ២៨, ៣០, ៣៤, ៥១, ៩០, ៩១, ៩៣ និង មាត្រាផ្សេងទៀតចាប់ពីជំពូក ៨ ដល់ជំពូក ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានអនុម័តដោយរដ្ឋសភាកាលពីថ្ងៃ ៤ ខែមីនា ឆ្នាំ ១៩៩៩ (“រដ្ឋធម្មនុញ្ញកម្ពុជា”)។ *សូមមើលខាងក្រោម* កថាខណ្ឌ ៤៣-៤៥, ៥០-៥១។

[15] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៤៥ & ១៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D427/2/15 កថាខណ្ឌ ៨៦ (សេចក្តីយោងខាងក្នុងត្រូវបានលុបចោល)។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ១១២ (សេចក្តីយោងខាងក្នុងត្រូវបានលុបចោល)។

[16] *សូមមើល រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D261 (“ដីកាដំណោះស្រាយរឿងក្តី ០០៤/១”) កថាខណ្ឌ ១០៖ “អ.ប.ជ. ជាស្ថាប័នតែមួយ ដែលទទួលពិនិត្យមើលបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស.”។

លើបញ្ហានីតិវិធី ឬ អង្គសេចក្តី ដែរឬយ៉ាងណា”[17]។ អ.ប.ជ. មិនបង្វិលសំណុំរឿងទៅឱ្យ ស.ច.ស. វិញឡើយ ហើយពិនិត្យកំហុសអង្គច្បាប់ដែលបានលើកឡើង *សាជាថ្មី* ដើម្បីសម្រេចថា តើការសម្រេចលើអង្គច្បាប់ទាំងនោះត្រឹមត្រូវឬយ៉ាងណា[18]។ អ.ប.ជ. សម្រេចថា តើ ស.ច.ស. “បានអនុវត្តតាមខ្លឹមសារនៃនិយាមគតិយុត្តិជាធរមាន ដោយផ្អែកតាមប្រភពដ៏សមស្របនៃច្បាប់ និង តាមរយៈការអនុវត្តនូវវិធាននៃការបកស្រាយទាក់ទងនឹងប្រភពនៃច្បាប់ទាំងនោះ” និង “វាយតម្លៃថាតើលទ្ធផលដែលទទួលបាននោះមានលក្ខណៈច្បាស់លាស់ និង ជាក់លាក់ ដែរឬយ៉ាងណា”[19]។

## ២. បទដ្ឋាននៃការពិនិត្យឡើងវិញដែលអនុវត្តចំពោះការសម្រេចលើយុត្តាធិការបុគ្គល

៦. ការសម្រេចថាតើ លោក មាស មុត គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ឬយ៉ាងណានោះ គឺជាសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ[20]។ ខណៈដែល “ភាពបត់បែន” នៃពាក្យអ្នកទទួលខុសត្រូវខ្ពស់បំផុត តម្រូវថា ស.ច.ស. អនុវត្ត “សិទ្ធិអំណាចមួយចំនួន”[21] ការសម្រេចនេះត្រូវធ្វើឡើងតាម

---

[17] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ១៤ (សេចក្តីយោងខាងក្នុងត្រូវបានលុបចោល)។

[18] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៤៥ & ១៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D427/2/15 កថាខណ្ឌ ៨៦។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អ.ប.ជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ១១៣។

[19] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ១៤ (សេចក្តីយោងនៅផ្នែកខាងក្នុងត្រូវបានលុបចោល)។

[20] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២០។

[21] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២០។

"គោលការណ៍ច្បាប់ដែលមានច្បាស់លាស់"[22] នេះជាកត្តាដែល ស.ច.ស. ត្រូវធ្វើឡើងរួមគ្នាដើម្បីសម្រេចថា តើជនត្រូវចោទគឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ឬយ៉ាងណា[23]។

៧. បញ្ហាចោទនៅចំពោះមុខ អ.ប.ជ. គឺមិនមែនថា តើខ្លួនយល់ស្របជាមួយនឹងសេចក្តីសន្និដ្ឋានរបស់ ស.ច.ស. ម្នាក់ ឬ ម្នាក់ទៀតនោះទេ ប៉ុន្តែគឺថាតើ ស.ច.ស. បានអនុវត្តអំណាចឆន្ទានុសិទ្ធិបានត្រឹមត្រូវ ឬយ៉ាងណា នៅពេលសម្រេចលើយុត្តាធិការបុគ្គល[24]។ ដើម្បីអាចឱ្យ អ.ប.ជ. ច្រាន

[22] អ.ប.ជ. មិនបានកំណត់និយមន័យ "គោលការណ៍ច្បាប់ដែលមានច្បាស់លាស់" ដែលអនុវត្តចំពោះការសម្រេចលើយុត្តាធិការបុគ្គលនោះទេ។ *សូមមើល រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២០ ដែលដកស្រង់ការជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៅចំពោះមុខសាលជម្រះក្តីយោធាអន្តរជាតិ ទីក្រុង Nuremberg ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ១៩៤៥ ដល់ថ្ងៃទី ១ ខែតុលា ឆ្នាំ ១៩៤៦ ភាគ I ទំព័រ ២៥៦៖ "គួរកត់សម្គាល់ថា មាត្រា ៩ ប្រើពាក្យថា 'សាលាជម្រះក្តីនេះអាចប្រកាស' ដូច្នេះ សាលាជម្រះក្តីនេះ មានឆន្ទានុសិទ្ធិក្នុងការសម្រេចថា តើខ្លួននឹងប្រកាស ឬ មិនប្រកាសអំពីអង្គការចាត់តាំងឧក្រិដ្ឋណាមួយនោះ។ ឆន្ទានុសិទ្ធិនេះ ជាឆន្ទានុសិទ្ធិតុលាការ ហើយមិនអនុញ្ញាតឱ្យមានអំពើធ្វើតាមទំនើងចិត្តនោះទេ ប៉ុន្តែ គួរត្រូវបានអនុវត្តឱ្យស្របទៅនឹងគោលការណ៍ច្បាប់ដែលមានច្បាស់លាស់ ដែលគោលការណ៍សំខាន់បំផុតមួយ ក្នុងចំណោមគោលការណ៍ច្បាប់ទាំងនោះ កំណត់ថា ពិរុទ្ធភាពព្រហ្មទណ្ឌមានលក្ខណៈជាបុគ្គល ហើយការផ្តន្ទាទោសទ្រង់ទ្រាយធំ គួរត្រូវបានចៀសវាង"។

[23] កត្តាទាំងនេះរួមមាន៖ **ក.** ចេតនារបស់ភាគីនៃកិច្ចព្រមព្រៀងក្នុងការកម្រិតយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ឱ្យនៅត្រឹមជនទាំងឡាយណាដែលមានការទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ **ខ.** គោលការណ៍ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* និង ការបកស្រាយតឹងរ៉ឹងចំពោះច្បាប់ព្រហ្មទណ្ឌ។ **គ.** ការធ្វើសេចក្តីសម្រេចនៅក្នុងរចនាសម្ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ (ពោលគឺកម្រិតដែលជនត្រូវចោទមានលទ្ធភាពចូលរួមចំណែក ឬ សម្រេចគោលនយោបាយរបស់ ប.ក.ក. និង/ឬ ការអនុវត្តគោលនយោបាយទាំងនោះ) និង **ឃ.** ស្ថានទម្ងន់នៃអំពើរបស់ជនត្រូវចោទ និង ផលប៉ះពាល់ពីអំពើទាំងនោះ អាស្រ័យទៅតាមចេតនារបស់ភាគីនៃកិច្ចព្រមព្រៀង។ *សូមមើល* ដីកាដំណោះស្រាយរឿងក្តី ០០៤/១ កថាខណ្ឌ ៣-៤១។

[24] *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២៥) *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម* ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D164/3/6 កថាខណ្ឌ ២៥-២៦ ដែលដកស្រង់រឿងក្តី *Milošević តទល់នឹង រដ្ឋអាជ្ញា* សំណុំរឿងលេខ IT-02-54-AR73.7 សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការចាត់តាំងមេធាវីការពារក្តី ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០០៤ កថាខណ្ឌ ៩-១០។ *សូមមើលផងដែរ រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការណែនាំឱ្យពិចារណាឡើងវិញលើសំណើសុំ D153, D172, D173, D174, D178 និង D284 ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ D300/1/7 កថាខណ្ឌ ១៤។ *រឿងក្តី*

ចោលការសម្រេចលើយុត្តាធិការបុគ្គលរបស់ ស.ច.ស. បាន ការសម្រេចនោះត្រូវ៖ **ក.** ផ្អែកលើកំហុសអង្គច្បាប់ ដែលនាំឱ្យសេចក្តីសម្រេចនោះគ្មានសុពលភាព **ខ.** ផ្អែកលើកំហុសអង្គហេតុដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌ និង/ឬ **គ.** "មានភាពអយុត្តិធម៌ ឬ មិនសមហេតុផល" ដែលជាការបំពានលើឆន្ទានុសិទ្ធិ[25]។

៨. ខណៈដែលកំហុសអង្គច្បាប់ត្រូវបានពិនិត្យមើល *សាជាថ្មី*[26] កំហុសអង្គហេតុត្រូវបានពិនិត្យមើលតាមបទដ្ឋាននៃភាពសមហេតុផល ដើម្បីសម្រេចថាតើ គ្មាន ស.ច.ស. ដែលមានហេតុផលណាម្នាក់ អាចឈានដល់ការយល់ឃើញទៅលើអង្គហេតុដែលកំពុងមានបញ្ហានេះ ឬយ៉ាងណា[27]។ អ.ប.ជ. បានបដិសេធមិនដាក់ជំនួសការយល់ឃើញរបស់ខ្លួន នៅពេលសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិពាក់ព័ន្ធនឹងបញ្ហាអង្គហេតុ[28] ពីព្រោះ ស.ច.ស. បានធ្វើការវាយតម្លៃ ដោយមាន "ការយល់ដឹង

---

*នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦៧) សាលដីកាស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៣៦។

[25] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២១។

[26] *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៤៥ & ១៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D427/2/15 កថាខណ្ឌ ៨៦។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ១១៣។

[27] *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ១៤៥ & ១៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D427/2/15 កថាខណ្ឌ ៨៦។

[28] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ២៥-២៦។ *សូមមើលផងដែរ រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦៧) សាលដីកាស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភ័ស្តុតាង

ជ្រៅជ្រះទៅលើសំណុំរឿង”[29]។ ខណៈដែល អ.ប.ជ. បានយល់ឃើញថា “ខ្លួនបំពេញតួនាទីជាសភាស៊ើបសួរកម្ពុជា” ដែលមានអំណាចស៊ើបអង្កេតរឿងក្តីដោយខ្លួនឯងនៅពេលទទួលបានដីកាលើកលែងការចោទប្រកាន់[30] អ.ប.ជ. ធ្លាប់បានទទួលស្គាល់ថា ខ្លួនមិនត្រូវបាន “បង្កើតឡើង” ឬ “រៀបចំដើម្បីដឹកនាំការស៊ើបអង្កេត” នៅក្នុងបរិបទពិសេសនៃរឿងក្តីរបស់ អ.វ.ត.ក. “ដែលជាសំណុំរឿងពាក់ព័ន្ធនឹងការស៊ើបអង្កេតក្នុងទំហំធំ និង ជាប់ពាក់ព័ន្ធនឹងករណីច្រើនលើសលប់”[31] នោះឡើយ។

៩. អ.ប.ជ. ត្រូវសម្រេចផងដែរថា កំហុសណាមួយដែលជា “កត្តាកំណត់ជាមូលដ្ឋាន” នៃការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ ស.ច.ស.[32] ពោលគឺថា សេចក្តីសម្រេចរបស់ ស.ច.ស. បានផ្អែកលើ

---

បន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៦៧។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការណែនាំឱ្យពិចារណាឡើងវិញលើសំណើសុំ D153, D172, D173, D174, D178 និង D284 ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ D300/1/7 កថាខណ្ឌ ១៥៖ “[អ.ប.ជ.] បានលើកឡើងដដែលៗថា ‘ [អ.ប.ជ.] មិនអាចយកការយល់ឃើញរបស់ខ្លួន ទៅដាក់ជំនួសការយល់ឃើញរបស់ [ស.ច.ស.] បានទេ’”។

[29] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦៧) សាលដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៦៧។

[30] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២២ ដែលដកស្រង់ *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០២) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ “ឌុច” ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ ៤១-៤២។

[31] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D164/3/6 កថាខណ្ឌ ២៤។

[32] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២១ ដែលដកស្រង់ *រឿងក្តីរបស់ យឹម ទិត្យ* សំណុំរឿង

កំហុសដែលបានប្រព្រឹត្ត។ កំហុសអង្គច្បាប់ បើទោះជារកឃើញ ត្រូវមានលក្ខណៈសំខាន់ជាមូលដ្ឋាន និង មានអានុភាពទៅលើផ្នែកសម្រេចសេចក្តី ដែល "ពិតជា" នាំឱ្យការសម្រេចលើយុត្តាធិការបុគ្គលរបស់ ស.ច.ស. គ្មានសុពលភាព[33]។ កំហុសអង្គហេតុ បើទោះជារកឃើញ ត្រូវតែប៉ះពាល់

លេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាផ្លូវភេទ នៅគុកលេខ ៨ និង នៅក្នុងស្រុកបាកាន ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៨ ឯកសារ D365/3/1/5 កថាខណ្ឌ ១៥។ *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៦) សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីដប់របស់ អោ អាន ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១៧ ឯកសារ D343/4 កថាខណ្ឌ ១២។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦៧) សាលដីកាស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៣៦។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការណែនាំឱ្យពិចារណាឡើងវិញលើសំណើសុំ D153, D172, D173, D174, D178 និង D284 ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D300/1/7 កថាខណ្ឌ ១៤។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំសម្ភាសន៍បុគ្គល ដូចរាយនាមនៅក្នុងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរស្តីពីការបាត់ខ្លួនដោយបង្ខំ និង ការរៀបការដោយបង្ខំ ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ D310/1/3 កថាខណ្ឌ ១៥-១៦។ *សូមមើលផងដែរ រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ" ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០១០ ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D353/2/3 កថាខណ្ឌ ៨។

[33] *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធ សំណើសុំសម្ភាសន៍បុគ្គលដូចរាយនាមនៅក្នុងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ស្តីពីការបាត់ខ្លួនដោយបង្ខំ និង ការរៀបការដោយបង្ខំ ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ D310/1/3 កថាខណ្ឌ ១៦៖ "[អ.ប.ជ.] កត់សម្គាល់ឃើញថា មិនមែនគ្រប់កំហុសអង្គច្បាប់ ឬ កំហុសអង្គហេតុទាំងអស់ អាចនឹងធ្វើឱ្យការអនុវត្តឆន្ទានុសិទ្ធិគ្មានសុពលភាព ដែលជាហេតុនាំឱ្យច្រានចោលដីកាសម្រេចឡើយ។ ដើមបណ្តឹងឧទ្ធរណ៍មានបន្ទុកក្នុងការបង្ហាញថា កំហុសអង្គច្បាប់ ឬ កំហុសអង្គហេតុ ពិតជានាំឱ្យសេចក្តីសម្រេចនោះគ្មានសុពលភាព ឬ នាំឱ្យមានភាពអយុត្តិធម៌"។

ដល់សេចក្តីសន្និដ្ឋាន ដែល "ពិតជា" នាំឱ្យមានការថ្លោះធ្លោយដល់ភាពយុត្តិធម៌[34] (ពោលគឺ "លទ្ធផលដែលមានភាពអយុត្តិធម៌ជាទីបំផុតនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការ")[35]។ ការបំពានឆន្ទានុសិទ្ធិត្រូវ "បង្ខំឱ្យធ្វើការសន្និដ្ឋាន ដោយពួកគាត់មិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានប្រយ័ត្នប្រយែង"[36]។

១០. នៅពេល អ.ប.ជ. រកឃើញកំហុស ឬ ការរំលោភបំពានដែលមានអានុភាពកំណត់ជាមូលដ្ឋានទៅលើការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ ស.ច.ស. អ.ប.ជ. នឹង "ជាធម្មតា បញ្ជូនសេចក្តីសម្រេច" ទៅ ស.ច.ស. ដើម្បីធ្វើការពិចារណាឡើងវិញ[37]។ មានតែក្នុងករណីលើកលែងប៉ុណ្ណោះ ដូចជា នៅពេលបញ្ហាត្រូវបានបង្វិលជូន ស.ច.ស. ដើម្បីធ្វើការពិចារណាឡើងវិញរួចហើយ ហើយ

---

[34] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធ សំណើសុំសម្ភាសន៍បុគ្គលដូចរាយនាមនៅក្នុងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ស្តីពីការបាត់ខ្លួនដោយបង្ខំ និង ការរៀបការដោយបង្ខំ ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ D310/1/3 កថាខណ្ឌ ១៦៖ "[អ.ប.ជ.] កត់សម្គាល់ឃើញថា មិនមែនគ្រប់កំហុសអង្គច្បាប់ ឬ កំហុសអង្គហេតុទាំងអស់ អាចនឹងធ្វើឱ្យការអនុវត្តឆន្ទានុសិទ្ធិគ្មានសុពលភាព ដែលជាហេតុនាំឱ្យច្រានចោលដីកាសម្រេចឡើយ។ ដើមបណ្តឹងឧទ្ធរណ៍មានបន្ទុកក្នុងការបង្ហាញថា កំហុសអង្គច្បាប់ ឬ កំហុសអង្គហេតុ ពិតជានាំឱ្យសេចក្តីសម្រេចនោះគ្មានសុពលភាព ឬ នាំឱ្យមានភាពអយុត្តិធម៌"។ *សូមមើលផងដែរ រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ១៩។

[35] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ១៩ (សេចក្តីយោងខាងក្នុងត្រូវបានលុបចោល)។

[36] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ស (អ.ប.ជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២១។

[37] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩/ក.ស.ច.ស (អ.ប.ជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២២។ *សូមមើលផងដែរ រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦៧) សាលដីកាស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៦៦, ៨១។

ស.ច.ស. បានខកខានមិនបានអនុវត្តតាមការណែនាំរបស់ អ.ប.ជ.[38] ទើប អ.ប.ជ. នឹងជំនួសសេចក្តីសម្រេចរបស់ ស.ច.ស. ដោយសេចក្តីសម្រេចរបស់ខ្លួន[39]។

**គ. គ្មានសម្បទាន និង ការរក្សាសិទ្ធិ**

១១. លោក មាស មុត មិនទទួលយកការរកឃើញអង្គហេតុ ឬ សេចក្តីសន្និដ្ឋានអង្គច្បាប់ណាមួយធ្វើឡើងដោយ ស.ច.ស.អ. ដែលមិនបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះទេ ហើយសុំរក្សាសិទ្ធិពោលប្រាស្រ័យអំពីបញ្ហាទាំងនេះ ប្រសិនបើរឿងក្តីនេះត្រូវបានបញ្ជូនទៅជំនុំជម្រះក្នុងសវនាការ។

**ឃ. សំណើសុំបើកសវនាការជាសាធារណៈ**

១២. "*តម្លាភាពនឹងជម្រះមន្ទិលសង្ស័យ*"[40]។ សវនាការជាសាធារណៈ[41] គឺជាប្រយោជន៍នៃភាពយុត្តិធម៌ ជាប្រយោជន៍សម្រាប់លោក មាស មុត ជាប្រយោជន៍សម្រាប់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ និងជាប្រយោជន៍សម្រាប់សហគមន៍អន្តរជាតិ (ជាពិសេស ប្រទេសម្ចាស់ជំនួយដែលផ្តល់ហិរញ្ញវត្ថុ

---

[38] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦៧) សាលដីកាស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៦៧៖ "ដោយហេតុថា [ស.ច.ស.] ខកខានក្នុងការធ្វើតាមសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះ ក្នុងការបញ្ជាក់ពីសំអាងហេតុសម្រាប់ការបដិសេធឯកសារនីមួយៗនោះ [អ.ប.ជ.] មិនមានជម្រើសអ្វីក្រៅពីទទួលស្គាល់ថា ការបញ្ជូនបញ្ហានេះទៅ [ស.ច.ស.] វិញ ហើយរង់ចាំដីកាសម្រេចលើកទីបីនេះ ប្រហែលជាមិនអាចបង្កើតឱ្យមានការវិភាគអង្គហេតុជាក់លាក់ ដែលជាតម្រូវការសម្រាប់ដីកាសម្រេចប្រភេទនេះបានទេ"។

[39] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩/ក.ស.ច.ស (អ.ប.ជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២២។

[40] អត្ថបទរបស់ Louis D. Brandeis៖ តើការផ្សព្វផ្សាយជាសាធារណៈអាចធ្វើអ្វីបានខ្លះ *(What Publicity Can Do)* ព្រឹត្តិប័ត្រព័ត៌មាន HARPER ប្រចាំសប្តាហ៍ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩១៣ ទំព័រ ១០។

[41] អនុលោមតាមវិធាន ៧៧(៦) អ.ប.ជ. អាច "សម្រេចថា នីតិវិធីទាំងស្រុង ឬ មួយផ្នែកនៃសវនាការត្រូវធ្វើឡើងជាសាធារណៈ ជាពិសេស នៅពេលដែលសំណុំរឿងនោះអាចត្រូវបានបញ្ចប់ ដោយសេចក្តីសម្រេចរបស់ខ្លួន ដូចជា ពាក្យបណ្តឹងឧទ្ធរណ៍ ឬ ពាក្យសុំពាក់ព័ន្ធទៅនឹងបញ្ហាយុត្តាធិការ ឬ មូលហេតុដែលនាំឱ្យរលត់បណ្តឹងអាជ្ញា បើអង្គបុរេជំនុំជម្រះយល់ឃើញថា ដើម្បីជាប្រយោជន៍យុត្តិធម៌ និង មិនធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬ វិធានការការពាររបស់តុលាការ"។

ដល់ អ.វ.ត.ក.) និង ជាប្រយោជន៍សម្រាប់ អ.វ.ត.ក. ដែលត្រូវបានរំពឹងថា នឹងជាតុលាការគំរូសម្រាប់ប្រជាពលរដ្ឋកម្ពុជា សិក្សារៀនសូត្រតាម និង ធ្វើឱ្យល្អជាង[42]។ បើពិចារណាទៅលើការផ្សព្វផ្សាយជាសាធារណៈ (និង ភាពចម្រូងចម្រាស) ដែលបង្កើតឡើងដោយរឿងក្តីនេះ[43] ការស៊ើបអង្កេតជិតមួយទសវត្សរ៍ ការចេញដីកាដំណោះស្រាយចំនួនពីរ និង បណ្តឹងឧទ្ធរណ៍ខ្វែង ចម្លើយ និង ការឆ្លើយតបជាបន្តបន្ទាប់ សវនាការជាសាធារណៈមិនត្រឹមតែមានប្រយោជន៍សម្រាប់ អ.ប.ជ. នៅក្នុងការធានាថា ភាពយុត្តិធម៌នឹងត្រូវបានធ្វើបានសម្រេចប៉ុណ្ណោះទេ ប៉ុន្តែក៏សំខាន់នៅក្នុងការបង្ហាញឱ្យឃើញថា ភាពយុត្តិធម៌ត្រូវបានធ្វើសម្រេចបានផងដែរ[44]។ ការអនុញ្ញាតឱ្យលោក មាស មុត ពោលប្រាស្រ័យអំពីបញ្ហានីតិវិធី និង អង្គសេចក្តីដែលអាចបញ្ចប់រឿងក្តីគាត់ នឹងមានផលប្រយោជន៍យ៉ាងខ្លាំងដល់ អ.វ.ត.ក. ដោយចំណាយធនធានតិច ហើយនឹងមិនបង្កព្យសនកម្មដល់ភាគីណាមួយ ឬ ធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈនោះឡើយ។

---

[42] *សូមមើល ឧទា. រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងជិតចិត្តចំពោះលោកចៅក្រម និល ណុន និង សំណើពាក់ព័ន្ធផ្សេងៗ ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១១ ឯកសារ E5/3 កថាខណ្ឌ ១៤ ដែលពន្យល់ថា អ.វ.ត.ក. អាចជាតុលាការគំរូមួយ សម្រាប់ជួយជំរុញឱ្យមានការធានានូវឯករាជ្យភាព និង សុចរិតភាពនៅក្នុងស្ថាប័នតុលាការ។

[43] *សូមមើល ឧទា.* អត្ថបទរបស់ Seth Mydans៖ *ចៅក្រមខ្វែងយោបល់គ្នាអំពីថា តើសាលាជម្រះក្តីកម្ពុជាអាចបន្តកាត់ក្តីមេបញ្ជាការខ្មែរក្រហមបានឬយ៉ាងណា* កាសែតញូវយ៉កថែម ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ *ដែលអាចរកបាននៅលើគេហទំព័រ* https://www.nytimes.com/2018/11/28/world/asia/cambodia-tribunal-genocide.html។ អត្ថបទសារព័ត៌មានរៀបរៀងដោយ Taing Vida៖ *អ.វ.ត.ក. នឹងពិចារណាអំពីតួនាទីរបស់ មាស មុត ក្នុងពេលឆាប់ៗនេះ* សារព័ត៌មាន KHMER TIMES ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០១៨ *ដែលអាចរកបាននៅលើគេហទំព័រ* https://www.khmertimeskh.com/552294/eccc-to-soon-determine-role-of-meas-muth/។ អត្ថបទសារព័ត៌មានរៀបរៀងដោយ Alessandro Marazzi Sassoon៖ *សហព្រះរាជអាជ្ញាសាលាក្តីខ្មែរក្រហមខ្វែងយោបល់គ្នាលើរឿងក្តីរបស់ មុត* សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១៧ *ដែលអាចរកបាននៅលើគេហទំព័រ* https://www.phnompenhpost.com/national-kr-tribunal/khmer-rouge-prosecutors-split-muth-case។

[44] នៅក្នុងពាក្យពេចន៍របស់ Lord Hewart C.J. ដែលលើកឡើងថា៖ "យុត្តិធម៌មិនគួរត្រឹមតែបានសម្រេចឡើងប៉ុណ្ណោះទេ ប៉ុន្តែគួរត្រូវបានគេមើលឃើញយ៉ាងច្បាស់ក្រឡែត និង ដោយគ្មានមន្ទិលសង្ស័យថាយុត្តិធម៌ត្រូវបានសម្រេចឡើងមែន [Justice should not only be done, but should manifestly and undoubtedly be seen to be done]។ រឿងក្តី *R តទល់នឹង Sussex Justices, Ex parte McCarthy* [1924] 1 KB 256, [1923] All ER 233។

## III. សាវតារ

១៣. ជិតមួយទសវត្សរ៍មកហើយ លោក មាស មុត បានស្ថិតនៅក្រោមការឃ្លាំមើលរបស់ ស.ច.ស. ជាតិម្នាក់ និង អន្តរជាតិចំនួនប្រាំនាក់បន្តបន្ទាប់គ្នា។ ក្រោយពេល ស.ច.ស. យូ ប៊ុនឡេង និង Siegfried Blunk បានចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ នៅចុងឆ្នាំ ២០១១ មក ចៅក្រម Blunk ដែលជា ស.ច.ស.អ. ទីពីរ បានលាលែងពីមុខដំណែង បន្ទាប់ពីរូបគាត់ និង ចៅក្រម យូ ប៊ុនឡេង រួមគ្នាបង្ហាញការយល់ឃើញថា អ.វ.ត.ក. មិនមានយុត្តាធិការកាត់ទោស លោក មាស មុត បានឯកភាពមិនចោទប្រកាន់គាត់ និង បញ្ចប់ការស៊ើបអង្កេត។ រយៈពេលប្រាំពីរឆ្នាំបានកន្លងផុតនៅចន្លោះពេលបញ្ចប់ការស៊ើបអង្កេត និង ការចេញដីកាសម្រេចលើកលែងចោទប្រកាន់របស់ចៅក្រម យូ ប៊ុនឡេង។ អ្នកស៊ើបអង្កេត អ្នកវិភាគ អ្នកជំនាញ មន្ត្រីច្បាប់ និង អ្នកបកប្រែរាប់មិនអស់ បានមកប្រទេសកម្ពុជា ស៊ើបអង្កេត ស៊ើបអង្កេតឡើងវិញ និង វិភាគភ័ស្តុតាងដែលប្រមូលបាន ដើម្បីធ្វើសេចក្តីសន្និដ្ឋានអំពីយុត្តាធិការរបស់ អ.វ.ត.ក. លើលោក មាស មុត។ គ្មានភ័ស្តុតាងបន្ថែមណាមួយដែលប្រមូលបាន អាចឱ្យចៅក្រម យូ ប៊ុនឡេង កែប្រែសេចក្តីសន្និដ្ឋានរបស់គាត់ដែលថា លោក មាស មុត មិនបានបង្កើត ឬ មានឥទ្ធិពលលើគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ("ប.ក.ក.") និង ដែលថា លោក មាស មុត មិនដែលប្រើប្រាស់អំណាចលើសពីអំណាចតិចតួចរបស់គាត់នោះឡើយ។ ចៅក្រម Michael Bohlander ជាចៅក្រមទីប្រាំ និង ជា ស.ច.ស.អ. បច្ចុប្បន្ន បានរកឃើញផ្ទុយពីនេះ។ ស.ច.ស. យូ ប៊ុនឡេង និង Bohlander បានចេញដីកាដំណោះស្រាយផ្ទុយគ្នា ក្នុងពេលដំណាលគ្នា នៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ ដីកាមួយសម្រេចលើកលែងការចោទប្រកាន់ និង ដីកាមួយទៀតសម្រេចបញ្ជូន លោក មាស មុត ទៅជំនុំជម្រះ។

### ក. កិច្ចស៊ើបសួរ

១៤. *ការចាប់ផ្តើមកិច្ចស៊ើបសួរ* កិច្ចស៊ើបសួរបានចាប់ផ្តើមនៅថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០០៩[45]។ នៅពេលនោះ ស.ច.ស.ជ. និង ស.ច.ស.អ. Marcel Lemonde ដែលជា ស.ច.ស.អ. ដំបូងគេ បាន

[45] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ២ ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ របស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ")។ សហព្រះ

ធ្វើការស៊ើបអង្កេតឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយខ្មែរក្រហម អស់រយៈពេលពីរឆ្នាំជាងនៅ អ.វ.ត.ក. ដើម្បីកំណត់ថា អ្នកដែលត្រូវបានស៊ើបអង្កេតទាំងនោះ គឺជាមេដឹកនាំជាន់ខ្ពស់ ឬ ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតដំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង នៅទូទាំងប្រទេសកម្ពុជា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យចន្លោះពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ១ ៩៧៥ ដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ ១៩៧៩ ឬយ៉ាងណា[46]។ចៅក្រមទាំងពីរបានបញ្ចប់កិច្ចស៊ើបសួរនៅក្នុងរឿងក្តី ០០១ ដោយរកឃើញថា កាំង ហ្គេកអ៊ាវ *ហៅ* "ឌុច" ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត[47] ហើយជិតនឹងបញ្ចប់កិច្ចស៊ើបសួរនៅក្នុងរឿងក្តី ០០២។ នៅពេលកំណត់យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. លើអ្នកដែលត្រូវបានស៊ើបអង្កេតនៅក្នុងរឿងក្តី ០០២ នៅក្នុងចំណោមសម្ភារៈឯកសារផ្សេងៗ ស.ច.ស. បានពិនិត្យមើលកំណត់ហេតុស្តាប់ចម្លើយចំនួនជាង ១០០០ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងចំនួន ៣៦ និង ភ័ស្តុតាងពាក់ព័ន្ធនឹងអង្គហេតុចំនួនជាង ២២៣.០០០ ទំព័រ[48]។ នៅពីក្រោយកិច្ចការនេះ ស.ច.ស. បានបង្កើតផែនការការងារលម្អិត ដើម្បីស៊ើបអង្កេតលោក មាស មុត[49]

---

រាជអាជ្ញាមិនបានយល់ស្របគ្នាអំពីថា តើត្រូវស្នើសុំឱ្យ ស.ច.ស. បើកកិច្ចស៊ើបសួរទៅលើរឿងក្តី ០០៣ ឬយ៉ាងណា។ ដោយសារតែ អ.ប.ជ. មិនអាចទទួលបានសំឡេងភាគច្រើនលើសលប់លើការខ្វែងយោបល់គ្នានេះ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ.") ត្រូវបានអនុញ្ញាតឱ្យបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់គាត់ទៅឱ្យ ស.ច.ស. ដើម្បីបើកកិច្ចស៊ើបសួរ។ *សូមមើល* ឧបសម្ព័ន្ធ ១៖ សំណៅសាធារណៈមានកោសលុបនៃសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០៩ ឯកសារ D1/1.3 កថាខណ្ឌ ៤៥។

[46] ស.ច.ស. បានទទួលសំណើសុំឱ្យបើកកិច្ចស៊ើបសួរទៅក្នុងរឿងក្តី ០០១ និង ០០២ កាលពីថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៧។ *សូមមើល រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយបញ្ជូន កាំង ហ្គេកអ៊ាវ ហៅ ឌុច ទៅជំនុំជម្រះ ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D99 កថាខណ្ឌ ៤។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D427 កថាខណ្ឌ ៣។

[47] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយបញ្ជូន កាំង ហ្គេកអ៊ាវ ហៅ ឌុច ទៅជំនុំជម្រះ ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D99 កថាខណ្ឌ ១២៩។

[48] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D427 កថាខណ្ឌ ១៧។

[49] របាយការណ៍តុលាការរបស់ អ.វ.ត.ក. លេខ ២៦ (ចុះខែមិថុនា ឆ្នាំ ២០១០) ទំព័រ ២ គេហទំព័រ https://www.eccc.gov.kh/sites/default/files/publications/The%20Court%20Report%20%5BJune%202010%5D%20FINAL.pdf។

ដោយប្រមូលភស្តុតាងបានចំនួនជាង ១.១៣០[50] នៅមុនពេលដែល ស.ច.ស.អ. Lemonde បានលាលែងដំណែង "ទៅរៀបចំផែនការរយៈពេលវែងផ្សេងទៀត"[51]។

១៥. ស.ច.ស.អ. Blunk បានបន្តការងារពី ស.ច.ស.អ. Lemonde នៅថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១០[52] ហើយបានបន្តការស៊ើបអង្កេត រួមជាមួយនឹង ស.ច.ស.ជ. ចាប់ពីពេលដែលការស៊ើបអង្កេតបានបន្សល់មិនទាន់ធ្វើ[53]។ ក្នុងនាមជាសហសេវិក ស.ច.ស.ជ. និង ស.ច.ស.អ. បានផ្តោតជាចម្បងលើការកំណត់ថាតើ លោក មាស មុត ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ឬយ៉ាងណា[54]។ ចៅក្រមទាំងពីរ "បានបង្កើតក្រុមការងាររួមគ្នា"[55] "បានឯកភាពគ្នាលើវិធីសាស្ត្រនៃការស៊ើបអង្កេត"[56] និង បានស៊ើបអង្កេត "ដោយរលូន និង ឯកភាពគ្នាទាំងស្រុង"[57]។ ក្នុងរយៈពេលប្រាំខែក្រោយ ស.ច.ស. បានប្រមូលភស្តុតាងបន្ថែម[58] និង បានពិនិត្យមើលភស្តុតាងដាក់បន្ទុក និង

---

[50] ការស្រាវជ្រាវនៅលើប្រព័ន្ធ ZyLAB បង្ហាញថា នៅចន្លោះពីថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១០ ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស.") បានដាក់ឯកសារចំនួន ១.១៣៤ ច្បាប់ ជាភាសាអង់គ្លេស ភាសាខ្មែរ និង ភាសាបារាំងទៅក្នុងសំណុំរឿង។ *សូមមើល* ប្រព័ន្ធ ZyLAB "សំណុំរឿង CF003" "កាលបរិច្ឆេទដាក់ឯកសារ៖ ចន្លោះពីថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១០" និង "ភាគីដាក់ឯកសារ៖ ក.ស.ច.ស."។ ឯកសារខ្លះត្រូវបានដាក់នៅក្នុងសំណុំរឿងក្នុងអំឡុងពេលនេះ អាចត្រួតគ្នា។

[51] របាយការណ៍តុលាការរបស់ អ.វ.ត.ក. លេខ ២៩ (ចុះខែកញ្ញា ឆ្នាំ ២០១០) ទំព័រ ២ គេហទំព័រ https://www.eccc.gov.kh/sites/default/files/publications/Court_Report_September2010.pdf។ *សូមមើលផងដែរ* គេហទំព័រ អ.វ.ត.ក. *ចៅក្រម Marcel Lemonde*, https://www.eccc.gov.kh/en/person/judge-marcel-lemonde។

[52] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *បណ្ឌិត Siegfried Blunk ត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី* ចុះថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១០ គេហទំព័រ https://www.eccc.gov.kh/en/articles/dr-siegfried-blunk-appointed-new-international-co-investigating-judge។

[53] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *សេចក្តីប្រកាសព័ត៌មានដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១១ គេហទំព័រ https://www.eccc.gov.kh/sites/default/files/documents/courtdoc/2012-12-24%2016%3A37/E189_3_1_1.1.3_EN.pdf.

[54] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៨។

[55] របាយការណ៍តុលាការរបស់ អ.វ.ត.ក. លេខ ៣៣ (ចុះខែកុម្ភៈ ឆ្នាំ ២០១១) ទំព័រ ៧ គេហទំព័រ https://www.eccc.gov.kh/sites/default/files/publications/Court_Report_February_2011.pdf។

[56] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៨។

[57] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១។

[58] ការស្រាវជ្រាវនៅលើប្រព័ន្ធ ZyLAB បង្ហាញថា នៅចន្លោះពីថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១០ ដល់ថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ក.ស.ច.ស. បានដាក់ឯកសារចំនួន ៣០២ ច្បាប់ជាភាសាអង់គ្លេស ភាសាខ្មែរ និង ភាសាបារាំងទៅក្នុងសំណុំរឿង ០០៣។ *សូម*

ដោះបន្ទុកចំនួនជាង ៣.០០០ ពីក្នុងរឿងក្ដី ០០១ រឿងក្ដី ០០២ និង រឿងក្ដី ០០៣[59] រួមមាន សារទូរលេខ កំណត់ហេតុប្រជុំ សេចក្ដីថ្លែងការណ៍ពីសាក្សីរណុកក្នុង ដូចជា កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុស្ដាប់ចម្លើយសាក្សីផ្សេងទៀត និង សម្ភារឯកសារមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា[60]។

១៦. *ការបញ្ចប់ការស៊ើបអង្កេត* នៅពេលបញ្ចប់ការស៊ើបអង្កេតដែលមានរយៈពេលចំនួន ២០ ខែ នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១[61] ស.ច.ស. "បានឯកភាពជាឯកច្ឆ័ន្ទ" ថា មិនគួរចោទប្រកាន់ លោក មាស មុត នោះទេ[62]។ នៅពេលសេចក្ដីថ្លែងការណ៍លេចឡើងនៅក្នុងសារព័ត៌មាន បានចោទសួរលើបញ្ហាឯករាជ្យភាព និង សុចរិតភាពរបស់ ស.ច.ស.អ. Blunk គាត់បានលាលែងពីមុខដំណែង[63]។ ក្រោយមកបន្តិច ឯកឧត្ដម សុខ អាន បានគូសបញ្ជាក់អំពី "ភាពចាំបាច់សម្រាប់អ្នកធ្វើសេចក្ដីសម្រេចទាំងសងខាង ក្នុងការបំពេញការទទួលខុសត្រូវ ដោយមិនត្រូវឱ្យមានការរំខានពីការទាយស្មានហួសហេតុពេក សម្ពាធ និង ការជ្រៀតជ្រែកពីសារព័ត៌មាន និង ប្រភពខាងក្រៅផ្សេងទៀត"[64]។

---

*មើល* ប្រព័ន្ធ ZyLAB "សំណុំរឿង៖ CF003" "កាលបរិច្ឆេទដាក់ឯកសារ៖ ចន្លោះពីថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១០ ដល់ថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១" និង "ភាគីដាក់ឯកសារ៖ ក.ស.ច.ស."។ ឯកសារខ្លះដែលបានដាក់ទៅក្នុងសំណុំរឿងក្នុងអំឡុងពេលនេះអាចត្រួតគ្នា។

[59] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២, ៤៨។ *សូមមើលផងដែរ* ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៥៩។

[60] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២។ *សូមមើលផងដែរ* ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២, ៤៨។

[61] សេចក្ដីជូនដំណឹងស្ដីពីការបិទការស៊ើបសួរ ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ឯកសារ D13។

[62] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥៣។

[63] សេចក្ដីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *សេចក្ដីប្រកាសព័ត៌មានដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១១ គេហទំព័រ https://www.eccc.gov.kh/sites/default/files/documents/courtdoc/2012-12-24%2016%3A37/E189_3_1_1.1.3_EN.pdf។ ស.ច.ស.អ. Blunk បានលាលែងពីដំណែងចាប់ពីថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១១។ *សូមមើល* គេហទំព័រ អ.វ.ត.ក.៖ *បណ្ឌិត Siegfried Blunk* គេហទំព័រ https://www.eccc.gov.kh/en/person/dr-siegfried-blunk។

[64] របាយការណ៍តុលាការរបស់ អ.វ.ត.ក. លេខ ៤២ (ខែវិច្ឆិកា ឆ្នាំ ២០១១) ទំព័រ ៥ គេហទំព័រ http://www.eccc.gov.kh/sites/default/files/publications/November%202011%20Court%20Report%20-%20FINAL2_0.pdf។

១៧. *ការបើកការស៊ើបអង្កេតឡើងវិញ* រយៈពេលពីរខែក្រោយ ស.ច.ស.អ. Blunk លាលែងពីដំណែង អតីត ស.ច.ស.អ. បម្រុង (“ស.ច.ស.អ.ប.”) Larurent Kasper-Ansermet ដែលមិនធ្លាប់បានធ្វើសម្បថចូលកាន់ដំណែងជា ស.ច.ស.អ.[65] បានបើកការស៊ើបអង្កេតឡើងវិញដោយឯកតោភាគីលើលោក មាស មុត[66]។ ស.ច.ស.ជ. បានដាស់តឿនឱ្យគាត់ពិនិត្យមើលភ័ស្តុតាងឡើងវិញដោយប្រុងប្រយ័ត្ននៅមុនពេលធ្វើ “ចំណាត់ការតាមបែបប្រញាប់ប្រញាល់” ណាមួយ[67]។ ស.ច.ស.អ.ប. Kasper-Ansermet បានទទួលស្គាល់ថា គាត់មិនបានពិនិត្យមើលសំណុំរឿងឡើងវិញនោះទេ “ប៉ុន្តែ ស្នើភ្លាមៗនូវការស៊ើបអង្កេតឡើងវិញ” ដោយសារគាត់ខ្លាចថា ស.ច.ស.ជ. នឹងចេញដីកាបញ្ជូនរឿងឱ្យពិនិត្យ ដែលបានព្រាងរួមគ្នាជាមួយ ស.ច.ស.អ. Blunk[68] ។ ប្រាំខែក្រោយមក គាត់បានលាលែងពីមុខដំណែង[69]។

---

[65] នៅថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០១២ រាជរដ្ឋាភិបាលកម្ពុជា (“RGC”) បានជូនដំណឹងជាផ្លូវការដល់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ (“អ.ស.ប.”) អំពីសេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា មិនតែងតាំង ស.ច.ស.អ.ប. Kasper-Ansermet ឱ្យធ្វើជា ស.ច.ស.អ.។ សេចក្តីប្រកាសព័ត៌មានរបស់ អ.ស.ប.៖ *សេចក្តីថ្លែងការណ៍ដោយអ្នកនាំពាក្យរបស់លោកអគ្គលេខាធិការស្តីពីប្រទេសកម្ពុជា* ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១២ គេហទំព័រ https://www.un.org/sg/en/content/sg/statement/2012-01-20/statement-attributable-spokesperson-secretary-general-cambodia។

[66] ដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ ចុះថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១១ ឯកសារ D28។ ស.ច.ស.អ.ប. Kasper-Ansermet បានបើកកិច្ចស៊ើបសួរឡើងវិញ បន្ទាប់ពីបណ្តឹងឧទ្ធរណ៍ទាំងអស់ពាក់ព័ន្ធនឹងការបញ្ចប់កិច្ចស៊ើបសួរដោយ ស.ច.ស.ជ. និង ស.ច.ស.អ. Blunk ត្រូវបានដោះស្រាយរួចរាល់។ *សូមមើល* សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹងសេចក្តីសម្រេចស្តីពីសំណើសុំពន្យាពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ ២០១១ ឯកសារ D20/4/4។ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹងសេចក្តីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០១១ ឯកសារ D26/1/3។

[67] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតជាតិ* ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១២ គេហទំព័រ https://www.eccc.gov.kh/en/node/17495។

[68] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតជាតិ* ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១២ គេហទំព័រ https://www.eccc.gov.kh/en/node/17495។

[69] ស.ច.ស.អ.ប. Kasper-Ansermet បានលាលែងពីដំណែងជាផ្លូវការនៅថ្ងៃទី ៤ ខែឧសភា ឆ្នាំ ២០១២។ *សូមមើល* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង* ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០១២ គេហទំព័រ https://www.eccc.gov.kh/en/articles/press-release-international-reserve-co-investigating-judge។

១៨. បន្ទាប់មក Mark Harmon ដែលជាអតីតរដ្ឋអាជ្ញានៅសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានមកដល់។ គាត់បានធ្វើសម្បថចូលកាន់ដំណែងជា ស.ច.ស.អ. ទីបួន នៅថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០១២[70]។ នៅពេល ស.ច.ស.អ. Harmon បានមកដល់ ស.ច.ស.ជ. បានផ្អាកការចេញដីកាបញ្ជូនរឿងទៅពិនិត្យ ដែលបានព្រាងរួមគ្នាជាមួយ ស.ច.ស.អ. Blunk ដោយយល់ឃើញថា ការចេញដីកាបញ្ជូនរឿងទៅពិនិត្យ នៅមុនពេលពិភាក្សាជាមួយនឹង ស.ច.ស.អ. ដែលត្រូវបានតែងតាំងត្រឹមត្រូវ នឹងអាចជា "ការប្រញាប់ប្រញាល់បំពេញកិច្ចនាំឱ្យខុសនីតិវិធី"[71]។ ស.ច.ស.ជ. បានរង់ចាំសមភាគីអន្តរជាតិរបស់ខ្លួន ឱ្យយល់ជ្រួតជ្រាបសំណុំរឿងជាមុនសិន។ នៅថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ស.ច.ស. បានពិភាក្សាអំពីស្ថានភាពនៃការស៊ើបអង្កេត និង បានចុះកំណត់ហេតុនៃការខ្វែងយោបល់គ្នា[72]។ នៅថ្ងៃដដែលនោះ ស.ច.ស.ជ. បានចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ដោយយល់ឃើញថា ការស៊ើបអង្កេតបានបញ្ចប់តាំងពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ មកម្ល៉េះ[73]។ ខណៈពេលនោះ ស.ច.ស.អ. Harmon បានបន្តការ

---

[70] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *លោក Mark Harmon បានធ្វើសច្ចាប្រណិធានចូលកាន់មុខដំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០១២ គេហទំព័រ https://www.eccc.gov.kh/en/articles/mark-harmon-sworn-international-co-investigating-judge។

[71] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតជាតិ* ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១២ គេហទំព័រ https://www.eccc.gov.kh/en/node/17495។ ស.ច.ស.ជ. បានព្យល់ថា គាត់ និង ស.ច.ស.អ. Blunk មិនអាចចុះហត្ថលេខាលើដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ដែលពួកគាត់បានធ្វើសេចក្តីព្រាងរួមគ្នា នៅមុនពេលដែល ស.ច.ស.អ. Blunk លាលែងពីដំណែងបានទេ ពីព្រោះថា អ.ប.ជ. បានទទួលបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ជំទាស់ដីកាសម្រេចរបស់ ស.ច.ស. ដែលបដិសេធសំណើរបស់គាត់សុំឱ្យបំពេញកិច្ចស៊ើបសួររួចទៅហើយ។ *ដូចជើងទំព័រខាងលើ។*

[72] *សូមមើល* សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ប្រតិចារិកសំណុំរឿង ០០២ ចូលទៅក្នុងសំណុំរឿង ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D53/2 កថាខណ្ឌ ១០៖ "**បានឃើញ**ថា នៅថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង Harmon បានចុះហត្ថលេខាលើកំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ទាក់ទងនឹងសុពលភាពនៃឯកសារមួយចំនួន ដែលត្រូវបានដាក់ចូលនៅក្នុងសំណុំរឿង ០០៣ ចាប់តាំងពីការលាលែងពីដំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried Blunk និង ស្ថានភាពបច្ចុប្បន្ននៃកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ (អក្សរដិតខ្មៅនៅក្នុងឯកសារដើម)។

[73] ដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D52។ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២។ *សូមមើលផងដែរ* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងសំណុំរឿង ០០៣* ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០១៣ គេហទំព័រ https://www.eccc.gov.kh/en/articles/statement-co-investigating-judges-regarding-case-003។

ស៊ើបអង្កេត និង ប្រមូលភ័ស្តុតាង[74] ដោយសារតែ តាមដែលលោកយល់ឃើញ ស.ច.ស. មាន "ឆន្ទានុសិទ្ធិសម្រេចដោយឯករាជ្យថាតើនៅពេលណាដែលខ្លួនយល់ឃើញថា ការស៊ើបអង្កេតត្រូវបានបញ្ចប់"[75]។ នៅពេលក្រោយមក ស.ច.ស.ជ. បានបញ្ជូនអនុស្សរណៈទៅ ស.ច.ស.អ. Harmon "អំពីការបិទការស៊ើបអង្កេត និង លទ្ធភាពរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការប្ដឹងទៅកាន់អង្គបុរេជំនុំជម្រះ ស្នើសុំឱ្យបើកការស៊ើបអង្កេតសំណុំរឿងលេខ ០០៣ ឡើងវិញ"[76] ស.ច.ស.អ. Harmon មិនបានឆ្លើយតបនោះទេ។ ផ្ទុយទៅវិញ គាត់បានបន្តស៊ើបអង្កេត និង ប្រមូលភ័ស្តុតាង[77] ដោយនៅទីបំផុត បានដាក់លោក មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យ[78] ក្នុងរយៈពេលបួនខែមុនពេលដែលគាត់លាលែងពីមុខដំណែង "ដោយសារមូលហេតុផ្ទាល់ខ្លួនមួយគត់"[79]។

១៩. *ការស៊ើបអង្កេតបានបញ្ចប់ ម្តងទៀត* បន្ទាប់មក Michael Bohlander បានមកដល់ ហើយបានស្បថចូលកាន់ដំណែងជា ស.ច.ស.អ. ទីប្រាំ នៅថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៥[80]។ មិនខុសពី

---

[74] *សូមមើល* សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ប្រតិចារិកនៃសំណុំរឿង ០០២ ចូលទៅក្នុងសំណុំរឿង ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D53/2 កថាខណ្ឌ ១២។ ដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D54។ ដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D55។

[75] សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ប្រតិចារិកសំណុំរឿង ០០២ ចូលទៅក្នុងសំណុំរឿង ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D53/2 កថាខណ្ឌ ៥ (សេចក្តីយោងខាងក្នុងត្រូវបានលុបចោល)។

[76] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥៤។

[77] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥៥។

[78] ការជូនដំណឹងអំពីបទចោទប្រឆាំង មាស មុត ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១៥ ឯកសារ D128.1។

[79] សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក.៖ *ចៅក្រម Harmon ប្រកាសលាលែងពីដំណែង* ចុះថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០១៥ គេហទំព័រ https://www.eccc.gov.kh/km/node/33629។ ស.ច.ស.អ. *Harmon* បានលាលែងពីដំណែង ដោយមានសុពលភាពចាប់ពីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៥។ *សូមមើល* គេហទំព័រ អ.វ.ត.ក.៖ *ចៅក្រម Mark Brian Harmon* https://www.eccc.gov.kh/km/person/caukrm-maak-praayqin-haamun។

[80] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១០។ សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក.៖ *លោក Michael Bohlander ត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី* ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០១៥ https://www.eccc.gov.kh/km/articles/34050។ គេហទំព័រ អ.វ.ត.ក.៖ ចៅក្រម *Michael Bohlander* គេហទំព័រ https://www.eccc.gov.kh/km/person/caukrm-michael-bohlander-pmrung។

ចៅក្រមមុនឡើយ គាត់បានសិក្សាសំណុំរឿងនៅមុនពេលស៊ើបអង្កេត និង ប្រមូលភស្តុតាង[81] ដោយបានចេញសាជាថ្មីនូវសេចក្តីសម្រេចដែល ស.ច.ស.អ. Harmon បានចេញនាពេលមុន[82] ដោយបានលុបចោលបទចោទខ្លះរបស់ ស.ច.ស.អ. Harmon[83] ហើយបានដាក់លោក មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យអំពីបទឧក្រិដ្ឋមួយចំនួនបន្ថែមទៀត[84]។ ស.ច.ស.ជ. បានរង់ចាំ ស.ច.ស.អ. Bohlander ដោយអត់ធ្មត់ និង ស្ងៀមស្ងាត់ ឱ្យគាត់បញ្ចប់កិច្ចស៊ើបសួរ។ ក្នុងរយៈពេល ១៦ ខែ ក្រោយពេលគាត់មកដល់[85] ស.ច.ស.អ. Bohlander បានបញ្ចប់កិច្ចស៊ើបសួរ ពោលគឺរយៈពេល ៦ ឆ្នាំ បន្ទាប់ពី ស.ច.ស.ជ. និង ស.ច.ស.អ. Blunk បានបញ្ចប់កិច្ចស៊ើបសួររបស់ពួកគាត់[86]។

២០. ស.ច.ស.ជ. យូ ប៊ុនឡេង និង ស.ច.ស.អ. Bohlander បានសហការគ្នាតាំងពីដើមដល់ចប់ នៅក្នុងពេលដែលពួកគាត់បានបន្តបំពេញការងារ។ ជាក់ស្តែង ដោយមានការបារម្ភខ្លាំងអំពីវិបត្តិថវិកានៅ អ.វ.ត.ក. ដែលអាចបណ្តាលឱ្យ "ដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅលងបន្លាចជនត្រូវចោទដោយសារគ្រាន់តែការផ្អាកប្រតិបត្តិការនៃ អ.វ.ត.ក."[87] ស.ច.ស. បានព្យាករណ៍ថា នឹងផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ ពីព្រោះវាមិនប្រាកដថាតើកិច្ចដំណើរការនីតិវិធីនាពេលអនាគតអាចអនុវត្តតាមតម្រូវការនៃវិធានច្បាប់ឬយ៉ាងណា[88]។ ស.ច.ស. ក៏យល់ស្របចេញដីកាដំណោះ

---

[81] *សូមមើល ឧទា.* ការពន្យារពេលអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ឯកសារ D59 ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D59.13។ ការពន្យារពេលអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស D89 ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D89.11។

[82] សេចក្តីជូនដំណឹងពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅភាគីនានា ស្តីពីការចេញសាឡើងវិញនូវដីកាសម្រេចដែលចៅក្រម Harmon បានសម្រេចនៅថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៥ ឬ បន្ទាប់ពីកាលបរិច្ឆេទនេះ ចុះថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D149។ *សូមមើល ឧទា.* ដីកាសម្រេចចេញសាឡើងវិញលើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានស្ថានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D120/3។

[83] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D174 ទំព័រ ១០។

[84] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D174។

[85] សេចក្តីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំង មាស មុត ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១៧ ឯកសារ D225។

[86] សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ឯកសារ D13។

[87] សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និង ផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D249 កថាខណ្ឌ ៥៥។

[88] សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D249 កថាខណ្ឌ ១, ៥៥។

ស្រាយពីរដាច់ដោយឡែកពីគ្នា ក្នុងពេលតែមួយផងដែរ ដោយផ្អែកលើលទ្ធផលនៃការស៊ើបអង្កេតរបស់ពួកគាត់[89]។

**ខ. ដីកាដំណោះស្រាយ**

២១. នៅក្នុងដីកាដំណោះស្រាយនីមួយៗរបស់ពួកគាត់ ស.ច.ស. បានវាយតម្លៃ និង សម្រេចលើអង្គហេតុនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក មាស មុត[90] ដែលនាំឱ្យពួកគាត់ឈានទៅរកសេចក្តីសន្និដ្ឋានផ្ទុយគ្នា[91]។

២២. ស.ច.ស. ទាំងពីរបានឯកភាពគ្នាថា លោក មាស មុត *មិនមែន* ជាមេដឹកនាំជាន់ខ្ពស់[92]។ ពួកគេក៏បានឯកភាពគ្នាផងដែរថា ការសម្រេចថាតើ លោក មាស មុត ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ឬយ៉ាងណានោះ គឺជាអំណាចឆន្ទានុសិទ្ធិ[93]។ ការវាយតម្លៃរបស់ពួកគាត់ គឺផ្អែកលើវិធីសាស្ត្រភ័ស្តុតាងដូចគ្នា[94] ហើយនឹងកត្តាដែលពួកគាត់បានបង្កើតឡើងរួមគ្នា៖ **ក.** ចេតនារបស់ភាគីនៃកិច្ចព្រមព្រៀងកម្រិតយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ឱ្យនៅត្រឹមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ **ខ.** គោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* និង ការបកស្រាយតឹងរ៉ឹងលើច្បាប់ព្រហ្មទណ្ឌ **គ.** ការធ្វើសេចក្តីសម្រេចនៅក្នុងរចនាសម្ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ (ពោលគឺ កម្រិតដែលជនត្រូវចោទអាចចូលរួមចំណែក ឬ

---

[89] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៩ ដែលដកស្រង់ *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D262.2 កថាខណ្ឌ ១៤។

[90] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D120 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម")។ *សូមមើល* កថាខណ្ឌ ២៤, ២៨ *ខាងក្រោម*។ *សូមមើលផងដែរ* កថាខណ្ឌ ៥៤ *ខាងក្រោម*។

[91] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤០៨-២៩។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៥៦-៦៩។

[92] *សូមមើល* ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤០៥-០៦, ៤២៩។ *សូមមើលផងដែរ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៥៩។

[93] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៤, ៣៧៧។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៧ ដកស្រង់ ដីកាដំណោះស្រាយរឿងក្តី ០០៤/១ កថាខណ្ឌ ៩-១០។

[94] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៥៤-៥៩។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១១៨-៣១។ *សូមមើលផងដែរ* ដីកាដំណោះស្រាយរឿងក្តី ០០៤/១ កថាខណ្ឌ ១០៣-៣៩។

កំណត់គោលនយោបាយ ប.ក.ក. និង/ឬ ការអនុវត្តគោលនយោបាយទាំងនោះ) និង ឃ. ភាពធ្ងន់ធ្ងរនៃអំពើរបស់ជនត្រូវចោទ និង ផលប៉ះពាល់របស់វា ដោយផ្អែកតាមចេតនារបស់ភាគីនៃកិច្ចព្រមព្រៀង[95]។ ស.ច.ស. ទាំងពីរបានយល់ឃើញថា បុគ្គលនៅថ្នាក់ក្រោមៗអាចជាអ្នកទទួលខុសត្រូវខ្ពស់បំផុត អាស្រ័យទៅតាមការចូលរួមរបស់ពួកគេនៅក្នុងអំពើដ៏ឃោរឃៅទាំងនេះ ដោយតម្រូវឱ្យពួកគាត់មើលហួសពីសិទ្ធិអំណាចតាមឋានានុក្រមជាផ្លូវការ និង ដោយមានប្រសិទ្ធភាពរបស់លោក មាស មុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ពិចារណាលើកម្រិតនៃការចូលរួមរបស់គាត់នៅក្នុងការធ្វើគោលនយោបាយ ប.ក.ក. និង/ឬ ការអនុវត្តគោលនយោបាយទាំងនោះ[96]។

២៣. ស.ច.ស.ជ. បានរកឃើញថា លោក មាស មុត មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ពីព្រោះថា បើទោះបីជាគាត់មានតួនាទីមួយចំនួនក៏ដោយ ក៏គាត់ "មិនមានអំណាចច្រើន" ហើយ "ការចូលរួមរបស់គាត់មិនសកម្ម មិនដុំកំភួន និង មិនបានកៀកកិតនឹងការប្រព្រឹត្តបទឧក្រិដ្ឋ" នោះទេ[97]។ គាត់បានសម្រេចលើកលែងការចោទប្រកាន់ក្នុងរឿងក្តីនេះ[98]។ ស.ច.ស.អ. បានរកឃើញថា លោក មាស មុត គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ពីព្រោះថា ការបញ្ចូលគ្នានូវឋានៈ និង វិសាលភាពនៃសិទ្ធិអំណាចរបស់គាត់ នៅក្នុងឋានានុក្រមរបបកម្ពុជាប្រជាធិបតេយ្យ និង ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងគាត់[99] "កំណត់ថា គាត់ជាអ្នកដើរតួចម្បងនៅក្នុងរចនាសម្ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ និង ជាអ្នកចូលរួមប្រកបដោយឆន្ទៈស្រួចស្រាល់ ចំពោះការអនុវត្តយ៉ាងឃោរឃៅ នូវគោលនយោបាយឧក្រិដ្ឋ និង អមនុស្សធម៌របស់របបកម្ពុជាប្រជាធិបតេយ្យ"[100]។ គាត់បានសម្រេចបញ្ជូនលោក មាស មុត ទៅជំនុំជម្រះពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មថ្នាក់ជាតិ[101]។

---

[95] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦០-៤០៧។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣២-៣៩។ *សូមមើលផងដែរ* ដីកាដំណោះស្រាយរឿងក្តី ០០៤/១ កថាខណ្ឌ ៣-៤១។

[96] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៨-៦៩។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៩ ដែលដកស្រង់ ដីកាដំណោះស្រាយរឿងក្តី ០០៤/១ កថាខណ្ឌ ៣៨-៣៩។

[97] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៨។

[98] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៣០។

[99] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៦០។

[100] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៦៩។

[101] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ២៥៦-៦៤។

### ១. ដីកាសម្រេចលើកលែងចោទប្រកាន់

២៤. ស.ច.ស.ជ. បានវាយតម្លៃលើអង្គហេតុដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរបន្ថែមទាក់ទងនឹងលោក មាស មុត[102]។ គាត់បានរកឃើញថា៖

ក. *មន្ទីរសន្តិសុខ ស-២១*[103] មន្ទីរសន្តិសុខ ស-២១ "ស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់គណៈកម្មាធិការមជ្ឈិម"[104]។ ទោះបីជាបានទទួលព័ត៌មានទាក់ទងនឹងការចាប់ខ្លួនក៏ដោយ[105] ក៏លោក មាស មុត មិនមានលទ្ធភាពធ្វើសេចក្ដីសម្រេចចាប់ខ្លួន ដោយខ្លួនគាត់ផ្ទាល់ដែរ[106] ហើយគាត់ក៏មិនពាក់ព័ន្ធនឹងការផ្ទេរកម្មាភិបាល នៅកងពលធំលេខ ១៦៤ ទៅកាន់មន្ទីរសន្តិសុខ ស-២១ នោះដែរ[107]។ គ្មានឯកសារណាមួយបង្ហាញអំពីការធ្វើទំនាក់ទំនងផ្ទាល់រវាងលោក មាស មុត និង ឌុច អតីតប្រធានមន្ទីរសន្តិសុខ ស-២១ នោះឡើយ[108]។

ខ. *មន្ទីរសន្តិសុខវត្តឥន្ទញាណ*[109] ខណៈដែលមន្ទីរសន្តិសុខវត្តឥន្ទញាណអាចស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងវរសេនាតូចនៃកងពលធំលេខ ១៦៤[110] គ្មានឯកសារណាមួយ

---

[102] *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ស្នើសុំ ក.ស.ច.ស. ឱ្យទទួលពិនិត្យអង្គហេតុនានាទាក់ទងនឹងដំណែង និងតួនាទីរបស់លោក មាស មុត នៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ (កថាខណ្ឌ ៨១-៨៦) មន្ទីរសន្តិសុខ ស-២១ (កថាខណ្ឌ ៤៣) មន្ទីរសន្តិសុខវត្តឥន្ទញាណ (កថាខណ្ឌ ៥៥-៥៧) ការដ្ឋានវាយថ្មស្ទឹងហាវ (កថាខណ្ឌ ៥៨) ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ (កថាខណ្ឌ៥៩-៦១) ការបោសសម្អាតកងពល ក.ប.ក. (កថាខណ្ឌ ៥២-៥៤) និង ជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម (កថាខណ្ឌ ៦២)។ *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ២០-២៤ ស្នើសុំ ក.ស.ច.ស. ឱ្យទទួលពិនិត្យអង្គហេតុបន្ថែមទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

[103] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៦៣-៨៧។

[104] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៦៧។

[105] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៨៥-៨៦។

[106] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៨៣។

[107] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៨០។

[108] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៨២។

[109] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៨៨-៩៧។

[110] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩៧។

បង្ហាញអំពីវត្តមានរបស់លោក មាស មុត នៅក្នុងការចាប់ខ្លួន ឬ ការត្រួតពិនិត្យនៅទីតាំងនោះជាទៀងទាត់ឡើយ[111]។

គ. *ការដ្ឋានវាយថ្មស្ទឹងហាវ*[112] ខណៈដែលការដ្ឋានវាយថ្មស្ទឹងហាវស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងវរសេនាតូចនៃកងពលធំលេខ ១៦៤[113] លោក មាស មុត បានគ្រាន់តែរាយការណ៍ និង ទទួលបញ្ជាពី សុន សេន ប៉ុណ្ណោះ នៅមុនពេលបញ្ជូនបញ្ជាទាំងនោះបន្តទៅឱ្យកងវរសេនាតូច[114]។ គ្មានភ័ស្តុតាងបង្ហាញថា លោក មាស មុត បានចុះត្រួតពិនិត្យទីតាំងនេះទេ[115]។

ឃ. *ឧក្រិដ្ឋកម្មប្រព្រឹត្តដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ នៅក្នុងដែនទឹក និង ដែនកោះកម្ពុជា*[116] គណៈកម្មាធិការអចិន្ត្រៃយ៍បានធ្វើសេចក្តីសម្រេចចាប់ខ្លួន និង សម្លាប់អ្នកនេសាទ ដែលត្រូវបានបញ្ជូនទៅឱ្យមេបញ្ជាការកងពលធំតាមរយៈ សុន សេន[117]។ ខណៈដែលមានការរាយការណ៍អំពីការចាប់ខ្លួនអ្នកនេសាទថៃ និង វៀតណាមនៅក្នុងដែនទឹកកម្ពុជាទៅលោក មាស មុត[118] ដែលបន្ទាប់មករាយការណ៍បន្តទៅ សុន សេន[119] លោក មាស មុត គ្មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចដោយឯករាជ្យទាក់ទងនឹងការចាប់ខ្លួន និងការកាប់សម្លាប់អ្នកនេសាទនោះឡើយ[120]។

ង. *ការបោសសម្អាតកងពលនៃកងទ័ពបដិវត្តន៍កម្ពុជា ("ក.ប.ក.")*[121] ខណៈដែលលោក មាស មុត បានចូលរួមកិច្ចប្រជុំទាក់ទងនឹងផែនការបោសសម្អាតកងពល ក.ប.ក.[122]

---

[111] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩៧។

[112] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩៨-៣០៥។

[113] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៥។

[114] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៥។

[115] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៥។

[116] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៦-២២។

[117] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២១-២២។

[118] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៨, ៣២០, ៣២២។

[119] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣១៣-១៤, ៣១៦, ៣២១-២២។

[120] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២១។

[121] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២២៩-៥៨។

ហើយ សុន សេន បានបញ្ជាគាត់ឱ្យចាត់វិធានការ ដូចជា ការអប់រំ ការបោសសម្អាត និង ការដកអង្គភាព ក.ប.ក.[123] លោក មាស មុត មិនបានសម្លាប់ទាហាននោះទេ ផ្ទុយទៅវិញ គាត់បានបញ្ជូនពួកគេទៅកាន់កងផលិតដើម្បីធ្វើស្រែ និង រកត្រី[124]។

ច. *ជម្លោះជាមួយប្រទេសវៀតណាម*[125] កិច្ចប្រជុំថ្នាក់មេបញ្ជាការបានធ្វើឡើងនៅផ្ទះរបស់ តាម៉ុក នៅក្នុងឆ្នាំ ១៩៧៧ ដើម្បីប្រមូលកងទ័ព ដែលនៅទីនោះ សុន សេន និង តាម៉ុក "បានពន្យល់ពីផែនការវាយប្រហារប្រទេសវៀតណាម"[126]។ ទោះបីជាយ៉ាងនេះក្តី ឈូក រិន ដែលបានចូលរួមការប្រជុំនោះ បានផ្តល់សក្ខីកម្មថា គាត់មិនដែលធ្លាប់បានជួប លោក មាស មុត នោះទេ[127]។

ឆ. *មន្ទីរសន្តិសុខ ក.ប.ក. និង ទីតាំងកាប់សម្លាប់ផ្សេងទៀត*[128] គ្មានភស្តុតាងបង្ហាញអំពីតួនាទី និង ការចូលរួមរបស់លោក មាស មុត នៅក្នុងឧក្រិដ្ឋកម្មនៅទីតាំងទាំងនេះទេ[129]។

ជ. *ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ*[130] ប.ក.ក. បានអនុវត្តគោលនយោបាយរៀបការដោយបង្ខំ[131] ដែលត្រូវបានរាយការណ៍តាមសារទូរលេខ បញ្ជូនទៅថ្នាក់លើ[132]។

២៥. ស.ច.ស.ជ. បានរកឃើញថា ទោះបីជាមានតួនាទីមួយចំនួនក៏ដោយ ក៏លោក មាស មុត "មិនមានអំណាចច្រើន" ដែរ[133]។ គាត់បានរកឃើញថា លោក មាស មុត មិនមែនជាសមាជិកគណៈ កម្មា

---

[122] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៥៦។
[123] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៥៨។
[124] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៥៨។
[125] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២៣-២៩។
[126] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២៧។
[127] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២៧។
[128] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៥២-៥៣។
[129] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៥២។
[130] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨២, ៩២-៩៣។
[131] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨២, ៩២។
[132] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៩៣។
[133] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៨។

ធិការអចិន្ត្រៃយ៍[134] ដែលជាស្ថាប័នមានសិទ្ធិអំណាចខ្ពស់បំផុត ក្នុងការធ្វើសេចក្តីសម្រេចលើគោលនយោបាយទាំងអស់របស់ ប.ក.ក. នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[135] ហើយក៏មិនមែនជាសមាជិកគណៈកម្មាធិការយោធានោះដែរ[136]។ ស.ច.ស.ជ. មិនបានជឿជាក់ថា លោក មាស មុត គឺជាសមាជិកនៃគណៈកម្មាធិការអគ្គសេនាធិការនោះទេ[137] និង បានផ្តល់ហេតុផលថា ប្រសិនបើគាត់ជាសមាជិកគណៈកម្មាធិការនេះ នៅក្នុងខែវិច្ឆិកា ឆ្នាំ ១៩៧៨ មែននោះ មុខដំណែងរបស់គាត់នេះ មានរយៈពេលតែមួយខែប៉ុណ្ណោះ នៅមុនពេលដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ[138]។ ផ្ទុយមកវិញ គាត់បានរកឃើញថា លោក មាស មុត គឺជាសមាជិកនៃគណៈកម្មាធិការជំនួយរបស់គណៈកម្មាធិការមជ្ឈិម[139] ដែលជាថ្នាក់ទាបជាងគេបំផុតនៃគណៈកម្មាធិការមជ្ឈិម[140] ដែលគ្មានសិទ្ធិចូលរួម ឬ សិទ្ធិបោះឆ្នោតនៅក្នុងការធ្វើសេចក្តីសម្រេចឡើយ[141]។ គាត់បានរកឃើញថា លោក មាស មុត បានបញ្ជាដឹកនាំកងពលធំលេខ ១៦៤ ហើយទទួលខុសត្រូវតែចំពោះប្រតិបត្តិការកងទ័ពជើងទឹកនៅតាមឆ្នេរ និង កោះនៃខេត្តកំពង់សោមប៉ុណ្ណោះ[142]។ គាត់ក៏បានរកឃើញផងដែរថា លោក មាស មុត "ស្ថិតនៅក្រោមកម្មាភិបាលប្រហែលចំនួន ៥០ (ហាសិប) នាក់ និង មានឋានៈស្មើកម្មាភិបាលជាច្រើននាក់ទៀត រាប់បញ្ចូលទាំងលេខាភូមិភាគ និង លេខាកងពលធំ"[143] ដែលបានអនុវត្តតាមគោលនយោបាយ ប.ក.ក. ដូចគ្នា[144]។

---

[134] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៧៩, ៤១៨។

[135] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៧៩, ១១០, ៤១០។

[136] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៥៣។

[137] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៦៣។

[138] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៦៣។

[139] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១១១, ១១៧, ១២១។

[140] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១១០។

[141] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១៨។

[142] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៨៧-៨៨, ៤១៦។ ស.ច.ស.ជ. បានយល់ឃើញថា សក្ខីកម្មរបស់ "សាក្សីសំខាន់ៗបានបង្ហាញថា កងពលធំលេខ ១ នៃភូមិភាគបស្ចិម ទទួលការងារដែនទឹកសមុទ្រ នៅក្នុងភូមិសាស្ត្រខេត្តកោះកុង"។ *សូមមើល ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២១៩, ៤១៦។

[143] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១៩។

[144] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២០។.

២៦. ស.ច.ស.ជ. បានរកឃើញថា ខណៈដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងនៅក្នុងតំបន់ក្រោមសិទ្ធិអំណាចរបស់ លោក មាស មុត[145] "ការចូលរួមរបស់គាត់ មិនសកម្ម មិនដុំកំភួន និង មិនបានកៀកកិតនឹងការប្រព្រឹត្តបទឧក្រិដ្ឋ" នោះឡើយ[146]។ គាត់បានផ្តល់ហេតុផលថា គណៈកម្មាធិការមជ្ឈិមពោលគឺ "ប៉ុល ពត និង នួន ជា តាមយោបល់របស់ សុន សេន និង មានការសហការពីមេដឹកនាំស្ថាប័ន"[147] បានធ្វើសេចក្តីសម្រេចចាប់ខ្លួន និង ផ្ទេរមនុស្សទៅកាន់មន្ទីរសន្តិសុខ ស-២១[148]។ គាត់បានរកឃើញថា នៅក្រោមសិទ្ធិអំណាចរបស់អគ្គសេនាធិការ និង គណៈកម្មាធិការយោធា[149] លោក មាស មុត បានចូលរួមនៅក្នុងការគាំទ្រ[150] និង ការផ្សព្វផ្សាយគោលនយោបាយ ប.ក.ក.[151] អនុវត្តតាមបញ្ជារបស់ថ្នាក់លើ ដើម្បីសម្រួលដល់ការចាប់ខ្លួន និង ការផ្ទេរអ្នកទោស[152]។ ខណៈដែល ស.ច.ស.ជ. បានរកឃើញថា ឯកសារនៅរបបកម្ពុជាប្រជាធិបតេយ្យចំនួន ២៨៦ បង្ហាញអំពីការឆ្លើយឆ្លងរបស់លោក មាស មុត ជាមួយ សុន សេន[153] គាត់បានរកឃើញថា គ្មានឯកសារណាមួយបង្ហាញអំពីគំនិតផ្តួចផ្តើមរបស់លោក មាស មុត ក្នុងការបញ្ជាឱ្យចាប់ខ្លួន ឬ ការកាប់សម្លាប់ឡើយ[154]។ គាត់មិនមែនជាបុគ្គលមួយរូបក្នុងចំណោមបុគ្គល ១៣ រូប ដែលមានសិទ្ធិ

---

[145] *សូមមើល ឧទា.* ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩៥-៩៧ (មន្ទីរសន្តិសុខវត្តឥន្ទញាណ) កថាខណ្ឌ ៣០៣-០៥ (ការដ្ឋានវាយថ្មស្ទឹងហាវ) កថាខណ្ឌ ៣០៧-២២ (ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យនៅក្នុងដែនទឹក និង កោះរបស់កម្ពុជា)។

[146] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៨។

[147] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៥។

[148] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៥។ *សូមមើលផងដែរ ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២៦៧ ដែលរកឃើញថា មន្ទីរសន្តិសុខ ស-២១ "ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់គណៈកម្មាធិការមជ្ឈិម"។

[149] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១៧។ *សូមមើលផងដែរ ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៥៣, ១៥៩ ទាក់ទងនឹងសមាសភាពគណៈកម្មាធិការយោធា និង សេនាធិការ។

[150] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២២។

[151] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១៦។

[152] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២០, ៤២២, ៤២៥។

[153] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៣។

[154] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២២០-២៥, ៤២៥-២៦។

អំណាចបែបនេះ ដូចជា ប៉ុល ពត នួន ជា សោ ភឹម តាម៉ុក វន វ៉េត សុន សេន ខៀវ សំផន កុយ ធួន មាស សាន រស់ ញឹម កែ ពក ជូ ចេត និង កង ចាប នោះទេ[155]។

២៧. ស.ច.ស.ជ. បានប្រៀបធៀបលោក មាស មុត ជាមួយ ឌុច ដែលគាត់បានរកឃើញថា ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត[156]។ ផ្ទុយពីការរកឃើញរបស់គាត់អំពីតួនាទី និង មុខដំណែងរបស់លោក មាស មុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[157] ស.ច.ស.ជ. បានរកឃើញថា ឌុច បានស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់គណៈកម្មាធិការអចិន្ត្រៃយ៍ និង បានអនុវត្ត "ការគ្រប់គ្រងដ៏មានឥទ្ធិពល និង មានប្រសិទ្ធភាព" ក្នុងនាមជាប្រធាន ស-២១[158] ដែលជាមន្ទីរសន្តិសុខធ្វើប្រតិបត្តិការនៅទូទាំងប្រទេស[159] ហើយនឹងមាន "អំណាចជម្រុញឱ្យមានការស្លាប់ និង សម្លាប់ដោយផ្ទាល់"[160]។ ផ្ទុយពីការរកឃើញរបស់គាត់លើការចូលរួមរបស់លោក មាស មុត នៅក្នុងឧក្រិដ្ឋកម្ម និង ការធ្វើសេចក្ដីសម្រេចផ្នែកគោលនយោបាយរបស់ ប.ក.ក. និង/ឬ ការអនុវត្ត[161] ស.ច.ស.ជ. បានរកឃើញថា ឌុច "បានអនុវត្តដោយផ្ទាល់ ដោយមានប្រសិទ្ធភាព និង ដោយពេញលេញនូវ" បញ្ជារបស់ថ្នាក់លើនៅមន្ទីរសន្តិសុខ ស-២១[162] បានជួយសម្រួលដល់ការចាប់ខ្លួន ការរៀបចំ ការណែនាំ និង ការតាមដានការសួរចម្លើយ និង ការកាប់សម្លាប់អ្នកទោស[163] ដែលត្រូវបានបញ្ជូនពី "ស្ទើរតែគ្រប់ទីកន្លែងនៅទូទាំងប្រទេស"[164]។ ស.ច.ស.ជ. ក៏បានរកឃើញផងដែរថា ចំនួនជនរង

---

[155] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៦៩, ៤១៨។ *សូមមើលផងដែរ ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១២២។

[156] *រឿងក្ដី កាំង ហ្គេកអ៊ាវ* លេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយបញ្ជូន កាំង ហ្គេកអ៊ាវ ហៅ ឌុច ទៅជំនុំជម្រះ ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D99 កថាខណ្ឌ ១២៩។

[157] *សូមមើលខាងលើ* កថាខណ្ឌ ២៥។

[158] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៧១។

[159] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៧២។

[160] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៧៥។

[161] *សូមមើលខាងលើ* កថាខណ្ឌ ២៦។

[162] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៧៤។

[163] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៧១-៧៤។

[164] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៧២។

គ្រោះដែលទទួលរងគ្រោះដោយសារអំពើដោយផ្ទាល់របស់លោក មាស មុត "មានភាពខុសគ្នាឆ្ងាយណាស់" ពីអ្នកដែលបានទទួលរងគ្រោះដោយសារអំពើផ្ទាល់របស់ ឌុច[165]។

## ២. ដីកាបញ្ជូនរឿងទៅជំនុំជម្រះ

២៨. ស.ច.ស.អ. បានវាយតម្លៃលើអង្គហេតុដែលបានចោទប្រកាន់ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងនឹងលោក មាស មុត[166]។ គាត់បានរកឃើញថា លោក មាស មុត ស្ថិតនៅក្នុងសហឧក្រិដ្ឋកម្មរួម ជាមួយ សុន សេន តាម៉ុក ស៊ូ ម៉េត និង បុគ្គលិកជាន់ខ្ពស់ផ្សេងទៀតនៃ ក.ប.ក. ដោយមានគោលបំណងរួមក្នុងការអនុវត្តគោលនយោបាយ ប.ក.ក. ចំនួនបួន៖ **ក.** បង្កើតសហករណ៍ និង ការដ្ឋានពលកម្មដោយបង្ខំ **ខ.** អប់រំ "សមាសធាតុមិនល្អ" និង សម្លាប់ "ខ្មាំង" នៅក្នុងជួរ និង ក្រៅជួរ ក.ប.ក. **គ.** កំណត់គោលដៅក្រុមជាក់លាក់ (វៀតណាម ថៃ បុគ្គលិកយោធា និង ជនស៊ីវិល) និង **ឃ.** អនុវត្តគោលនយោបាយរៀបការដោយបង្ខំរបស់ ប.ក.ក.[167]។

---

[165] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៨។

[166] *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ស្នើសុំ ក.ស.ច.ស. ឱ្យទទួលពិនិត្យអង្គហេតុនានាទាក់ទងនឹងដំណែង និងតួនាទីរបស់លោក មាស មុត នៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ (កថាខណ្ឌ ៨១-៨៦) មន្ទីរសន្តិសុខ ស-២១ (កថាខណ្ឌ ៤៣) មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ (កថាខណ្ឌ ៥៥-៥៧) ការដ្ឋានវាយថ្មស្ទឹងហាវ (កថាខណ្ឌ ៥៨) ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ (កថាខណ្ឌ ៥៩-៦១) ការបោសសម្អាតកងពលធំ ក.ប.ក. (កថាខណ្ឌ ៥២-៥៤) និង ជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម (កថាខណ្ឌ ៦២)។ *សូមមើលផងដែរ* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ២០-២៤ ស្នើសុំ ក.ស.ច.ស. ឱ្យទទួលពិនិត្យអង្គហេតុបន្ថែមទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ស.ច.ស.អ. បានលុបចោលជាផ្លូវនូវការស៊ើបអង្កេតលើអង្គហេតុ ដែលគាត់បានដកចេញនៅក្នុងដីកាសម្រេចកាត់បន្ថយវិសាលភាពនៃការស៊ើបសួរពាក់ព័ន្ធនឹងការចោទប្រកាន់ទាំងអស់ទាក់ទងនឹង៖ **ក.** មន្ទីរសន្តិសុខ ស-២២ **ខ.** ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង **គ.** ទីកន្លែងសម្លាប់មនុស្សស្ទឹងតូច **ឃ.** ការចូលរួមរបស់ ក.ប.ក. នៅក្នុងការបោសសម្អាតភូមិភាគកណ្ដាល ភូមិភាគឧត្តរថ្មី និង ភូមិភាគបូព៌ា ដោយមិនរាប់បញ្ចូលការចោទប្រកាន់អំពីការបោសសម្អាតសមាជិកនៅកង/អង្គភាពរបស់ ក.ប.ក. ដែលមានទីតាំងនៅក្នុងតំបន់ទាំងនោះ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១២-១៣។ ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១៧ ឯកសារ D226 កថាខណ្ឌ ៤, ១៣។

[167] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៧១។

២៩. ស.ច.ស.អ. បានរកឃើញថា លោក មាស មុត បានឡើងកាន់កាប់តួនាទី "ដោយបំពេញកិច្ចការក្នុងកម្រិតខ្ពស់ នៅក្នុងរចនាសម្ព័ន្ធបញ្ជាការកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលស្ថិតនៅក្រោមការដឹកនាំរបស់អ្នកនយោបាយថ្នាក់ជាតិ"[168]។ គាត់បានយល់ឃើញថា ខណៈដែលលោក មាស មុត មិនមែនជាមេដឹកនាំជាន់ខ្ពស់ម្នាក់ គាត់នៅកៀកនឹងថ្នាក់ដឹកនាំជាន់ខ្ពស់ ប.ក.ក. ដោយផ្តល់សំអាងហេតុថា លោក មាស មុត បានបញ្ជាកងពលធំលេខ ១៦៤ បានទទួលខុសត្រូវលើដែនទឹកនៃរបបកម្ពុជាប្រជាធិបតេយ្យ ធ្លាប់ជាសមាជិករង់ត្រៀមនៃគណៈកម្មាធិការអគ្គសេនាធិការ និង ជាអនុប្រធានរបស់ សុន សេន ហើយ ចាប់ពីចុងឆ្នាំ ១៩៧៨ ជាសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិម[169]។ ក្រៅពីរកឃើញថា លោក មាស មុត បានប្រើប្រាស់អំណាចជាមេបញ្ជាការកងពលធំ[170] និង បានគ្រប់គ្រងសកម្មភាពជនស៊ីវិលនៅកំពង់សោម[171] ស.ច.ស.អ. មិនបានរកឃើញពីសិទ្ធិអំណាចប្រកបដោយប្រសិទ្ធភាពរបស់គាត់ នៅក្នុងមុខនាទីផ្សេងទៀតដែលចោទប្រកាន់លើរូបគាត់នោះទេ។

៣០. ស.ច.ស.អ. បានរកឃើញថា បទចោទនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម និង ការសម្លាប់រង្គាលលើជនជាតិថៃ ដែលចាប់ខ្លួនបានដោយកងទ័ពជើងទឹកនៃរបបកម្ពុជាប្រជាធិបតេយ្យ "ដាក់ឱ្យ [លោក មាស មុត] ស្ថិតនៃយុត្តាធិការបុគ្គលយ៉ាងរឹងមាំ"[172] ដោយបានរកឃើញថា គាត់បានចេញបញ្ជាដែលគ្មានដែនកំណត់ ឱ្យសម្លាប់អ្នកដែលបានចូលដែនទឹកនៃរបបកម្ពុជាប្រជាធិបតេយ្យ[173]។ គាត់ក៏យល់ឃើញផងដែរថា លោក មាស មុត ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មផ្សេងទៀតនៅក្រោមច្បាប់ជាតិ[174]។ ខណៈដែល ស.ច.ស.អ. បានរកឃើញថា លោក មាស មុត បានអនុវត្តគោលនយោបាយ ប.ក.ក.

---

[168] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៦១។

[169] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៥៩។

[170] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៥៦។

[171] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៥៩។

[172] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៦៣។

[173] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៦៤។

[174] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៦៦។

នៅក្នុងតំបន់ក្រោមសិទ្ធិអំណាចរបស់គាត់[175] គាត់មិនបានរកឃើញថា លោក មាស មុត មានតួនាទីណាមួយនៅក្នុងការបង្កើតគោលនយោបាយទាំងនេះ ឬ មានឆន្ទានុសិទ្ធិក្នុងការកំណត់ការអនុវត្តគោលនយោបាយទាំងនេះឡើយ។

៣១. ស.ច.ស.អ. បានប្រៀបធៀប លោក មាស មុត ទៅនឹងជនត្រូវចោទផ្សេងទៀត។ គាត់បានរកឃើញថា លោក មាស មុត បានបំពេញភារកិច្ចនៅកម្រិតខ្ពស់ជាង អោ អាន ដែលគាត់ក៏បានរកឃើញផងដែរថា ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត[176] ហើយថា មុខនាទីរបស់លោក មាស មុត រួមជាមួយនឹងលក្ខណៈ និង ផលប៉ះពាល់នៃអំពើរបស់គាត់ មានអានុភាពខ្លាំងជាង អោ អាន អ៊ឹម ចែម និង ឌុច[177] "កំណត់ថា គាត់ជាអ្នកដើរតួចម្បងនៅក្នុងរបបនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ និង ជាអ្នកចូលរួមប្រកបដោយឆន្ទៈស្រួចស្រាល់ ចំពោះការអនុវត្តយ៉ាងឃោរឃៅ នូវគោលនយោបាយឧក្រិដ្ឋ និង អមនុស្សធម៌របស់កម្ពុជាប្រជាធិបតេយ្យ"[178]។

## IV. ច្បាប់ និង ឧទ្ធរណ៍

**ក. ស.ច.ស.អ. មានកំហុសអង្គច្បាប់ដោយបានបកស្រាយវិធាន ៧៧(១៣) នៅក្នុងរបៀបមួយដែលស្នើថា ដីកាដំណោះស្រាយទាំងពីរ ឬ មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ប៉ុណ្ណោះដែលមានអានុភាពអនុវត្ត ប្រសិនបើ អ.ប.ជ. មិនអាចសម្រេចតម្កល់ដីកាដំណោះស្រាយណាមួយក្នុងចំណោមដីកាដំណោះស្រាយទាំងពីរនេះ តាមសំឡេងភាគច្រើនលើសលប់**

៣២. អនុលោមតាមវិធាន ៧៧(១៣) សេចក្តីសម្រេចរបស់ អ.ប.ជ. លើបណ្តឹងឧទ្ធរណ៍តម្រូវឱ្យមានសំឡេងភាគច្រើនលើសលប់ពីចៅក្រមចំនួន ៤ រូប ក្នុងចំណោមចៅក្រមចំនួន ៥ រូប។ ប្រសិនបើ អ.ប.ជ. មិនអាចរកសំឡេងភាគច្រើនលើសលប់បានទេ វិធាន ៧៧(១៣) ចែងអំពី "សេចក្តី

[175] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៨០ (ការបង្កើតការដ្ឋាន និង សហករណ៍) កថាខណ្ឌ ១៨៨ (ការបោសសម្អាត ក.ប.ក. នូវ "សមាសភាពមិនល្អ") កថាខណ្ឌ ១៩២, ១៩៥, ១៩៨-៩៩, ២៧៣, ២៧៩, ២៨២, ២៨៤-៨៦, ៣២៧ (ការដាក់គោលដៅលើក្រុមជាក់លាក់) កថាខណ្ឌ ២០៥ (អាពាហ៍ពិពាហ៍ដោយបង្ខំ)។ *សូមមើលផងដែរ ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៣០៣, ៣១៥ (ដែលរកឃើញថា លោក មាស មុត មិនបានចូលរួមផ្ទាល់នៅក្នុងការបោសសម្អាតកងពលធំ ៥០២ និង ៣១០ នោះទេ)។

[176] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៦១។

[177] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៦០។

[178] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៦៩។

សម្រេចដែលមិនមានសំឡេងគាំទ្រ” ទាំងពីរ៖ អនុលោមតាមវិធាន ៧៧(១៣)(ក) “ដីកា ឬ កិច្ចស៊ើបសួរដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកា ឬ កិច្ចស៊ើបសួរនោះ ត្រូវតម្កល់ទុកជាបានការ”។ អនុលោមតាមវិធាន ៧៧(១៣)(ខ) អ.ជ.ត.ក. ទទួលបានរឿងក្តី “ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់ [ស.ច.ស.]”។ នៅពេលផ្តល់ការយល់ឃើញលើចំណុចបណ្តឹងឧទ្ធរណ៍ដែលមិនស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន ស.ច.ស.អ. បានស្នើថា ដីកាដំណោះស្រាយទាំងពីរ ឬ មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ប៉ុណ្ណោះដែលមានអានុភាពអនុវត្ត លើកលែងតែ អ.ប.ជ. សម្រេចតម្កល់ដីកាដំណោះស្រាយណាមួយ តាមសំឡេងភាគច្រើនលើសលប់អនុលោមតាមវិធាន ៧៧(១៣) ។ នៅក្នុងប្រវត្តិនីតិវិធីនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួន ស.ច.ស.អ. បានដាក់បញ្ចូលការយល់ឃើញរបស់ ស.ច.ស. ដែលថា ដីកាដំណោះស្រាយទាំងពីរ “អាចទំនងជាមានអានុភាពអនុវត្ត” អនុលោមតាមវិធាន ៧៧(១៣) ដោយដកស្រង់សេចក្តីសម្រេចដែលពួកគាត់បានជូនដំណឹងដល់ភាគី អំពីផលវិបាកដែលអាចកើតចេញពីការចេញដីកាដំណោះស្រាយផ្ទុយគ្នា[179]។ ផ្ទុយមកវិញ នៅក្នុងផ្នែកនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះទាក់ទងនឹងការឃុំខ្លួនមុនអង្គសេចក្តី ស.ច.ស.អ. បានយល់ឃើញថា វា “មិនច្បាស់លាស់” ថាតើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួននឹងមានអានុភាពអនុវត្តអនុលោមតាមវិធាន ៧៧(១៣) ឬយ៉ាងណា[180]។ ស.ច.ស.អ. បានបកស្រាយមិនត្រឹមត្រូវនូវវិធាន ៧៧(១៣)។ វិធាន ៧៧(១៣) មិនអនុវត្តចំពោះដីកាដំណោះស្រាយផ្ទុយគ្នានោះទេ ពីព្រោះ៖ **ក.** ភាគីនៃកិច្ចព្រមព្រៀងមិនមានចេតនាឱ្យរឿងក្តីត្រូវបានបញ្ជូនទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលដែលដីកាសម្រេចលើកលែងចោទប្រកាន់ ត្រូវបានចេញក្នុងពេលដំណាលគ្នា និង **ខ.** ការអនុវត្តវិធាន ៧៧(១៣) ចំពោះបណ្តឹងឧទ្ធរណ៍នៃដីកាដំណោះស្រាយផ្ទុយគ្នា នឹងនាំទៅរកលទ្ធផលដែលមិនសមហេតុផល បង្កពន្យសនកម្មដែលមិនអាចកែតម្រូវបាន ដល់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក មាស មុត និង រំលោភរដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខ័ណ្ឌ អ.វ.ត.ក.។

---

[179] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៩ ជើងទំព័រ ២៦ ដែលដកស្រង់ *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការថ្លែងយោបល់ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D262.2 កថាខណ្ឌ ១៦។

[180] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៥៧៩។

**១. ភាគីនៃកិច្ចព្រមព្រៀង មិនមានចេតនាឱ្យរឿងក្តីបន្តទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ នៅពេលដីកាលើកលែងការចោទប្រកាន់ត្រូវបានចេញក្នុងពេលដំណាលគ្នានោះ**

៣៣. នៅក្នុងអំឡុងពេលនៃការចរចាដែលមានការអូសបន្លាយមុនពេលបង្កើត អ.វ.ត.ក.[181] ភាគីនៃកិច្ចព្រមព្រៀង ពោលគឺ រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប. បានប្រមើលមើលឃើញថា ស.ច.ស. អាចខ្វែងយោបល់គ្នាដោយសមហេតុផល ទៅលើដំណើរការស៊ើបអង្កេត រួមទាំង វិសាលភាពនៃយុត្តាធិការបុគ្គល[182]។ នៅពេលពិនិត្យមើលសេចក្តីព្រាងច្បាប់កម្ពុជាស្តីពីការបង្កើត "សាលាជម្រះក្តីពិសេស" សម្រាប់កាត់ទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានដាក់ជូន អ.ស.ប. នៅក្នុងខែមករា ឆ្នាំ ២០០០ អគ្គលេខាធិការ អ.ស.ប. Kofi Annan បានបង្ហាញសេចក្តីបារម្ភថា "ស្ថាប័នបច្ចុប្បន្នរបស់ ... សហចៅក្រមស៊ើបអង្កេត ដែលគ្មានចៅក្រមណាមួយអាចបន្តនីតិវិធីបាននោះទេ ប្រសិនបើគ្មានការព្រមព្រៀងពីចៅក្រមម្នាក់ទៀត នឹងនាំឱ្យមានការលំបាកក្នុងការប្រតិបត្តិការ ហើយទំនងជានាំឱ្យមានការជាប់គាំង"[183]។ ក្រោយ

---

[181] ការចរចាដែលនាំឱ្យបង្កើត អ.វ.ត.ក. បានចាប់ផ្តើមនៅខែមិថុនា ឆ្នាំ ១៩៩៦ នៅពេលដែលលោក Thomas Hammarberg តំណាងពិសេសរបស់អគ្គលេខាធិការ អ.ស.ប. ទទួលបន្ទុកសិទ្ធិមនុស្សនៅប្រទេសកម្ពុជា បានចុះបេសកកម្មលើកដំបូងរបស់គាត់មកប្រទេសកម្ពុជា។ *សូមមើល* Thomas Hammarberg *បទយកការណ៍ពិសេស៖ កិច្ចខិតខំប្រឹងប្រែងបង្កើតសាលាក្តីប្រឆាំងមេដឹកនាំខ្មែរក្រហម* (Special instert: Efforts to establish a tribunal against KR leaders សារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០១ *មាននៅលើគេហទំព័រ* http://www.phnompenhpost.com/national/special-insert-efforts-establish-tribunal-against-kr-leaders។

[182] *សូមមើល* លិខិតពីអគ្គលេខាធិការ អ.ស.ប. Kofi Annan ផ្ញើជូននាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២០០០ ទំព័រ ២ [ភាសាអង់គ្លេស]។ លិខិតពីអគ្គលេខាធិការ អ.ស.ប. Kofi Annan ផ្ញើជូននាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០០០ ទំព័រ ១, ៣ [ភាសាអង់គ្លេស]។ វិសាលភាពនៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. គឺជាចំណុចចម្បងនៃការចម្រូងចម្រាសរវាងភាគីនៃកិច្ចព្រមព្រៀង។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានសម្តែងសេចក្តីព្រួយបារម្ភថា "ប្រសិនបើធ្វើឡើងដោយមិនត្រឹមត្រូវ និង ដោយគ្មានការយកចិត្តទុកដាក់ទេ ការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនឹងធ្វើឱ្យអតីតមន្ត្រីខ្មែរក្រហម និងអ្នកឋានៈធម្មតាផ្សេងទៀតមានការភ័យខ្លាច ដែលអ្នកទាំងនោះបានចុះចូលរួចហើយ..."។ លិខិតខ្លឹមសារដូចគ្នាចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ១៩៩៩ ពីតំណាងអចិន្ត្រៃយ៍របស់ប្រទេសកម្ពុជាប្រចាំអង្គការសហប្រជាជាតិ ផ្ញើជូនអគ្គលេខាធិការ និង ប្រធានក្រុមប្រឹក្សាសន្តិសុខ សម័យប្រជុំលើកទី ៥៣ របៀបវារៈលេខរៀង ១១០ ឯកសារ អ.ស.ប. លេខ A/53/851-S/1999/230 (ថ្ងៃទី ៣ ខែមីនា ឆ្នាំ ១៩៩៩) ឧបសម្ព័ន្ធ លិខិតចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ១៩៩៩ ពីនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ផ្ញើជូនអគ្គលេខាធិការ។

[183] លិខិតពីអគ្គលេខាធិការ អ.ស.ប. Kofi Annan ផ្ញើជូននាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២០០០ ទំព័រ ២ [ភាសាអង់គ្លេស]។

ពេលជួបជាមួយនាយករដ្ឋមន្ត្រី សម្តេច ហ៊ុន សែន នៅក្នុងខែមេសា ឆ្នាំ ២០០០ អ.ស.ប. បានស្នើថា ការខ្វែងយោបល់គ្នារវាង ស.ច.ស. ទាំងពីរ គួរត្រូវបានដោះស្រាយដោយ អ.ប.ជ. ដែលមានចៅក្រមកម្ពុជាចំនួនបីរូប និង ចៅក្រមអន្តរជាតិចំនួនពីររូប[184]។ វិធានស្តីពីសំឡេងភាគច្រើនលើសលប់ត្រូវបានស្នើឡើង ដើម្បីធានាថា ការចោទប្រកាន់ និង ការស៊ើបអង្កេតជនសង្ស័យនឹងមិនជាប់គាំងដោយសារភាពទាល់ច្រករវាង ស.ច.ស.[185]។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ដែលអនុម័តដោយសភាជាតិកម្ពុជា បានទទួលការយល់ព្រមពីព្រឹទ្ធសភា និង ក្រុមប្រឹក្សាធម្មនុញ្ញ និង ចុងក្រោយបំផុតត្រូវបានប្រកាសឱ្យប្រើ នៅថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០១ មានចែងអំពីវិធានស្តីពីសំឡេងភាគច្រើនលើសលប់៖ ប្រសិនបើគ្មានសំឡេងភាគច្រើនលើសលប់នៅ អ.ប.ជ. ទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ"[186]។ កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប. បានសម្រេចនៅថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០០៣ មានបទប្បញ្ញត្តិដូចគ្នានឹងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[187]។ វិធានផ្ទៃក្នុង ដែលត្រូវបានពិនិត្យសម្រេចចុងក្រោយដោយកិច្ចប្រជុំពេញអង្គនៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០០៧ ឆ្លុះបញ្ចាំងកិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[188]។

---

[184] លិខិតពីអគ្គលេខាធិការ អ.ស.ប. Kofi Annan ផ្ញើជូននាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០០០ ទំព័រ ១។

[185] លិខិតពីអគ្គលេខាធិការ អ.ស.ប. Kofi Annan ផ្ញើជូននាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០០០ ឧបសម្ព័ន្ធ មាត្រា ៥ស្ទួន(៤)។

[186] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ HJ/1/3/01 (កែសម្រួលដោយ Helen Jarvis នៅថ្ងៃទី ១ ខែមករា ឆ្នាំ ២០០១) មាត្រា ២៣៖ "សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឱ្យមានបណ្តឹងឧទ្ធរណ៍ តម្រូវឱ្យមានសំឡេងវិជ្ជមាន ពីចៅក្រមបួនរូបយ៉ាងតិច។ ... ប្រសិនបើពុំមានមតិភាគច្រើន ដូចដែលតម្រូវឱ្យមានចំពោះសេចក្តីសម្រេចទេ ការស៊ើបអង្កេតត្រូវធ្វើបន្តទៅទៀត"។ *សូមមើលផងដែរ* Stephen Heder *យុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទាក់ទងនឹង "មេដឹកនាំជាន់ខ្ពស់" និង ជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មខ្មែរក្រហម៖ ប្រវត្តិសាស្ត្រ និង ដំណើរការវិវឌ្ឍន៍នាពេលថ្មីៗនេះ* ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១២ ទំព័រ ៣៨ [ភាសាអង់គ្លេស]។ គេហទំព័រ អ.វ.ត.ក. *កាលប្បវត្តិនៃការបង្កើត អ.វ.ត.ក. https://www.eccc.gov.kh/km/about-eccc/chronologies?page=3*។ មាត្រា ៩ នៃកិច្ចព្រមព្រៀង (ដែលកត់សម្គាល់ថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ត្រូវបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០១)។ ក្រោយមកច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ ២០០៤ ប៉ុន្តែ វិសោធនកម្មទាំងនេះមិនទាក់ទងនឹងវិធានដែលចែងអំពីសំឡេងភាគច្រើនលើសលប់នៅ អ.ប.ជ. ឬ យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ឡើយ។

[187] មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង។ *សូមមើលផងដែរ* មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[188] *សូមមើល* វិធាន ៧២(៤)(ឃ) វិធាន ៧៧(១៣ ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ http://www.eccc.gov.kh/sites/default/files/legal-documents/ECCC_IRs_Khmer_2007_06_12%5B1%5D_0.pdf។

៣៤. ខណៈដែលភាគីនៃកិច្ចព្រមព្រៀង និង អ្នកព្រាងវិធានផ្ទៃក្នុង បានប្រមើលមើលឃើញថា ស.ច.ស. អាចខ្វែងយោបល់គ្នា និង បានបង្កើតយន្តការដោះស្រាយការខ្វែងយោបល់គ្នា នៅក្នុងដំណាក់កាលស៊ើបអង្កេត ភាគី និង អ្នកព្រាង មានបំណងទុកស្ថានភាពដីកាដំណោះស្រាយផ្ទុយគ្នានេះចោលដោយគ្មានដំណោះស្រាយនៅដំណាក់កាលនៃដីកាដំណោះស្រាយ។ ពួកគេមិនមានចេតនាឱ្យរឿងក្ដីបន្តទៅជំនុំជម្រះឡើយ នៅពេលដីកាលើកលែងការចោទប្រកាន់ និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានចេញក្នុងពេលដំណាលគ្នានោះ។ ផ្ទុយមកវិញ ភាគីនៃកិច្ចព្រមព្រៀង និង អ្នកព្រាងវិធានផ្ទៃក្នុង បានផ្ដល់ឋានៈស្មើគ្នាដល់ ស.ច.ស. និង សិទ្ធអំណាចឯករាជ្យលើការស៊ើបអង្កេត[189] និង សិទ្ធិអំណាចឆន្ទានុសិទ្ធិ ក្នុងការសម្រេចលើវិធីដោះស្រាយការខ្វែងយោបល់គ្នានៅពេលកើតឡើង[190]។

---

[189] កិច្ចព្រមព្រៀង និង ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. ចែងអំពី ស.ច.ស. ពីររូប ម្នាក់ជាចៅក្រមកម្ពុជា និង ម្នាក់ទៀតជាចៅក្រមអន្តរជាតិ ដែល "មានឋានៈស្មើគ្នា"។ មាត្រា ៥(១) នៃកិច្ចព្រមព្រៀង។ មាត្រា ២៧ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.។ វិធានផ្ទៃក្នុងចែងថា ស.ច.ស. អាចបំពេញកិច្ចដោយឯករាជ្យពីគ្នា៖ វិធាន ១៤(២) ផ្ដល់ឱ្យ ស.ច.ស. ម្នាក់ នូវក្រឡាបញ្ជីម្នាក់ ហើយ វិធាន ១៤(៧) ផ្ដល់ឱ្យ ស.ច.ស. នូវអំណាចឆន្ទានុសិទ្ធិប្រើប្រាស់នីតិវិធីដោះស្រាយតាមវិធាន ៧២ ក្នុងករណីដែល ស.ច.ស. ខ្វែងយោបល់គ្នា។ អ.ប.ជ. បានសម្រេចថា ស.ច.ស. "មានឯករាជ្យភាពចំពោះការស៊ើបអង្កេតរបស់ខ្លួន"។ *រឿងក្ដី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ១៦) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តចិរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៩ ឯកសារ C20/5/18 កថាខណ្ឌ ៦៣ (សេចក្ដីយោងខាងក្នុងត្រូវបានលុបចោល)។ *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ២៤) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ២២។

[190] ខណៈដែល ស.ច.ស. ត្រូវ "សហការគ្នាដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត" ស.ច.ស. មិនទាមទារឱ្យត្រូវតែឯកភាពគ្នានោះទេ។ មាត្រា ៥(៤) នៃកិច្ចព្រមព្រៀង ។ មាត្រា ២៣ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.។ *សូមមើលផងដែរ* វិធាន ១៤(៧) (ដែលចែងថា "ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត នីតិវិធីដែលមានចែងក្នុងវិធាន ៧២ ត្រូវយកមកអនុវត្ត")។ វិធាន ៧២(១) (ដែលចែងថា ស.ច.ស. *អាច* ធ្វើកំណត់ហេតុអំពីមូលហេតុនៃការខ្វែងយោបល់គ្នានៅក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដែលរក្សាទុកដោយក្រឡាបញ្ជីរបស់ ស.ច.ស.)។ វិធាន ៧២(២) (ដែលចែងថា ស.ច.ស. *អាច* នាំយកករណីខ្វែងយោបល់គ្នាទៅដោះស្រាយចំពោះមុខ អ.ប.ជ.)។ *សូមមើលផងដែរ រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៧៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ២៧៤ (ដែលសម្រេចថា ស.ច.ស. "មិនមានកាតព្វកិច្ច" ត្រូវប្ដឹងទៅ អ.ប.ជ. ទេ ក្នុងករណីដែល ស.ច.ស. ខ្វែងយោបល់គ្នាលើបញ្ហាណាមួយនៅចំពោះមុខខ្លួន)។

៣៥. វិធាន ៧២ ដែលចែងអំពីដំណោះស្រាយនៃការខ្វែងយោបល់គ្នារវាង ស.ច.ស. ផ្ដល់ឆន្ទានុសិទ្ធិដល់ ស.ច.ស. នៅពេលមានការខ្វែងយោបល់គ្នា ឱ្យចុះការខ្វែងយោបល់គ្នានៅក្នុងកំណត់ហេតុផ្ទៃក្នុង ឬ បញ្ជូនការខ្វែងយោបល់គ្នានេះទៅ អ.ប.ជ. ដើម្បីរកដំណោះស្រាយ[191]។ តួនាទីរបស់ អ.ប.ជ. នៅក្នុងការដោះស្រាយការខ្វែងយោបល់គ្នាអនុលោមតាមវិធាន ៧២ គឺ "សម្រេចពីបញ្ហាខ្វែងគំនិតគ្នារបស់...[ស.ច.ស.]"[192]។ អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក.") "បានទទួលស្គាល់យ៉ាងច្បាស់អំពីសេណារីយ៉ូ ដែល ស.ច.ស. ខ្វែងយោបល់គ្នាយ៉ាងសមហេតុផលលើបញ្ហាយុត្តាធិការបុគ្គល ... នៅក្នុងបរិបទនៃនីតិវិធីខ្វែងយោបល់"[193]។

> "ឧទាហរណ៍ ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតណាមួយមានកំហុសក្នុងការសម្រេចចេញ ឬ ក្នុង *ការស្នើ* ឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់ដោយមូលហេតុថា ជនត្រូវចោទ គឺជា ឬ មិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ ទៅលើផលវិបាកនៃសេណារីយ៉ូនេះទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ""[194]។

៣៦. ស.ច.ស. មិនបានប្ដឹងទៅ អ.ប.ជ. អំពីសំណើនៅក្នុងវិធាន ៧២ ដើម្បីដោះស្រាយការយល់ឃើញផ្ទុយគ្នារបស់ខ្លួន នៅមុនពេលចេញដីកាដំណោះស្រាយឡើយ[195]។ ក៏គ្មានការតម្រូវឱ្យ ស.ច.ស.

---

[191] វិធាន ៧២(១)-(២)។

[192] *រឿងក្ដី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ 00១/១៨-0៧-២00៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ៦៥ (សេចក្ដីយោងខាងក្នុងត្រូវបានលុបចោល)។

[193] *រឿងក្ដី អោ អាន* សំណុំរឿងលេខ 00៤/២/0៧-0៩-២00៩-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D262.2 កថាខណ្ឌ ១៥ ដែលដកស្រង់ *រឿងក្ដី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ 00១/១៨-0៧-២00៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ៦៥។

[194] *រឿងក្ដី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ 00១/១៨-0៧-២00៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ៦៥ (គូសបញ្ជាក់បន្ថែម) ដែលដកស្រង់ មាត្រា ២៣ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង វិធាន ៧២(៤)(ឃ)។

[195] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ២៧៖ "នៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១៨ ស.ច.ស. បានចុះបញ្ជីនូវករណីខ្វែងយោបល់មួយពាក់ព័ន្ធនឹងការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និង ផ្ទុយគ្នា"។

ធ្វើដូច្នេះដែរ[196]។ ស.ច.ស. បានអនុវត្តអំណាចឆន្ទានុសិទ្ធិ ក្នុងការចុះការខ្វែងយោបល់គ្នានៅក្នុងកំណត់ហេតុផ្ទៃក្នុង[197] ដោយបានបង្ហាញការយល់ឃើញរបស់ពួកគេរៀងៗខ្លួននៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន[198]។

៣៧. ការចាត់ទុកដីកាដំណោះស្រាយផ្ទុយគ្នា ថាជាការខ្វែងយោបល់គ្នាដោយគ្មានដំណោះស្រាយ នឹងដកហូតសិទ្ធិអំណាចតាមឆន្ទានុសិទ្ធិរបស់ពួកគាត់ មិនឱ្យសម្រេចអំពីវិធីដោះស្រាយការខ្វែងយោបល់គ្នាដែលកើតឡើង។ បើទោះជា អ.ប.ជ. ចាត់ទុកដីកាដំណោះស្រាយផ្ទុយគ្នាថាជាការខ្វែងយោបល់គ្នាដោយគ្មានដំណោះស្រាយក៏ដោយ ក៏នីតិវិធីដោះស្រាយការខ្វែងយោបល់គ្នាអនុលោមតាមវិធាន ៧២ នឹងមិនអាចដោះស្រាយស្ថានភាពដីកាដំណោះស្រាយផ្ទុយគ្នាបាននោះដែរ។ អនុលោមតាមវិធាន ៧២(៤)(ឃ) ប្រសិនបើ អ.ប.ជ. មិនអាចរកសំឡេងភាគច្រើនលើសលប់ ដើម្បីដោះស្រាយការខ្វែងយោបល់គ្នានោះទេ "សេចក្តីសម្រេចដែលមិនមានសំឡេងគាំទ្រមានន័យថា ដីកា ... ដែលធ្វើឡើងដោយ [ស.ច.ស.] ណាម្នាក់ ត្រូវមានសុពលភាព ឬ មានន័យថា ដីកា ... ធ្វើដោយ [ស.ច.ស.] ម្នាក់ត្រូវតែយកមកអនុវត្ត"[199]។ ស.ច.ស. ទាំងពីរ បានចេញដីកាដំណោះស្រាយ ហើយ ស.ច.ស. ទាំងពីរមានឋានៈស្មើគ្នា[200]។ អនុលោមតាមវិធាន ៧២(៤)(ឃ) ដីកាដំណោះស្រាយទាំងពីរមានអានុភាពអនុវត្តដូចគ្នា។

---

[196] វិធាន ១៤(៤) វិធាន ៧២(១) -(២)។

[197] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ២៧។

[198] ខុសពីសេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះ ដែលតម្រូវឱ្យចេញសេចក្តីសម្រេចតែមួយ ដោយដាក់បន្ថែមយោបល់របស់សំឡេងភាគច្រើន និង សំឡេងភាគតិច ក្នុងករណីដែលមិនអាចទទួលបានសំឡេងជាឯកច្ឆន្ទ ក្របខ័ណ្ឌ អ.វ.ត.ក. មិនតម្រូវឱ្យ ស.ច.ស. ចេញដីកាដំណោះស្រាយតែមួយទេ។ វិធាន ៦៧(១) ចែងថា ស.ច.ស. "បញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថា ត្រូវចោទប្រកាន់ និង បញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់"។ វិធាន ១(២) ចែងថា "ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះចំពោះពាក្យ [ស.ច.ស.] សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និង ចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ..."។ សូមប្រៀបធៀបជាមួយនឹង មាត្រា ៤(២) នៃកិច្ចព្រមព្រៀង មាត្រា ១៤ថ្មី(២) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. វិធាន ៧៧(១៤) សន្ទានុក្រមនៃវិធានផ្ទៃក្នុង (ដែលកំណត់និយមន័យពាក្យ "អង្គជំនុំជម្រះ" ថាជា អ.ប.ជ. អ.ជ.ស.ដ. និង អ.ជ.ត.ក.)។

[199] វិធាន ៧២(៤)(ឃ)។

[200] មាត្រា ៥(១) នៃកិច្ចព្រមព្រៀង។ មាត្រា ២៧ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

៣៨. ការព្យាយាមជំនះឧបសគ្គអនុលោមតាមនីតិវិធីដោះស្រាយវិវាទក្នុងវិធាន ៧២ ដោយចាត់ទុកថា ការចេញដីកាដំណោះស្រាយផ្ទុយគ្នា មិនត្រូវបានអនុញ្ញាត ការបង្វិលរឿងក្តីត្រឡប់ទៅវិញ ជាមួយនឹងការណែនាំឱ្យធ្វើដីកាដំណោះស្រាយតែមួយ នឹងមិនត្រឹមតែជាការប្រើប្រាស់មិនសមស្របនូវធនធានហិរញ្ញវត្ថុ និង ធនធានមនុស្សរបស់ អ.វ.ត.ក. ដែលជម្រុញឱ្យមានបណ្តឹងឧទ្ធរណ៍ ចម្លើយ និង ការឆ្លើយតបបន្ថែមប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងរំលោភសិទ្ធិរបស់ មាស មុត ក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីដែលឈានដល់ការបញ្ចប់ក្នុងពេលវេលាមួយសមស្រប[201]។ ប្រសិនបើ អ.ប.ជ. បានយល់ឃើញថា ស.ច.ស. ត្រូវចេញដីកាដំណោះស្រាយតែមួយ អ.ប.ជ. នឹងនិយាយដូច្នេះជាមិនខាន នៅពេលដែលលើកឡើងដោយភាគី តាមរយៈការសុំឱ្យបញ្ជាក់បំភ្លឺលើអង្គច្បាប់ក្នុងករណីដែល ស.ច.ស. ខ្វែងយោបល់គ្នាថាតើត្រូវលើកលែងការចោទប្រកាន់ ឬ បញ្ជូនរឿងទៅជំនុំជម្រះនោះ[202]។ ខណៈដែលបញ្ហាអង្គច្បាប់នេះ មិនទាន់ដល់ពេលវេលាត្រូវពិចារណានៅពេល អ.ប.ជ. ត្រូវបានស្នើសុំឱ្យពិនិត្យមើលឡើងវិញ ច្បាស់ណាស់ថាវានឹងកើតឡើង ហើយមិនមែនជាសម្មតិកម្មតាមបែបស្រាវជ្រាវនោះទេ។ ទោះក្នុងករណីណាក៏ដោយ នៅពេលពិចារណាអំពីរយៈពេលនៃការស៊ើបអង្កេតរបស់ ស.ច.ស.[203] និង សំអាងហេតុលម្អិតនៅក្នុងដីកាដំណោះស្រាយ[204] ការបង្វិលរឿងក្តីគ្រាន់តែជាការឱ្យតម្លៃទៅលើទម្រង់ ជាងខ្លឹមសារតែប៉ុណ្ណោះ ដោយគ្រាន់តែបង្កើតឯកសាររួមមួយ ដើម្បីច្របាច់បញ្ចូលការយល់ឃើញដែលមិនអាចធ្វើឱ្យដូចគ្នាបានរបស់ ស.ច.ស. អំពីយុត្តាធិការបុគ្គលលើលោក មាស មុត ប៉ុណ្ណោះ ហើយគ្មានអានុភាពលើសេចក្តីសន្និដ្ឋានដែលចៅក្រមទាំងពីរបានធ្វើឡើងដោយឯករាជ្យនោះទេ។ ស.ច.ស. ម្នាក់នៅតែសម្រេចឱ្យ

---

[201] វិធាន ២១(៤)៖ "ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប"។

[202] អ.ប.ជ. ត្រូវបានស្នើសុំឱ្យផ្តល់ការយល់ឃើញអំពីច្បាប់៖ ក. ប្រសិនបើ ស.ច.ស. ខ្វែងយោបល់គ្នាអំពីថា តើត្រូវលើកលែងការចោទប្រកាន់ ឬ ក៏ចោទបញ្ជូនទៅជំនុះជម្រះ និង ខ. ប្រសិនបើករណីខ្វែងយោបល់គ្នានេះនៅចំពោះមុខ អ.ប.ជ. ហើយ អ.ប.ជ. មិនអាចរកបានសំឡេងភាគច្រើនលើសលប់នៅពេលសម្រេចលើករណីខ្វែងយោបល់គ្នានេះ។ អ.ប.ជ. បានបដិសេធមិនផ្តល់ការបញ្ជាក់បំភ្លឺ ដោយយល់ឃើញថា ខ្លួន "មិនមានយុត្តាធិការដើម្បីដោះស្រាយបញ្ហាជាសម្មតិកម្ម ឬ ផ្តល់មតិយោបល់ណែនាំនោះទេ" *សំណុំរឿង យឹម ទិត្យ* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D205/1/1/2 កថាខណ្ឌ ៤, ៨។

[203] *សូមមើល* កថាខណ្ឌ ១៤-២០ *ខាងលើ*។

[204] *សូមមើល* កថាខណ្ឌ ២១-៣១ *ខាងលើ*។ *សូមមើលផងដែរ* កថាខណ្ឌ ៥៤-៦០ *ខាងក្រោម*។

លើកលែងការចោទប្រកាន់ ហើយចៅក្រមម្នាក់ទៀតនៅតែសម្រេចឱ្យបញ្ជូនរឿងទៅជំនុំជម្រះ។ ឧបសគ្គអនុលោមតាមវិធាន ៧២ នៅតែពុំអាចជំនះបានដដែល។

៣៩. នៅពេលនេះ អ.ប.ជ. បានទទួលបណ្តឹងឧទ្ធរណ៍ខ្វែងជំទាស់ដីកាសម្រេចលើកលែងចោទប្រកាន់ និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ[205] បញ្ហាចោទសំខាន់ដែល អ.ប.ជ. ត្រូវដោះស្រាយ គឺថាតើដីកាដំណោះស្រាយណាមួយនឹងមានអានុភាពអនុវត្ត។ វិធាន ៧៧ ចែងអំពីបណ្តឹងឧទ្ធរណ៍ជំទាស់សេចក្តីសម្រេច ឬ ដីកាសម្រេចរបស់ ស.ច.ស.។ អនុលោមតាមវិធាន ៧៧ តួនាទីរបស់ អ.ប.ជ. គឺត្រូវសម្រេចថាតើ ស.ច.ស. បានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនបានត្រឹមត្រូវ នៅក្នុងការឈានដល់ការធ្វើសេចក្តីសន្និដ្ឋានផ្ទុយគ្នា ឬយ៉ាងណា[206] ជាជាងដោះស្រាយភាពខុសគ្នារបស់ ស.ច.ស. នោះ។ នៅពេលរកមិនឃើញមានកំហុស ឬ ការរំលោភបំពានដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ចៅក្រមណាម្នាក់ អ.ប.ជ. មិនអាចយកការយល់ឃើញរបស់ខ្លួនមកជំនួសការយល់ឃើញរបស់ ស.ច.ស. នោះទេ[207]។

---

[205] *សូមមើល* សេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៩ ឯកសារ D266/1។ សេចក្តីជូនដំណឹងរបស់ មាស មុត អំពីបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០១៨ ឯកសារ D267/1។ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាជាតិ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០១៩ ឯកសារ D267/2។

[206] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២១។ *សូមមើលផងដែរ* កថាខណ្ឌ ៧-៩ *ខាងលើ*។

[207] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ២៤, ២៦។ *សូមមើលផងដែរ រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៦៧) សាលដីកាស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៦៧។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការណែនាំឱ្យពិចារណាឡើងវិញលើសំណើសុំ D153, D172, D173, D174, D178 និង D284

៤០. ប្រសិនបើភាគីនៃកិច្ចព្រមព្រៀង និង អ្នកព្រាងវិធានផ្ទៃក្នុង មានបំណងចង់ឱ្យរឿងក្តីបន្តទៅមុខ នៅពេលមានដីកាលើកលែងការចោទប្រកាន់ និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចេញក្នុងពេលដំណាលគ្នា ហើយគ្មានដីកាណាមួយត្រូវបានច្រានចោលនៅក្នុងដំណាក់កាលបណ្តឹងឧទ្ធរណ៍ដោយសំឡេងភាគច្រើនលើសលប់នោះ ភាគី និង អ្នកព្រាងវិធានផ្ទៃក្នុង ប្រហែលជានឹងបានព្រមព្រៀងគ្នាលើបទប្បញ្ញត្តិច្បាស់លាស់ដែលចែងអំពីលទ្ធផលបែបនេះហើយ។ មិនមានទាល់តែសោះ។ ការធ្វើវិសោធនកម្មណាមួយលើវិធានផ្ទៃក្នុង នឹងតម្រូវឱ្យមានការកែប្រែច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និង កិច្ចព្រមព្រៀង ដោយផ្អែកលើការពិគ្រោះយោបល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប.[208]។ ហើយប្រសិនបើសន្មតថា រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប. បានឯកភាពគ្នានោះ វានឹងតម្រូវឱ្យចៅក្រមចំនួន ១៤ រូប ក្នុងចំណោមចៅក្រមចំនួន ១៩ រូប ដែលមានសិទ្ធិបោះឆ្នោត មានការឯកភាពគ្នាលើវិសោធនកម្មដែលបានស្នើឡើង ចំពោះវិធានផ្ទៃក្នុងដែលចែងអំពីនីតិវិធីរបស់ អ.វ.ត.ក.[209]។ គ្មានការធ្វើវិសោធនកម្មបែបនេះត្រូវបានធ្វើឡើងនោះទេ កុំថាឡើយដល់ទៅបានអនុម័តនោះ[210]។

**២. ការអនុវត្តវិធាន ៧៧(១៣) លើបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយផ្ទុយគ្នាអាចនាំទៅរកលទ្ធផលមិនសមហេតុផល បង្កឱ្យមានព្យសនកម្មដែលមិនអាចកែតម្រូវបានដល់សិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និង រំលោភលើរដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខ័ណ្ឌ អ.វ.ត.ក.**

៤១. អនុលោមតាមវិធាន ៧៧(១៣) សេចក្តីសម្រេចរបស់ អ.ប.ជ. លើបណ្តឹងឧទ្ធរណ៍ តម្រូវឱ្យមានសំឡេងគាំទ្រភាគច្រើនលើសលប់ នៃចៅក្រមចំនួន ៤ រូបក្នុងចំណោមចៅក្រមចំនួន ៥ រូប។ ប្រសិនបើ អ.ប.ជ. មិនអាចរកបានសំឡេងភាគច្រើនលើសលប់បានទេ វិធាន ៧៧(១៣) ចែងនូវ

---

ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D300/1/7 កថាខណ្ឌ ១៥៖ "អ.ប.ជ. បានលើកឡើងដដែលៗថា '[អ.ប.ជ.] មិនអាចយកការយល់ឃើញរបស់ខ្លួន ទៅដាក់ជំនួសការយល់ឃើញរបស់ [ស.ច.ស.] បានទេ'"។

[208] មាត្រា ២(៣), ៣០ នៃកិច្ចព្រមព្រៀង។

[209] វិធាន ៣, ១៨(៣)(ខ)។

[210] វិធានផ្ទៃក្នុង ត្រូវបានធ្វើវិសោធនកម្មចំនួន ៩ ដង ចាប់តាំងពីវិធាននេះត្រូវបានអនុម័តនៅឆ្នាំ ២០០៧។ *សូមមើល* វិធានផ្ទៃក្នុង ទំព័រ ៨១។ វិធាន ៧៧ ត្រូវបានធ្វើវិសោធនកម្មចំនួនពីរដង (នៅឆ្នាំ ២០០៨ និង ឆ្នាំ ២០១០) ប៉ុន្តែ វិធាន ៧៧(១៣) មិនដែលត្រូវបានធ្វើវិសោធនកម្មនោះទេ។ មិនមានសំណើសុំឱ្យធ្វើវិសោធនកម្មវិធាន ៧៧(១៣) នោះទេ។

សេចក្តីសម្រេចចំនួនពីរ៖ អនុលោមតាមវិធាន ៧៧(១៣)(ក) "ដីកា ឬ កិច្ចស៊ើបសួរ ដែលមិនមែនជាដីកា ... ត្រូវតម្កល់ទុកជាបានការ"។ អនុលោមតាមវិធាន ៧៧(១៣)(ខ) អ.ជ.ស.ជ. ទទួលបណ្តឹង "ដោយឈរលើមូលដ្ឋាននៃដីកាដំណោះស្រាយរបស់ [ស.ច.ស.]"។ ប្រសិនបើវិធាន ៧៧(១៣)(ក) អនុវត្តចំពោះដីកាលើកលែងការចោទប្រកាន់ និង វិធាន ៧៧(១៣)(ខ) អនុវត្តចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ ការអនុវត្តរួមគ្នានៃវិធានទាំងពីរនេះចំពោះបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយដែលផ្ទុយគ្នា អាចនាំទៅរកលទ្ធផលមិនសមហេតុផល និង បង្កជាព្យសនកម្មដែលមិនអាចកែតម្រូវបានលើសិទ្ធិរបស់ លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[211]។ ប្រសិនបើអនុវត្តតែវិធាន ៧៧(១៣)(ខ) អាចដោយហេតុថា វិធាន ៧៧(១៣)(ក) មិនអនុវត្តចំពោះដីកាលើកលែងការចោទប្រកាន់ ឬ ដោយហេតុថា វិធាន ៧៧(១៣)(ខ) មានអានុភាពលុបលើវិធាន ៧៧(១៣)(ក) នៅក្នុងដំណាក់កាលដីកាដំណោះស្រាយ នោះដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ អាចនឹងមានអនុភាពលើដីកាលើកលែងការចោទប្រកាន់ដោយស្វ័យប្រវត្តិ ដែលនេះគឺរំលោភបំពានលើរដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខ័ណ្ឌ អ.វ.ត.ក.[212]។

៤២. ការអនុវត្តវិធាន ៧៧(១៣)(ក) និង វិធាន ៧៧(១៣)(ខ) ទាំងពីរនេះ ចំពោះបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយដែលផ្ទុយគ្នា អាចនឹងនាំទៅរកលទ្ធផលមិនសមហេតុផល[213] ពីព្រោះវិធានផ្ទុយគ្នា អាចនឹងយកមកអនុវត្ត។ ខណៈដែលអនុលោមតាមវិធាន ៧៧(១៣)(ក) ដីកាលើកលែងការចោទប្រកាន់នឹងតម្កល់ទុកជាបានការ ហើយសំណុំរឿងនឹងត្រូវបញ្ចប់ និង រក្សាទុកក្នុងបណ្ណសារ[214]។ អនុលោមតាមវិធាន ៧៧(១៣)(ខ) ដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងតម្កល់ទុកជាបានការ ហើយសំណុំរឿងនឹងបន្តទៅជំនុំជម្រះ[215]។ ការបញ្ជូនរឿងក្តីទៅជំនុំជម្រះ នៅពេលដែល

---

[211] *សូមមើល* កថាខណ្ឌ ៤២-៤៤ *ខាងក្រោម*។

[212] *សូមមើល* កថាខណ្ឌ ៤៥-៤៦ *ខាងក្រោម*។

[213] លទ្ធផលមិនសមហេតុផល គឺជាលទ្ធផលដែល **ក.** "មិនពិត ឬ មិនសមហេតុផលយ៉ាងច្បាស់ក្រឡែត មិនស៊ីសង្វាក់គ្នាគួរឱ្យអស់សំណើចជាមួយនឹងហេតុផល ឬ វិចារណញ្ញាណដ៏សាមញ្ញ ហើយផ្ទុយគ្នាទៅវិញទៅមកយ៉ាងសមហេតុផល" **ខ.** "មិនស្របតាមវិចារណញ្ញាណ មិនសមស្របសោះ" ឬ **គ.** "គួរឱ្យអស់សំណើច ល្ងីល្ងើ"។ *សូមមើល* Veronica M. Dougherty *ភាពចម្លែក និង ដែនកំណត់នៃន័យត្រង់៖ ការកំណត់និយមន័យអំពីគោលការណ៍លទ្ធផលមិនសមហេតុផល នៅក្នុងការបកស្រាយច្បាប់* 44 AM. U.L. REV. 127, 141 (1994) (សេចក្តីដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[214] សូមប្រៀបធៀបជាមួយវិធាន ៧៧(១៣)(ក), ៦៩(២)(ខ)។

[215] សូមប្រៀបធៀបជាមួយវិធាន ៧៧(១៣)(ខ), ៦៩(២)(ក), ៧៩(១)។

រឿងក្តីនោះបានបញ្ចប់ (និង រក្សាទុកក្នុងបណ្ណសារ) អាចនឹងផ្ទុយគ្នាផង និង មិនយុត្តិធម៌ផង។ ស្រដៀងគ្នានេះដែរ ការបន្សល់ទុកដីកាបញ្ជូនរឿងទៅជំនុំជម្រះឱ្យលងបន្លាចលោក មាស មុត គ្មានទីបញ្ចប់ ក្រោយពីកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ផ្អាកនោះ[216] អាចនឹងបង្កព្យសនកម្ម ដែលមិនអាចកែតម្រូវបាន និង ដកសិទ្ធិរបស់គាត់ជាអចិន្ត្រៃយ៍ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលធានាដោយរដ្ឋធម្មនុញ្ញ។

៤៣. ស.ច.ស. ទាំងពីរបានទទួលស្គាល់ថា ការទុកដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមិនអាចជំទាស់បានឱ្យនៅលងបន្លាចគ្មានទីបញ្ចប់ គឺមិនស្របទៅនឹងតម្រូវការជាមូលដ្ឋាននៃនីតិរដ្ឋឡើយ[217]។ ហើយដូចអ្វីដែល ស.ច.ស. បានទទួលស្គាល់នូវផលវិបាកដែលមិនអាចទទួលយកបាននៃការទុកឱ្យបទចោទធ្ងន់ធ្ងរបែបនេះឱ្យនៅលងបន្លាចលោក មាស មុត ធ្វើឱ្យគាត់ស្ថិតក្នុងកន្លែងរងទុក្ខជាច្រើនឆ្នាំ អ.ប.ជ. ត្រូវតែទទួលស្គាល់ និង ផ្តល់ឱ្យដាច់ខាតដល់លោក មាស មុត នូវសិទ្ធិទាំងអស់របស់គាត់អនុលោមតាមរដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខ័ណ្ឌ អ.វ.ត.ក.[218] ពោលគឺ សិទ្ធិទទួលបានសច្ចធាណ៍និរទោស[219] ការពារក្តីខ្លួនគាត់[220] ទទួលបានការបញ្ចប់កិច្ចនីតិវិធីក្នុងពេលវេលាសមស្រប[221] និង ទទួលបានការការពារស្មើគ្នាចំពោះមុខ អ.វ.ត.ក.[222]។

---

[216] ប្រសិនបើ អ.ប.ជ. មិនអាចតម្កល់ដីកាដំណោះស្រាយមួយ ដោយបដិសេធដីកាដំណោះស្រាយមួយទៀតនៅពេលប្តឹងឧទ្ធរណ៍នោះ វាអាចជាករណីស្រដៀងគ្នាទៅនឹងករណីដែលមិនមានការដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ មានចែងក្នុងវិធាន ៦៩(២)(ខ)៖ "សំណុំរឿងត្រូវបានរក្សាទុកក្នុងបណ្ណសារក្រោយពីផុតរយៈពេលធ្វើបណ្តឹងឧទ្ធរណ៍"។

[217] សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D249 កថាខណ្ឌ ៥៤។

[218] *សូមមើល* ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ និង សារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៧ ឯកសារ D249/6 កថាខណ្ឌ ១៨។

[219] រដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខ័ណ្ឌ អ.វ.ត.ក. ធានាសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការសន្មតថាគ្មានទោសរហូតទាល់តែរកឃើញថាជាប់ពិរុទ្ធ តាមរយៈសេចក្តីសម្រេចស្ថាពរ មានអានុភាពអនុវត្ត អនុលោមតាមច្បាប់។ *សូមមើល* មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ១២(២) និង ១៣(១) នៃកិច្ចព្រមព្រៀង មាត្រា ៣៣ថ្មី ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. វិធាន ២១(១)(ឃ) មាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដែលត្រូវបានអនុម័ត និង បើកឱ្យចុះហត្ថលេខា ផ្តល់សច្ចាប័ន និង ចូលរួមជាសមាជិក ដោយសេចក្តីសម្រេចរបស់មហាសន្និបាត អ.ស.ប. លេខ 2200A (XXI) ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦ ចូលជាធរមាននៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៧៦ អនុលោមតាមមាត្រា ៤៩ ("កតិកាសញ្ញា ICCPR")។ ការសន្មតថាគ្មានទោស ដាក់បន្ទុកលើអយ្យការឱ្យបង្ហាញភស្តុតាងបញ្ជាក់ពីបទចោទ។ មិនអាច

---

សន្មតថាមានទោសទេ ប្រសិនបើបទចោទនោះមិនអាចមានភស្តុតាងបញ្ជាក់ឱ្យហួសពីវិមតិសង្ស័យ។ *សូមមើល* គណៈកម្មាធិការសិទ្ធិមនុស្ស មតិយោបល់រួមលេខ ៣២ មាត្រា ១៤៖ សិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ និង សាលាជម្រះក្តី និង សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ឯកសារ អ.ស.ប. លេខ CCPR/C/GC/32 ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០០៧ ("មតិយោបល់រួមលេខ ៣២") កថាខណ្ឌ ៣០។

[220] អនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលត្រូវបានបញ្ចូលក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខ័ណ្ឌ អ.វ.ត.ក. លោក មាស មុត ត្រូវបានធានាឱ្យមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។ សិទ្ធិការពារខ្លួនរបស់លោក មាស មុត រួមមាន សិទ្ធិទទួលបានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់សម្រាប់ការពារក្តី សិទ្ធិទទួលបានជំនួយផ្លូវច្បាប់ សិទ្ធិប្រាស្រ័យទាក់ទងជាមួយនឹងមេធាវីដើម្បីរៀបចំការពារក្តីប្រកបដោយប្រសិទ្ធភាព និង សិទ្ធិពិនិត្យសាក្សី និង ភស្តុតាងដាក់បន្ទុក។ *សូមមើល* មាត្រា ៣១, ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ១២(២), ១៣(១) នៃកិច្ចព្រមព្រៀង មាត្រា ៣៣ថ្មី, ៣៥ថ្មី(ខ)(ឃ)(ង) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. មាត្រា ១៤(៣)(ខ)(ឃ)(ង) នៃកតិកាសញ្ញា ICCPR។ *សូមមើលផងដែរ* មតិយោបល់រួមលេខ ៣២ កថាខណ្ឌ ៣២-៣៤, ៣៧-៣៩។

[221] រដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខ័ណ្ឌ អ.វ.ត.ក. ធានាឱ្យ លោក មាស មុត មានសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយគ្មានការពន្យារពេល និង កិច្ចដំណើរការនីតិវិធីដែលមានការបញ្ចប់ពិតប្រាកដ។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ១២(២), ១៣(១) នៃកិច្ចព្រមព្រៀង មាត្រា ៣៣ថ្មី, ៣៥ថ្មី(គ) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. វិធាន ២១(៤) មាត្រា ១៤(៣)(គ) នៃកតិកាសញ្ញា ICCPR។ គោលបំណងនៃសិទ្ធិនេះ គឺដើម្បីចៀសវាងកុំឱ្យទុកមនុស្សស្ថិតនៅក្នុងស្ថានភាពមិនច្បាស់លាស់អំពីជោគវាសនារបស់ខ្លួនក្នុងរយៈពេលយូរពេក និង ដើម្បីផលប្រយោជន៍យុត្តិធម៌។ ការធានាសិទ្ធិនេះទាក់ទងមិនត្រឹមតែនឹងពេលវេលារវាងពេលដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ និង ពេលវេលាដែលការជំនុំជម្រះក្តីគួរចាប់ផ្តើមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពេលវេលារហូតដល់មានសាលដីកាស្ថាពរផងដែរ។ *សូមមើល* មតិយោបល់រួមលេខ ៣២ កថាខណ្ឌ ៣៥។

[222] រដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខ័ណ្ឌ អ.វ.ត.ក. ធានាឱ្យ លោក មាស មុត ទទួលបានសិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និង សាលាជម្រះក្តី។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ១២(២), ១៣(១) នៃកិច្ចព្រមព្រៀង មាត្រា ៣៣ថ្មី, ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. វិធាន ២១(១)(ខ) មាត្រា ១៤(១), ២៦ នៃកតិកាសញ្ញា ICCPR។ សិទ្ធិនេះនាំឱ្យមានការទទួលបានសេវារដ្ឋបាលតុលាការប្រកបដោយប្រសិទ្ធភាព "ដើម្បីធានាថា នៅក្នុងនីតិវិធី គ្មានបុគ្គលណាម្នាក់ត្រូវបានដកសិទ្ធិប្តឹងរកយុត្តិធម៌"។ *សូមមើល* មតិយោបល់រួមលេខ ៣២ កថាខណ្ឌ ៩។ ការប្រព្រឹត្តិផ្សេងគ្នានៅក្នុងរឿងក្តីស្រដៀងគ្នា ត្រូវតែធ្វើឡើង "ដោយផ្អែកលើលក្ខណវិនិច្ឆ័យសមហេតុផល និង សត្យានុម័ត"។ *សូមមើល* រឿងក្តី *Rita Hiro Balani តទល់នឹង ប្រទេសអេស្ប៉ាញ* សេចក្តីជូនដំណឹងលេខ 1021/2001 ឯកសារ អ.ស.ប. លេខ CCPR/C/77/D/1021/2001 (ឆ្នាំ ១៩៩៨) កថាខណ្ឌ ៤.៣ *មាននៅគេហទំព័រ* http://www1.umn.edu/humanrts/undocs/1021-2001.html។ *សូមមើលផងដែរ* រឿងក្តី *Waldman តទល់នឹង ប្រទេសកាណាដា* (ការយល់ឃើញដែលត្រូវបានអនុម័តនៅថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ១៩៩៩) នៅក្នុងរបាយការណ៍គណៈកម្មាធិការសិទ្ធិមនុស្ស (ភាគ II) ឯកសារ អ.ស.ប. លេខ A/55/40 កថាខណ្ឌ ១០.៦ *មាននៅគេហទំព័រ* *https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=A%2F55%2F40%5BVOL.II%5D(SUPP)&Lang=en*។

៤៤. មិនមានយន្តការនៅ អ.វ.ត.ក. ក្នុងការផ្ទេររឿងក្តីទៅតុលាការ ឬ សាលាក្តីណាមួយឡើយ (ជាតិ ឬ អន្តរជាតិ)[223] ដែលអាចផ្តល់លទ្ធភាពឱ្យលោក មាស មុត តវ៉ាជំទាស់នឹងភស្តុតាងប្រឆាំងនឹងគាត់ តទល់ជាមួយអ្នកចោទប្រកាន់គាត់ ឬ រក្សានិរទោសរបស់គាត់។ អ្វីដែលមិនអាចប្រកែកបាននោះគឺ គាត់អាចនឹងត្រូវបានគេលាបពណ៌ជាឧក្រិដ្ឋជនសង្គ្រាម និង *ឧក្រិដ្ឋជនប្រល័យពូជសាសន៍*។ លោក មាស មុត និង ក្រុមគ្រួសារអាចនឹងរស់នៅជាមួយស្លាកស្នាមទុយ៌សជាអចិន្ត្រៃយ៍ ដោយសារលោក មាស មុត ត្រូវបានចោទប្រកាន់ដោយភាគីម្ខាងនៃសាលាក្តីដែលគាំទ្រដោយ អ.ស.ប. អំពីឧក្រិដ្ឋកម្មដែលជាការព្រួយបារម្ភបំផុតចំពោះសហគមន៍អន្តរជាតិ ពោលគឺបទចោទដែលគាត់មិនអាចតវ៉ាជំទាស់បានទាល់តែសោះ។ លោក មាស មុត ក៏នឹងមិនអាចដឹងផងដែរថា តើកិច្ចដំណើរការនីតិវិធីអាចនឹងបើកឡើងវិញប្រឆាំងនឹងគាត់ ឬយ៉ាងណានោះ ហើយប្រសិនបើដូច្នេះមែន ថាតើបទចោទទាំងនោះនឹងផ្អែកលើការស៊ើបអង្កេតរបស់ អ.វ.ត.ក. ឬយ៉ាងណា ឬ ថាតើរឿងក្តីរបស់គាត់អាចនឹងត្រូវបានស៊ើបអង្កេតជាថ្មីឬយ៉ាងណា។ ក្នុងរឿងក្តី ០០១ ០០២ និង ០០៤/០១ អ.ប.ជ. បានចេញសេចក្តីសម្រេចជាស្ថាពរ និង មានអនុភាពអនុវត្ត លើបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយទាំងអស់[224]។ លោក មាស មុត មិនត្រូវទទួលបានការអនុវត្តខុសពី ឌុច នួន ជា អៀង សារី

---

[223] សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D249 កថាខណ្ឌ ៥៥។ *សូមមើលផងដែរ* ដីកាដំណោះស្រាយរឿងក្តី ០០៤/១ កថាខណ្ឌ ១៦ (រកឃើញថា រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប. មិនបានព្យាយាម "កំណត់ឱ្យមានការស៊ើបអង្កេត និង ការជំនុំជម្រះទៅលើបុគ្គលដែលមិនស្ថិតនៅក្នុងលក្ខខណ្ឌនៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ទេ"។ *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ៧៤។

[224] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០២) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០០៨ ឯកសារ D99/3/42។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៤៥ & ១៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D427/2/15។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១០៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ ២០១១ ឯកសារ D427/4/15។ *រឿងក្តី អ៊ឹម ចែម* លេខ សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-

អៀង ធីរិទ្ធ ខៀវ សំផន អ៊ឹម ចែម ឬ ជនត្រូវចោទណាម្នាក់ផ្សេងទៀត នៅចំពោះមុខតុលាការកម្ពុជាឡើយ។

៤៥. ប្រសិនបើមានតែវិធាន ៧៧(១៣)(ខ) អនុវត្តចំពោះបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយផ្ទុយគ្នា ដីកាបញ្ជូនរឿងទៅជំនុំជម្រះអាចនឹងមានអានុភាពអនុវត្តលើដីកាសម្រេចលើកលែងចោទប្រកាន់ ដោយស្វ័យប្រវត្តិ ដែលជាការរំលោភលើរដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខ័ណ្ឌ អ.វ.ត.ក.។ អនុលោមតាមរដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខ័ណ្ឌ អ.វ.ត.ក. វិមតិសង្ស័យ ទាក់ទងនឹងយុត្តាធិការបុគ្គល ឬ ចំណុចផ្សេងពីនេះ ត្រូវតែបានជាប្រយោជន៍ដល់ជនត្រូវចោទតាមគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ[225]។ ក្របខ័ណ្ឌ អ.វ.ត.ក. ចែងឱ្យ ស.ច.ស. ឯករាជ្យទាំងពីរនាក់មានឋានៈស្មើគ្នា[226]។ ក្នុងករណីដែលគ្មានកំហុស ឬ ការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ ស.ច.ស.ជ. ដីកាសម្រេចលើកលែងចោទប្រកាន់ មិនអាចត្រូវបានទុកចោលឡើយ[227]។ ការអនុវត្តវិធាន ៧៧(១៣)(ខ) ដើម្បីឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះមានអនុភាពអនុវត្ត ដោយស្វ័យប្រវត្តិ លុបលើដីកាសម្រេចលើកលែងចោទប្រកាន់ អាចនឹងដកឋានៈស្មើគ្នារបស់ ស.ច.ស.ជ. និង សិទ្ធិអំណាចឆន្ទានុសិទ្ធិរបស់គាត់ក្នុង

---

អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20។

[225] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា៖ "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"។ មាត្រា ១២(២), ១៣(១) នៃកិច្ចព្រមព្រៀង មាត្រា ៣៣ថ្មី, ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. វិធាន ២១(១)។ *សូមមើលផងដែរ រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(០៤) សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១៖ "អង្គជំនុំជម្រះតុលាការកំពូល បញ្ជាក់យ៉ាងមុតមាំថា គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលកើតចេញពីគោលការណ៍ការសន្មតទុកជាមុនថាគ្មានទោស"។ គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ដែលត្រូវបានធានាដោយមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា ប្រហែលជាមិនត្រូវបានយកមកចរចាដោយភាគីនៃកិច្ចព្រមព្រៀងនោះទេ។ *សូមមើលផងដែរ* កថាខណ្ឌ ៥០-៥១ *ខាងក្រោម*។

[226] មាត្រា ៥(១) នៃកិច្ចព្រមព្រៀង។ មាត្រា ២៧ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ វិធាន ១៤(២), ១៤(៧), ៧២។

[227] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២១។

ការបង្ហាញទស្សនៈរបស់គាត់នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួនគាត់ផ្ទាល់[228]។ ការណ៍នេះអាចធ្វើឱ្យគាត់មានឋានៈទាបជាង ស.ច.ស.អ.។

៤៦. ការអនុវត្តវិធាន ៧៧(១៣)(ខ) ចំពោះបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយផ្ទុយគ្នា គឺការរឹងទទឹងក្នុងផ្លូវខុស និង ផ្ទុយពីគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា[229]។ ភាគីនៃកិច្ចព្រមព្រៀងមិនអាចចរចាឱ្យប្រាសចាកពីគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ នៅក្នុងការរៀបចំក្របខ័ណ្ឌ អ.វ.ត.ក. ដែលអាចឱ្យចៅក្រមកាត់បន្ថយ ធ្វើឱ្យចុះខ្សោយ ឬ មិនគោរពការអនុវត្តគោលការណ៍នេះ ក្នុងការព្រាងវិធានផ្ទៃក្នុង ដែលអនុវត្តកិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ឡើយ។ បើទោះបីជា ដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានទុកចោលដោយសំឡេងភាគច្រើនលើសលប់ក៏ដោយ ក៏ អ.ប.ជ. នៅតែចាំបាច់ត្រូវសម្រេចតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយសំឡេងភាគច្រើនលើសលប់ និង រកឃើញថា រឿងក្តីនេះគួរត្រូវបានបញ្ជូនទៅជំនុំជម្រះនៅក្នុងសវនាការ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះដែរ។ ដើម្បីសម្រេចដាក់ទោសជនជាប់ចោទនៅ អ.វ.ត.ក. បាន អ.ជ.ស.ដ. ត្រូវរកឱ្យបានសំឡេងភាគច្រើនលើសលប់នៃចៅក្រមចំនួន ៤ រូប[230]។ ដើម្បីសម្រេចបដិសេធការសម្រេចឱ្យរួចទោស អ.ជ.ត.ក. ត្រូវរកឱ្យបានសំឡេងភាគច្រើនលើសលប់នៃចៅក្រមយ៉ាងហោចណាសចំនួន ៥ រូប[231]។ វាជាការមិនសមហេតុផលឡើយដែលថា អនុលោមតាមវិធាន ៧៧(១៣) ចៅក្រមចំនួនតែមួយរូប ពីររូប ឬ សូម្បីតែបីរូបនៃ អ.ប.ជ. អាចបញ្ជូនរឿងទៅជំនុំជម្រះបាន ដោយមិនអើពើនឹងវិធានសំឡេងភាគច្រើនលើសលប់នោះ។

### ៣. សេចក្តីសន្និដ្ឋាន

៤៧. នៅក្នុងការបកស្រាយវិធាន ៧៧(១៣) មិនត្រឹមត្រូវ ស.ច.ស.អ. មានកំហុសអង្គច្បាប់ ដែលបានស្នើថា ដីកាដំណោះស្រាយទាំងពីរអាចនឹងមានអានុភាពអនុវត្តជារៀងរហូត ឬ មានតែដីកាបញ្ជូន

[228] *សូមមើល* កថាខណ្ឌ ៣៤, ៣៦ *ខាងលើ*។

[229] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា។ *សូមមើលផងដែរ* កថាខណ្ឌ ៥០-៥១ *ខាងក្រោម*។

[230] មាត្រា ៤(១)(ក) នៃកិច្ចព្រមព្រៀង។ មាត្រា ១៤(ថ្មី)(១)(ក) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ វិធាន ៩៨(៤)។

[231] មាត្រា ៤(១)(ខ) នៃកិច្ចព្រមព្រៀង។ មាត្រា ១៤(ថ្មី)(១)(ខ) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ វិធាន ១១១(៦)។

រឿងទៅជំនុំជម្រះរបស់គាត់តែប៉ុណ្ណោះ ដែលមានអានុភាពអនុវត្ត លើកលែងតែ អ.ប.ជ. សម្រេច តម្កល់ដីកាដំណោះស្រាយណាមួយ ដោយសំឡេងភាគច្រើនលើសលប់។ ខណៈដែលភាគីនៃកិច្ចព្រមព្រៀងប្រមើលមើលឃើញថា ស.ច.ស. អាចមិនយល់ស្របគ្នាដោយសមហេតុផល ក្នុងអំឡុងពេលនៃការស៊ើបអង្កេតរបស់ខ្លួន និង បានបង្កើតយន្តការដោះស្រាយវិវាទ នៅក្នុងដំណាក់កាលស៊ើបអង្កេតនៃកិច្ចដំណើរការនីតិវិធី ភាគីនៃកិច្ចព្រមព្រៀងមិនបានមានចេតនាបញ្ជូនរឿងក្តីទៅជំនុំជម្រះ នៅពេលដែលដីកាលើកលែងការចោទប្រកាន់ និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានចេញក្នុងពេលដំណាលគ្នានោះឡើយ។ ដោយរយៈពេលចរចាបានអូសបន្លាយយូរទម្រាំឈានដល់ការបង្កើត អ.វ.ត.ក. ប្រសិនបើភាគីនៃកិច្ចព្រមព្រៀងមានបំណងចង់បានលទ្ធផលបែបនេះមែននោះ ម្ល៉េះសមពួកគេបានព្រមព្រៀងគ្នាលើបទប្បញ្ញត្តិច្បាស់លាស់រួចទៅហើយ។ ការអនុវត្តវិធាន ៧៧(១៣) ដូចដែល ស.ច.ស.អ. បានស្នើ មិនត្រឹមតែនឹងនាំទៅរកលទ្ធផលមួយដែលមិនសមហេតុផលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចនឹងបង្កព្យសនកម្ម ដែលមិនអាចកែតម្រូវបាន និងដកហូតជារៀងរហូតនូវសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ដែលធានាដោយរដ្ឋធម្មនុញ្ញ និង ដែល អ.វ.ត.ក. មានកាតព្វកិច្ចប្រតិបត្តិតាម។

៤៨. ជម្រើសដែលបង្ហាញចំពោះ អ.ប.ជ. ដោយ ស.ច.ស.អ. គឺមិនសមហេតុផល ដោយសារជម្រើសនេះមិនអាចឱ្យប្រតិបត្តិតាម។ ការសន្និដ្ឋានរបស់គាត់ដែលថា ដីកាដំណោះស្រាយទាំងពីរអាចនឹងមានអានុភាពអនុវត្តនោះ នឹងធ្វើឱ្យលោក មាស មុត និង គ្រួសាររបស់គាត់ រស់នៅជាមួយនឹងស្ពាកស្ពាមទុយ៏សជាអចិន្ត្រៃយ៍ ដោយសារត្រូវបានបញ្ជូនទៅជំនុំជម្រះពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មថ្នាក់ជាតិ ពោលគឺជាបទចោទដែលអាច "លងបន្លាច [គាត់]"[232] ដោយគ្មានឱកាសបង្ហាញឱ្យឃើញពីនិរទោសរបស់គាត់ឡើយ។ ម្យ៉ាងវិញទៀត ការសន្និដ្ឋានរបស់ ស.ច.ស.អ. ដែលថា មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ប៉ុណ្ណោះ តាមរយៈការចេញដីកានេះ ដែលមានអានុភាពអនុវត្ត នៅពេលដែលមិនមានសំអាងផ្លូវច្បាប់ណាមួយសម្រាប់បដិសេធដីកាសម្រេចលើកលែងចោទប្រកាន់របស់ ស.ច.ស.ជ. នោះបង្ហាញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ មានអានុភាពលើដីកាសម្រេចលើកលែងចោទប្រកាន់របស់ ស.ច.ស.ជ. ដោយមិនអាចបញ្ជាក់ពីហេតុផល។ អ.ប.ជ. គួររកឃើញថា ស.ច.ស.

[232] *សូមមើល* សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D249 កថាខណ្ឌ ៥៤។

អ. មានកំហុសអង្គច្បាប់ក្នុងការពិចារណាថា វិធាន ៧៧(១៣) អនុវត្តចំពោះបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយផ្ទុយគ្នា និង ដែលស្នើថា ដីកាដំណោះស្រាយទាំងពីរ ឬ មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ប៉ុណ្ណោះដែលមានអានុភាពអនុវត្ត។ វិធាន ៧៧(១៣) អនុវត្តតែចំពោះដីកាដំណោះស្រាយរួមប៉ុណ្ណោះ។

**ខ. ស.ច.ស.អ. មានកំហុសអង្គច្បាប់ ដោយខកខានមិនបានសន្និដ្ឋានថា ប្រសិនបើ អ.ប.ជ. មិនអាចសម្រេចដោយសំឡេងភាគច្រើនលើសលប់ថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស ឬ ការរំលោភបំពានដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនទេនោះ ដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ**

៤៩. នៅក្នុងការបកស្រាយ វិធាន ៧៧(១៣) មិនត្រឹមត្រូវ និង ស្នើថា ដីកាដំណោះស្រាយទាំងពីរ ឬ មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ប៉ុណ្ណោះ ដែលមានអានុភាពអនុវត្ត នៅពេលគ្មានសំឡេងភាគច្រើនលើសលប់នៅ អ.ប.ជ.[233] ស.ច.ស.អ. បានខកខានមិនបានសន្និដ្ឋានថា ប្រសិនបើ អ.ប.ជ. មិនអាចសម្រេចដោយសំឡេងភាគច្រើនលើសលប់ថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស ឬ ការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនទេនោះ ដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពីព្រោះ៖ (ក) អនុលោមតាមគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ វិមតិសង្ស័យ ទាំងចំពោះអង្គហេតុ និង ការបកស្រាយបទប្បញ្ញត្តិច្បាប់ ត្រូវតែដោះស្រាយជាប្រយោជន៍ដល់លោក មាស មុត។ (ខ) ស.ច.ស. ទាំងពីររូប បានស៊ើបអង្កេតអង្គហេតុដែលខ្លួន

---

[233] *សូមមើល* កថាខណ្ឌ ៣២-៤៨ *ខាងលើ*។ នៅក្នុងប្រវត្តិនីតិវិធីនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួន ស.ច.ស.អ. បានបញ្ចូលមតិយោបល់របស់ ស.ច.ស. ដែលថា ដីកាដំណោះស្រាយទាំងពីរ "អាចមានអានុភាពអនុវត្ត" តាមវិធាន ៧៧(១៣) ដោយបានដកស្រង់ដីកាសម្រេចមួយដែលពួកគេបានជូនដំណឹងដល់ភាគី អំពីផលវិបាកដែលអាចមានចំពោះកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ ដោយសារការចេញដីកាដំណោះស្រាយផ្ទុយគ្នា។ *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៩ ជើងទំព័រ ២៩ ដែលដកស្រង់ *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D262.2 កថាខណ្ឌ ១៦។ ផ្ទុយទៅវិញ នៅក្នុងផ្នែកនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ ទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន ស.ច.ស.អ. បានពិចារណាថា វា "មិនច្បាស់" ទេថា តើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់នឹងមានអានុភាពអនុវត្តតាមវិធាន ៧៧(១៣) ឬយ៉ាងណា។ *សូមមើល ដូចយោងខាងលើ* កថាខណ្ឌ ៥៧៩។

បានទទួល និង បានផ្តល់ការរកឃើញអំពីអង្គហេតុទាំងនោះនៅក្នុងដីកាដំណោះស្រាយដែលមានសំអាងហេតុ។ (គ) នៅពេលដែលគ្មានកំហុស ឬ ការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ ស.ច.ស.ជ. ដែលអាចរារាំងដល់ការអនុវត្តគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ ដីកាសម្រេចលើកលែងចោទប្រកាន់មានអនុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

**១. អនុលោមតាមគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ ការសង្ស័យ ចំពោះអង្គហេតុ និង ការបកស្រាយបទប្បញ្ញត្តិច្បាប់ ត្រូវតែដោះស្រាយជាប្រយោជន៍ដល់លោក មាស មុត**

៥០. គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ គឺជាគោលការណ៍ជាមូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា[234] ក្របខ័ណ្ឌ អ.វ.ត.ក.[235] និង ច្បាប់អន្តរជាតិ[236]។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងថា "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់

---

[234] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា៖ "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"។ *សូមមើលផងដែរ រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(០៤) សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១៖ "អង្គជំនុំជម្រះតុលាការកំពូល បញ្ជាក់យ៉ាងមុតមាំថា គោលការណ៍នេះដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលកើតចេញពីគោលការណ៍សន្មតទុកជាមុនថាគ្មានទោស"។

[235] *សូមមើល* មាត្រា ១២(២), ១៣(១) នៃកិច្ចព្រមព្រៀង។ មាត្រា ៣៣ថ្មី, ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ វិធាន ២១(១)។

[236] *សូមមើល* ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តីយោធា Nurnberg តាមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ រឿងក្តីស្តីពីក្រសួងនានា មតិយោបល់ជំទាស់របស់ចៅក្រម Powers ភាគ XIV (ខែតុលា ឆ្នាំ ១៩៤៦ - ខែមេសា ឆ្នាំ ១៩៤៩) ទំព័រ ៨៧៨៖ "ហេតុនេះ បញ្ហាផ្នែកច្បាប់សម្រាប់យើងកំណត់ គឺមិនមែនថា តើអំពើជាក់លាក់មួយគួរតែជាឧក្រិដ្ឋកម្ម ឬយ៉ាងណានោះទេ តែថា តើវាជាឧក្រិដ្ឋកម្មនៅក្រោមវិធានជាធរមាននៅទីនេះ ឬយ៉ាងណា ដោយត្រូវចងចាំក្នុងចិត្តជានិច្ចថា យើងគ្មានសិទ្ធិពង្រីកវិធានទាំងនេះ តាមរយៈការបកស្រាយនោះទេ។ វាជាវិធានទូទៅដែលថា លក្ខន្តិកៈ និង វិធាននានាដែលកំណត់និយមន័យឧក្រិដ្ឋកម្មត្រូវតែបកស្រាយយ៉ាងតឹងរ៉ឹង ជាប្រយោជន៍ដល់ជនជាប់ចោទ។ ចំណុចនេះមានន័យថា បញ្ហានានាពាក់ព័ន្ធនឹងការបកស្រាយដែលមានមន្ទិលសង្ស័យ គួរតែត្រូវបានដោះស្រាយជាប្រយោជន៍ដល់ជនជាប់ចោទ"។ លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ចែងអំពីគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ដោយអនុវត្តនូវការបកស្រាយយ៉ាងតឹងរ៉ឹងនូវច្បាប់ព្រហ្មទណ្ឌ។ *សូមមើល* មាត្រា ២២(២) នៃលក្ខន្តិកៈទីក្រុងរ៉ូម៖ "និយមន័យនៃបទល្មើសព្រហ្មទណ្ឌ ត្រូវតែបកស្រាយអធិប្បាយឱ្យល្អិត ហើយមិនត្រូវពន្លាតតាមសទិសភាពឡើយ។។ នៅក្នុងករណីមានវិមតិសង្ស័យ

ជនជាប់ចោទ"។ វិធាន ២១(១) តម្រូវថា ក្របខ័ណ្ឌ អ.វ.ត.ក. ដែលរួមបញ្ចូលបទដ្ឋានអន្តរយុត្តិធម៌ជាតិ ភាពត្រឹមត្រូវ និង ដំណើរការសមស្របនៃច្បាប់ ដែលមានចែងនៅក្នុងកតិកាសញ្ញា ICCPR ដែលប្រទេសកម្ពុជាជាភាគី[237] ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍ជនត្រូវចោទ។

៥១. គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ "កើតចេញពីគោលការណ៍ការសន្និតជាមុនថាគ្មានទោស"[238] និង អនុវត្តគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី "រួមទាំងដំណាក់កាលមុនជំនុំជម្រះ"[239]។ គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវ

---

ការកំណត់និយមន័យនោះ ត្រូវបកស្រាយជាប្រយោជន៍ដល់ជនដែលកំពុងរងការស៊ើបអង្កេត ជំនុំជម្រះ ឬ ផ្តន្ទាទោស"។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Al Bashir* សំណុំរឿងលេខ ICC-02/05-01/09-3 សេចក្តីសម្រេចលើពាក្យសុំរបស់អយ្យការដែលស្នើសុំឱ្យចេញដីកាចាប់ខ្លួន Omar Hassan Ahmad Al Bashir ចុះថ្ងៃទី ៤ ខែមីនា ឆ្នាំ ២០០៩ កថាខណ្ឌ ១៥៦ (សេចក្តីយោងខាងក្នុងត្រូវបានលុបចោល)។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bemba* សំណុំរឿងលេខ ICC-01/05-01/08-424 សេចក្តីសម្រេចអនុលោមតាមមាត្រា ៦១(៧)(ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីការចោទប្រកាន់របស់រដ្ឋអាជ្ញាប្រឆាំងនឹង Jean-Pierre Bemba Gombo ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០៩ កថាខណ្ឌ ៣១។

[237] ប្រទេសកម្ពុជាបានចុះហត្ថលេខាលើកតិកាសញ្ញា ICCPR នៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ ១៩៨០ និង បានចូលជាសមាជិកនៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ១៩៩២។ *សូមមើល* ការចងក្រងសន្ធិសញ្ញា អ.ស.ប... កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ៖ https://treaties.un.org/Pages/ViewDetails.aspx?chapter=4&clang=_en&mtdsg_no=IV-4&src=IND (ចូលមើលចុងក្រោយនៅថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៩)។

[238] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(០៤) សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១។

[239] *សូមមើល ឧទា. រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៣១០។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ១៤៥ & ១៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D427/2/15 កថាខណ្ឌ ១៤៤។ តុលាការព្រហ្មទណ្ឌអន្តរជាតិក៏ពិចារណាផងដែរ ពីគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ដែលអនុវត្តនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី។ *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bemba* សំណុំរឿងលេខ ICC-01/05-01/08-424 សេចក្តីសម្រេចអនុលោមតាមមាត្រា ៦១(៧)(ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីការចោទប្រកាន់របស់រដ្ឋអាជ្ញាប្រឆាំងនឹង Jean-Pierre Bemba Gombo ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០៩ កថាខណ្ឌ ៣១៖ "ចុងក្រោយ ក្នុងការសម្រេចបែបនេះ [ស្តីពីការបញ្ជាក់នូវបទចោទ] អង្គជំនុំជម្រះចង់ធ្វើការគូសបញ្ជាក់ថា ដោយសារមានការណែនាំពីគោលការណ៍វិមតិសង្ស័យត្រូវបានជា

ចោទ អនុវត្តចំពោះអង្គហេតុ និង ការបកស្រាយបទប្បញ្ញត្តិច្បាប់[240]។ ស.ច.ស. ទាំងពីររូបបានពិចារណាឃើញថា ជនត្រូវចោទមានសិទ្ធិទទួលបាននូវ "ការវាយតម្លៃដោយមិនលំអៀងលើភស្តុតាង និង ការបកស្រាយច្បាប់ នៅក្នុងឋានានុក្រមតុលាការនៃ អ.វ.ត.ក. គ្រប់ជាន់ថ្នាក់ ដោយចាប់ផ្តើមពី ក.ស.ច.ស."[241]។ ស.ច.ស. ទាំងពីររូបបានពិចារណាឃើញថា គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ មាន "តួនាទីបន្ទាប់បន្សំក្នុងការបកស្រាយបទប្បញ្ញត្តិច្បាប់" នៅពេលដែលវិមតិសង្ស័យនៅតែមាន ក្រោយពីការអនុវត្តបទដ្ឋានវិធាននៃការបកស្រាយតាមប្រព័ន្ធច្បាប់ស៊ីវិល[242]។ ដោយពិចារណាពី "ភាពបត់បែន" នៃពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" ដែល "តម្រូវឱ្យ ស.ច.ស. មានសិទ្ធិអំណាចមួយចំនួន"[243] ភាពមន្ទិលសង្ស័យទាំងអស់អំពីយុត្តាធិការ អ.វ.ត.ក. លើលោក មាស មុត ត្រូវតែដោះស្រាយជាប្រយោជន៍ដល់គាត់។

---

ប្រយោជន៍ដល់ជនជាប់ចោទ ជាសមាសធាតុមួយនៃការសន្មតជាមុនថាគ្មានទោស ដែលជាគោលការណ៍ទូទៅនៅក្នុងនីតិវិធីព្រហ្មទណ្ឌអនុវត្តដូចគ្នានៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី រួមទាំងដំណាក់កាលមុនការជំនុំជម្រះផងដែរ"។

[240] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(០៤) សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១។

[241] *សូមមើល* ដីកាដំណោះស្រាយរឿងក្តី ០០៤/១ កថាខណ្ឌ ៣៦។

[242] *សូមមើល* ដីកាដំណោះស្រាយរឿងក្តី ០០៤/១ កថាខណ្ឌ ២៦ (សេចក្តីយោងខាងក្នុងត្រូវបានលុបចោល)។ *សូមមើលផងដែរ រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(០៤) សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១។

[243] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆ័ន្ទ) កថាខណ្ឌ ២១ ដោយពិចារណាដល់ភាពបត់បែននៃពាក្យ "មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត តម្រូវឱ្យ ស.ច.ស. មានសិទ្ធិអំណាចមួយចំនួន ..."។

## ២. ស.ច.ស. ទាំងពីររូបបានស៊ើបអង្កេតអង្គហេតុដែលពួកគាត់បានទទួល និង បានផ្តល់ការរកឃើញរបស់ខ្លួននៅក្នុងដីកាដំណោះស្រាយដែលមានសំអាងហេតុ

៥២. ស.ច.ស. "មានឯករាជ្យភាពចំពោះការដឹកនាំកិច្ចស៊ើបសួររបស់ខ្លួន"[244]។ ពួកគាត់ "កំណត់ពី *យុទ្ធសាស្ត្រ* ក្នុងការដឹកនាំកិច្ចស៊ើបសួរ ព្រមទាំង *ជម្រើសមធ្យោបាយនានា* ដែលនាំទៅរកការបង្ហាញការពិត ហើយក្នុងករណីនេះខ្លួនមានអំណាចឆន្ទានុសិទ្ធិ"[245]។ ស.ច.ស. ទាំងពីររូប បានស៊ើបអង្កេតអង្គហេតុដែលខ្លួនបានទទួល បានពិនិត្យសម្ភារភស្តុតាងដាក់បន្ទុក និង ដោះបន្ទុក ព្រមទាំងបានប្រមូលភស្តុតាងបន្ថែមទៀត[246]។ ស.ច.ស.ជ. មិនត្រូវបានបង្ខំឱ្យបន្តស៊ើបអង្កេត ឬ វាយតម្លៃឡើងវិញទៅលើការសម្រេចរបស់គាត់ និង ស.ច.ស.អ. Blunk ដែលថា លោក មាស មុត មិនស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ឡើយ។ ស.ច.ស. មាន "ឆន្ទានុសិទ្ធិសម្រេចដោយឯករាជ្យថា តើនៅពេលណាដែលខ្លួនយល់ឃើញថាការស៊ើបអង្កេតត្រូវបានបញ្ចប់"[247]។

៥៣. គ្មានអ្វីដែលបង្ហាញថា ភស្តុតាងណាមួយដែលប្រមូលបាននៅក្រោយថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ នឹងអាចបានកែប្រែសំអាងហេតុរបស់ ស.ច.ស.ជ. ដែលថា លោក មាស មុត មិនមានឋានៈខ្ពស់គ្រប់គ្រាន់ នៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ ដែលអាចបង្កើត ឬ មានឥទ្ធិពលលើគោលនយោបាយ ប.ក.ក. និង/ឬ ការអនុវត្តគោលនយោបាយនេះឡើយ ពោលគឺជាសំអាងហេតុដែលកំណត់ជាមូលដ្ឋាននូវការសន្និដ្ឋានរបស់គាត់ដែលថា លោក មាស មុត មិនមែនជាអ្នកទទួលខុស

---

[244] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ១៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៩ ឯកសារ C20/5/18 កថាខណ្ឌ ៦៣ (សេចក្តីយោងខាងក្នុងត្រូវបានលុបចោល)។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ២៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ២២។

[245] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតទៅលើ "សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធដូចជាយុទ្ធសាស្ត្រអនុវត្តដោយការិយាល័យសហចៅក្រមស៊ើបអង្កេត" ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០០៩ ឯកសារ D171/5 កថាខណ្ឌ ១៥ (អក្សរទ្រេតនៅក្នុងឯកសារដើម)។

[246] *សូមមើល* កថាខណ្ឌ ១៤-២០ *ខាងលើ*។

[247] សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ប្រតិចារឹកសំណុំរឿង ០០២ ចូលទៅក្នុងសំណុំរឿង ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D53/2 កថាខណ្ឌ ៥ (សេចក្តីយោងខាងក្នុងត្រូវបានលុបចោល)។

ត្រូវខ្ពស់បំផុត[248]។ ខណៈដែល ស.ច.ស.ជ. បានថ្លែងថា គាត់មិនបានប្រើប្រាស់ឯកសារដែលដាក់នៅក្នុងសំណុំរឿងក្រោយថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ គាត់បានដកស្រង់ឯកសារដែលដាក់ក្រោយកាលបរិច្ឆេទនេះ[249] ដែលនេះជាការចង្អុលបង្ហាញថា គាត់នៅតែចូលរួមពាក់ព័ន្ធនៅក្នុងកិច្ចស៊ើបសួរទាំងមូល ហើយបានពិចារណាលើសម្ភារឯកសារនៅក្នុងសំណុំរឿង នៅមុនពេលធ្វើសេចក្តីព្រាងដីកាសម្រេចលើកលែងចោទប្រកាន់។ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម គ្មានចំណុចណាមួយដែលចោទប្រកាន់លោក មាស មុត ថាមានឋានៈខ្ពស់នៅក្នុងឋានានុក្រមនៃរបបកម្ពុជាប្រជាធិបតេយ្យ ឬ មានសិទ្ធិអំណាចដ៏មានប្រសិទ្ធភាពខ្ពស់ជាងការចោទប្រកាន់ទាំងឡាយ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឡើយ[250]។ ដើម្បីរកឃើញថាជនណាម្នាក់ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅទូទាំងប្រទេសកម្ពុជា ក្នុងរយៈកាលរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ ១៩៧៩ គឺត្រូវមានភស្តុតាងបង្ហាញថា លោក មាស មុត បានពាក់ព័ន្ធក្នុងការបង្កើត ឬ មានឥទ្ធិពលលើគោលនយោបាយ ប.ក.ក. និង/ឬការអនុវត្តគោលនយោបាយទាំងនោះ ដែលជាការផ្ទុយទៅនឹងភាពត្រឹមតែជាអ្នកសម្របសម្រួល[251]។

៥៤. ស.ច.ស. ទាំងពីររូបបានផ្តល់ការរកឃើញរបស់ខ្លួន នៅក្នុងដីកាដំណោះស្រាយ លើអង្គហេតុទាំងឡាយ ដែលខ្លួនបានទទួលទាក់ទងនឹងលោក មាស មុត[252] ពោលគឺ តួនាទី និង ការទទួលខុស

[248] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១៦-២០, ៤២៩។

[249] *សូមមើល ឧទា.* ដីកាសម្រេចលើកលែងចោទប្រកាន់ ជើងទំព័រលេខ ៧, ២៥, ២៧-៤០, ៤២, ៤៦-៤៨, ៥១, ៥៤, ៥៧។ *សូមមើលផងដែរ ដូចយោងខាងលើ* ជើងទំព័រ ១១០០-០៣, ១១០៥ នៅពេលដែល ស.ច.ស.ជ. ក៏បានដកស្រង់ផងដែរនូវឯកសារនានាដែលមាននៅក្នុងសំណុំរឿង នៅក្រោយថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១។

[250] *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ១-២, ៦, ៧, ១០, ១២, ១៥ ដែលក្នុងនោះ ស.ព.អ. បានលើកឡើងថា គាត់បានយល់ឃើញថា ក.ស.ច.ស. បានទទួលយកអង្គហេតុរួចហើយ ទាក់ទងនឹងចម្ការទុរេន និង បិតត្រាំងកងកេង ទឹកសាប ការបោសសម្អាតនៅក្រចេះ និង តំបន់ ៤០៤ ព្រមទាំងរាម ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់គាត់។ អង្គហេតុថ្មីតែមួយគត់ ដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម គឺទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ *សូមមើល ដូចយោងខាងលើ* កថាខណ្ឌ ២០-២៤។

[251] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦០-៤០៧។ *សូមមើលផងដែរ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៨-៣៩ ដែលដកស្រង់ពីដីកាដំណោះស្រាយរឿងក្តី ០០៤/១ កថាខណ្ឌ ២៦-៤១។

[252] *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលប្តឹង ក.ស.ច.ស. ឱ្យទទួលពិនិត្យអង្គហេតុដែលទាក់ទងនឹងមុខដំណែង និង តួនាទីរបស់លោក មាស មុត នៅក្នុងឋានានុក្រមរបបកម្ពុជាប្រជាធិបតេយ្យ (កថាខណ្ឌ ៨១-៨៦) មន្ទីរសន្តិសុខ ស-២១

ត្រូវនៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ[253] មន្ទីរសន្តិសុខ ស-២១[254] មន្ទីរសន្តិសុខវត្តឥន្ទញាណ[255] ការដ្ឋានវាយថ្មស្ទឹងហាវ[256] ឧក្រិដ្ឋកម្មប្រព្រឹត្តដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ[257] ការបោសសំអាតកងពល ក.ប.ក.[258] ជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម[259]

---

(កថាខណ្ឌ ៤៣) មន្ទីរសន្តិសុខវត្តឥន្ទញាណ (កថាខណ្ឌ ៥៥-៥៧) ការដ្ឋានវាយថ្មស្ទឹងហាវ (កថាខណ្ឌ ៥៨) ឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តដោយទាហានជើងទឹកកម្ពុជាប្រជាធិបតេយ្យ (កថាខណ្ឌ ៥៩-៦១) ការបោសសម្អាតនៅតាមកងពលនៃ ក.ប.ក. (កថាខណ្ឌ ៥២-៥៤) និង ជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម (កថាខណ្ឌ ៦២)។ *សូមមើលផងដែរ* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ២០-២៤ ដែលប្ដឹង ក.ស.ច.ស. ឱ្យទទួលពិនិត្យអង្គហេតុបន្ថែមទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ស.ច.ស.អ. បានបញ្ចប់ការស៊ើបអង្កេតជាផ្លូវការទៅលើអង្គហេតុនានាដែលគាត់បានដកចេញ នៅក្នុងសេចក្ដីសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរពាក់ព័ន្ធនឹងការចោទប្រកាន់ទាំងអស់ដែលទាក់ទងនឹង៖ **ក.** មន្ទីរសន្តិសុខ ស-២២ **ខ.** ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង **គ.** ការដ្ឋានសម្លាប់មនុស្សស្ទឹងតូច **ឃ.** ការចូលរួមរបស់ ក.ប.ក. នៅក្នុងការបោសសម្អាតភូមិភាគកណ្ដាល ភូមិភាគឧត្តរថ្មី និង ភូមិភាគបូព៌ា ដោយដកចេញនូវការបោសសម្អាតសមាជិកនៅក្នុងកង/អង្គភាពរបស់ ក.ប.ក. ដែលមានទីតាំងនៅតំបន់ទាំងនោះ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១២-១៣។ ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ *ស្ទួន* ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១៧ ឯកសារ D226 កថាខណ្ឌ ៤, ១៣។

[253] *សូមមើល* ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៧៩ (ដែលរកឃើញថា លោក មាស មុត មិនមែនជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍) កថាខណ្ឌ ១០៨-២២ (ដែលវាយតម្លៃលើតួនាទី និង សិទ្ធិអំណាចរបស់លោក មាស មុត នៅក្នុងគណៈកម្មាធិការមជ្ឈិម) កថាខណ្ឌ ១៥៣ (ដែលរកឃើញថា លោក មាស មុត មិនស្ថិតនៅក្នុងគណៈកម្មាធិការយោធា) កថាខណ្ឌ ១៥៦-៧១ (ដែលវាយតម្លៃពីតួនាទី និង សិទ្ធិអំណាចរបស់លោក មាស មុត នៅក្នុងអគ្គសេនាធិការ) កថាខណ្ឌ ១៨៧-៨៩ (ដែលវាយតម្លៃពីតួនាទីរបស់លោក មាស មុត ក្នុងនាមជាមេបញ្ជាការកងពលធំ ១៦៤ និង ជាប្រធានគណៈកម្មាធិការក្រុងកំពង់សោម)។ *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៥០ (ដែលវាយតម្លៃពីតួនាទី និង សិទ្ធិអំណាចរបស់លោក មាស មុត នៅក្នុងគណៈកម្មាធិការមជ្ឈិម) កថាខណ្ឌ ១៥៦-៥៨ (ដែលវាយតម្លៃពីតួនាទី និង សិទ្ធិអំណាចរបស់លោក មាស មុត ក្នុងនាមជាមេបញ្ជាការកងពលធំ ១៦៤) កថាខណ្ឌ ១៥៩-៦១ (ដែលវាយតម្លៃពីតួនាទី និង សិទ្ធិអំណាចរបស់លោក មាស មុត ក្នុងនាមជាលេខាតំបន់ស្វយ័តកំពង់សោម) កថាខណ្ឌ ១៦២ (ដែលវាយតម្លៃពីតួនាទីរបស់លោក មាស មុត នៅក្នុងអគ្គសេនាធិការ)។

[254] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៦៣-៨៧។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៦៨-៦៩។

[255] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៨៨-៩៧។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤២៦-៤៣។

[256] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩៨-៣០៥។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៥៥-៤០២។

[257] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៦-២២។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ២១៧-៥៧។

[258] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២២៩-៥៨។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ២៧០-៣២៩។

[259] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២៣-២៩។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ២០៦-១០។

និង ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[260]។ ក្រៅពីដាក់ជូន ស.ច.ស. ឱ្យពិនិត្យលើអង្គហេតុទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គោលបំណងចម្បងនៃការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ យោងតាម ស.ព.អ. គឺមិនមែនដើម្បីប្តឹង ស.ច.ស. ឱ្យពិនិត្យអង្គហេតុថ្មីៗឡើយ ប៉ុន្តែគឺដើម្បី "បញ្ជាក់បំភ្លឺ" អង្គហេតុដែលគាត់បានយល់ឃើញថា ស.ច.ស. បានទទួលពិនិត្យរួចទៅហើយ[261]។

៩៥. ស.ច.ស. ទាំងពីររូប បានប្រើប្រាស់វិធីសាស្ត្រប្រមូលភស្តុតាងដូចគ្នា[262] ហើយបានវាយតម្លៃថាតើលោក មាស មុត គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ស្របតាម "គោលការណ៍ច្បាប់ដែលមានច្បាស់លាស់"[263] ផ្អែកលើកត្តាទាំងឡាយដែលពួកគាត់បានបង្កើតរួមគ្នា[264] ដោយមើលទៅលើសិទ្ធិអំណាចតាមឋានានុក្រមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការចូលរួមដោយផ្ទាល់នៅក្នុងឧក្រិដ្ឋកម្ម និង កម្រិតនៃការចូលរួមរបស់គាត់នៅក្នុងការធ្វើគោលនយោបាយ ប.ក.ក. និង/ឬអនុវត្តគោលនយោបាយទាំងនោះ[265]។

---

[260] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨២, ៩២-៩៣។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ២០០-០៥, ៤៤៥-៥៥។

[261] *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ១-២, ៦, ៧, ១០, ១២, ១៥។

[262] *សូមមើល* កថាខណ្ឌ ២២ *ខាងលើ*។

[263] *សូមមើល រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆ័ន្ទ) កថាខណ្ឌ ២១។

[264] កត្តាទាំងនេះគឺ៖ **ក.** ចេតនារបស់ភាគីនៃកិច្ចព្រមព្រៀងក្នុងការកម្រិតយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ឱ្យនៅត្រឹមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ **ខ.** គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ និង ការបកស្រាយតឹងរ៉ឹងនៃច្បាប់ព្រហ្មទណ្ឌ **គ.** ការធ្វើសេចក្តីសម្រេចនៅក្នុងរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ (ពោលគឺ កម្រិតដែលជនត្រូវចោទអាចចូលរួមចំណែក ឬ កំណត់អំពីគោលនយោបាយរបស់ ប.ក.ក. និង/ឬ ការអនុវត្តន៍គោលនយោបាយទាំងនោះ) និង **ឃ.** ស្ថានទម្ងន់នៃអំពើរបស់ជនត្រូវចោទ និង ឥទ្ធិពលនៃអំពើទាំងនោះ ដែលស្ថិតក្រោមចេតនារបស់ភាគីនៃកិច្ចព្រមព្រៀង។ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦០-៤០៧។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣២-៣៩។ *សូមមើលផងដែរ* ដីកាដំណោះស្រាយរឿងក្តី ០០៤/១ កថាខណ្ឌ ៣-៤១។ *សូមមើល* កថាខណ្ឌ ២២ *ខាងលើ*។

[265] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៨-៦៩។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៩ ដែលដកស្រង់ដីកាដំណោះស្រាយរឿងក្តី ០០៤/១ កថាខណ្ឌ ៣៨-៣៩។

៥៦. ស.ច.ស. ទាំងពីររូប បានវាយតម្លៃសិទ្ធិអំណាចរបស់លោក មាស មុត នៅក្នុងឋានានុក្រមរបប កម្ពុជាប្រជាធិបតេយ្យ[266]។ ស.ច.ស.ជ. បានរកឃើញថា ទោះបីជា លោក មាស មុត កាន់តួនាទីមួយចំនួនក៏ដោយ ក៏គាត់មិនមានអំណាចច្រើនដែរ[267] ដោយផ្តល់សំអាងហេតុថា គាត់មិនមែនជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍[268] គ្មានសិទ្ធិចូលរួមនៅក្នុងការសម្រេចចិត្តនៅក្នុងគណៈកម្មាធិការមជ្ឈិម[269] គ្មានសិទ្ធិអំណាចក្នុងការបញ្ជាឱ្យចាប់ខ្លួន និង សម្លាប់[270] និង "ស្ថិតនៅក្រោមកម្មាភិបាលប្រហែល ៥០ នាក់ និង កាន់មុខដំណែងដូចកម្មាភិបាលផ្សេងទៀតដែរ ក្នុងនោះរួមមានលេខាភូមិភាគ និង កងពល"[271] ដែលអ្នកទាំងអស់ត្រូវតែដើរតាមគោលនយោបាយរបស់ ប.ក.ក.[272]។ ស.ច.ស.អ. បានរកឃើញថា ខណៈដែលលោក មាស មុត មិនមែនជាមេដឹកនាំជាន់ខ្ពស់ គាត់ស្ថិតនៅជិតថ្នាក់ដឹកនាំជាន់ខ្ពស់ ដោយផ្តល់សំអាងហេតុថា លោក មាស មុត បានបញ្ជាកងពលធំលេខ ១៦៤ បានទទួលខុសត្រូវដែនទឹករបស់របបកម្ពុជាប្រជាធិបតេយ្យ ជាសមាជិកត្រៀមនៃគណៈកម្មាធិការសេនាធិការ និង ជាអនុប្រធានម្នាក់របស់ សុន សេន ហើយចាប់ពីចុងឆ្នាំ ១៩៧៨ មក គឺជាសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិម[273]។

៥៧. ស.ច.ស. ទាំងពីររូប បានវាយតម្លៃលើការចូលរួមរបស់លោក មាស មុត នៅក្នុងឧក្រិដ្ឋកម្ម[274]។ ខណៈដែល ស.ច.ស.ជ. បានរកឃើញថា ឧក្រិដ្ឋកម្មបានកើតមានឡើងនៅក្នុងតំបន់ទាំងឡាយដែលនៅក្រោមសិទ្ធិអំណាចរបស់លោក មាស មុត[275] ស.ច.ស.ជ. បានផ្តល់សំអាងហេតុថា ការចូលរួមរបស់លោក មាស មុត គឺ "មិនសកម្ម មិនដុំកំភួន និង មិនកៀកកិតនឹងការប្រព្រឹត្តឧក្រិដ្ឋ

---

[266] *សូមមើល* កថាខណ្ឌ ២៥, ២៩ *ខាងលើ*។

[267] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៨។

[268] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៧៩, ៤១៨។

[269] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១៨។

[270] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៦៩, ៤១៨។ *សូមមើលផងដែរ ដូចយោងខាងលើ* កថាខណ្ឌ ១២២។

[271] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១៩។

[272] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២០។

[273] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៥៥៩។

[274] *សូមមើល* កថាខណ្ឌ ២៦, ៣០ *ខាងលើ*។

[275] *សូមមើល ឧទា.* ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩៥-៩៧ (មន្ទីរសន្តិសុខវត្តឥន្ទញាណ) កថាខណ្ឌ ៣០៣-០៥ (ការដ្ឋានវាយថ្មស្ទឹងហាវ) កថាខណ្ឌ ៣០៧-២២ (ឧក្រិដ្ឋកម្មប្រព្រឹត្តដោយទាហានជើងទឹកកម្ពុជាប្រជាធិបតេយ្យនៅក្នុងដែនទឹក និង ដែនកោះកម្ពុជា)។

កម្ម” ឡើយ[276]។ ស.ច.ស.អ. បានរកឃើញថា ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មរបស់លោក មាស មុត គឺផ្តល់យុត្តិកម្មឱ្យសន្និដ្ឋានថា គាត់គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ដោយផ្តល់សំអាងហេតុថា លោក មាស មុត ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិវៀតណាម និង ការសម្លាប់រង្គាលជនជាតិថៃដែលចាប់បាន ដោយកងទ័ពជើងទឹករបស់របបកម្ពុជាប្រជាធិបតេយ្យ និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មថ្នាក់ជាតិ[277]។

៩៨. ស.ច.ស. ទាំងពីររូប បានវាយតម្លៃលើការចូលរួមរបស់លោក មាស មុត ក្នុងគោលនយោបាយរបស់ ប.ក.ក.[278]។ ស.ច.ស. បានរកឃើញថា៖ ការបង្កើតគោលនយោបាយរបស់ ប.ក.ក. និង មធ្យោបាយ ក្នុងការអនុវត្តគោលនយោបាយទាំងនោះ គឺស្ថិតនៅលើថ្នាក់ដឹកនាំកំពូល[279] សេចក្តីសម្រេចធ្វើឡើងនៅថ្នាក់កំពូល ហើយបន្ទាប់មកត្រូវបានអនុវត្តដោយថ្នាក់ក្រោមៗ ដោយមិនខ្វល់ពីផលវិបាកក្នុងការអនុវត្តបញ្ជា ឬ លទ្ធផល ដែលចេញពីការអនុវត្តបញ្ជានោះឡើយ[280] ទោះជាមានការរៀបចំកិច្ចប្រជុំជាទៀងទាត់ក៏ដោយ ក៏ការធ្វើសេចក្តីសម្រេចនៅក្នុងកម្ពុជាប្រជាធិបតេយ្យមិនអនុញ្ញាតឱ្យមាន “ការលើកយោបល់ដោយសមភាពនៅចំពោះអ្នកមុខអ្នកការនៅគ្រប់ថ្នាក់ ហើយនាំឱ្យមានការពិភាក្សាគ្នារកច្រកចេញនោះទេ”[281] ហើយគ្មាននណាម្នាក់អាចមានសុវត្ថិភាពនៅក្នុងការសន្មតថាការសន្ទនាទាក់ទងនឹងសេចក្តីណែនាំរបស់ថ្នាក់ដឹកនាំកំពូលនឹងមិនត្រូវបាន “រាយការណ៍នៅក្នុងក្រុមពាក់ព័ន្ធដែលទទួលរងនូវផលប៉ះពាល់អវិជ្ជមានមកលើខ្លួន”[282]។ ស.ច.ស.ជ. បានរកឃើញថា លោក មាស មុត បានចូលរួមនៅក្នុងការគាំទ្រ[283] និង ផ្សព្វផ្សាយគោល

---

[276] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៨។

[277] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៦២-៦៦។

[278] *សូមមើល* កថាខណ្ឌ ២៦, ៣០ *ខាងលើ*។

[279] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៨៦-៨៧។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៩ ដែលដកស្រង់ដីកាដំណោះស្រាយរឿងក្តី ០០៤/១ កថាខណ្ឌ ៤០។

[280] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៨៦។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៩ ដែលដកស្រង់ដីកាដំណោះស្រាយសំណុំរឿង ០០៤/១ កថាខណ្ឌ ៤០។

[281] ដីកាដំណោះស្រាយរឿងក្តី ០០៤/១ កថាខណ្ឌ ៤០ ដែលត្រូវបានដកស្រង់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៩។ *សូមមើលផងដែរ* ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៨៦, ៣៨៨។

[282] ដីកាដំណោះស្រាយរឿងក្តី ០០៤/១ កថាខណ្ឌ ៤១ ដែលត្រូវបានដកស្រង់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៩។ *សូមមើលផងដែរ* ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៨៨។

[283] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២២។

នយោបាយរបស់ ប.ក.ក.[284]។ ស.ច.ស.អ. បានរកឃើញថា លោក មាស មុត គឺជា "អ្នកចូលរួមប្រកបដោយឆន្ទៈស្រួចស្រាល់" ក្នុងការអនុវត្តគោលនយោបាយរបស់ ប.ក.ក.[285]។ មានតែ ស.ច.ស.ជ. ប៉ុណ្ណោះ ដែលបានវាយតម្លៃលើលទ្ធភាពរបស់លោកមាស មុត ក្នុងការបង្កើត ឬ មានឥទ្ធិពលលើគោលនយោបាយរបស់ ប.ក.ក. ឬ ការអនុវត្តគោលនយោបាយទាំងនោះ[286]។ មិនមានចំណុចណាមួយ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែល ស.ច.ស.អ. បង្ហាញឱ្យឃើញថា លោក មាស មុត បានចូលរួមក្នុងការបង្កើតគោលនយោបាយរបស់ ប.ក.ក. ដែលជាការផ្ទុយទៅនឹងភាពត្រឹមតែជាអ្នកសម្របសម្រួល ដែលគ្មានសិទ្ធិអំណាចងាកចេញពីសិទ្ធិអំណាចរបស់គាត់ដែលត្រូវបានកំណត់យ៉ាងចង្អៀតនោះឡើយ[287]។

៩៩. ស.ច.ស ទាំងពីររូប បានប្រៀបធៀបលោក មាស មុត ជាមួយជនត្រូវចោទផ្សេងទៀតនៅ អ.វ.ត.ក.[288]។ ស.ច.ស.ជ. បានរកឃើញថា ផ្ទុយពី ឌុច ដែលបានចូលរួមដោយផ្ទាល់នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម[289] បានអនុវត្ត "ការដឹកនាំដ៏មានអំណាច និង ប្រសិទ្ធភាព" ក្នុងនាមជាប្រធានមន្ទីរសន្តិសុខ ស-២១[290] និង មាន "អំណាចក្នុងការជំរុញឱ្យមានការស្លាប់ និង សម្លាប់ដោយផ្ទាល់"[291] "ការចូលរួមរបស់ លោក មាស មុត គឺមិនសកម្ម មិនដុំកំភួន និង មិនបានកៀកកិតនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម" ឡើយ[292]។ ស.ច.ស.ជ. ក៏បានរកឃើញដែរថា ចំនួនជនរងគ្រោះដែលបានរងការឈឺចាប់ដោយសារអំពើដោយផ្ទាល់របស់លោក មាស មុត "មានលក្ខណៈខុសគ្នាយ៉ាងខ្លាំង" ពីជនរងគ្រោះដោយសារអំពើផ្ទាល់របស់ ឌុច[293]។ ស.ច.ស.អ. បានរកឃើញថា មុខ

---

[284] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១៦។

[285] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៦៩។

[286] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤០៩-២០។

[287] *សូមមើល* កថាខណ្ឌ ២៩-៣០ *ខាងលើ*។

[288] *សូមមើល* កថាខណ្ឌ ២៧, ៣១ *ខាងលើ*។

[289] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៧១-៧៤។

[290] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៧១។

[291] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៧៤។

[292] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៨។

[293] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៨។

ដំណែងរបស់ មាស មុត ព្រមទាំងលក្ខណៈ និង ឥទ្ធិពលនៃអំពើរបស់គាត់ គឺលើសពី អោ អាន អ៊ឹម ចែម និង ឌុច[294]។

៦០. ស.ច.ស. ទាំងពីររូប បានថ្លែងពីសំអាងហេតុនៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន ដោយកំណត់ពីរបៀបដែលពួកគាត់បានវាយតម្លៃលើភស្តុតាង និង ឈានទៅរកការសន្និដ្ឋានផ្ទុយគ្នា[295]។ ស.ច.ស. មិនជាប់កាតព្វកិច្ច ដោយសារណារបស់ភាគី[296] មិនត្រូវបានបង្ខំឱ្យធ្វើការដូចគ្រឿងចក្រទៅលើគ្រប់ទឡ្ហីករណ៍នីមួយៗដែលបានលើកឡើង[297] ឬ តម្រូវឱ្យពិភាក្សាភស្តុតាងនីមួយៗនៅក្នុងសំណុំរឿងឡើយ[298]។ ស.ច.ស. មានឆន្ទានុសិទ្ធិ "ក្នុងការសម្រេចលើលក្ខណៈនៃការផ្តល់សំអាង

---

[294] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៦០។

[295] *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ F36 កថាខណ្ឌ ២០៧៖ "ការតម្រូវឱ្យមានសំអាងហេតុដើម្បីធានានូវភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ជានិច្ចកាល អាស្រ័យទៅលើកាលៈទេសៈជាក់លាក់នៃរឿងក្តី។ ការលើកឡើងបែបនេះពុំមែនមានន័យថា អង្គជំនុំជម្រះត្រូវតែផ្តល់ជាស្វ័យប្រវត្តិនូវសំអាងហេតុចំពោះអំណះអំណាងនីមួយៗដែលភាគីបានលើកឡើង ... និង ថា ការពុំបានអនុវត្តដូច្នោះ បានរំលោភបំពានជាស្វ័យប្រវត្តិ ទៅលើសិទ្ធិក្នុងការទទួលបានសេចក្តីសម្រេចមួយដោយមានសំអាងហេតុនោះឡើយ។ អ្វីដែលសំខាន់នោះគឺ ថាតើអង្គជំនុំជម្រះសាលាដំបូងធ្វើការវាយតម្លៃលើភស្តុតាង និង ធ្វើសេចក្តីសន្និដ្ឋានផ្នែកអង្គហេតុ និងអង្គច្បាប់ អាចយល់បានដល់កម្រិតណា" (សេចក្តីយោងខាងក្នុងត្រូវបានលុបចោល)។ *សូមមើលផងដែរ ខាងលើ* កថាខណ្ឌ ២១-៣១។

[296] វិធាន ៦៧(១)៖ "សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់។ ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាមិនចងសហចៅក្រមស៊ើបអង្កេតឡើយ"។

[297] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ F36 កថាខណ្ឌ ២០៧។ *សូមមើលផងដែរ រឿងក្តី Van de Hurk តទល់នឹង ប្រទេសហូឡង់* តុលាការ ECtHR ពាក្យសុំលេខ 16034/90 សាលក្រម ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ១៩៩៤ កថាខណ្ឌ ៦១ (តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា កាតព្វកិច្ចចេញសេចក្តីសម្រេចដែលមានសំអាងហេតុ "មិនអាចត្រូវបានយល់ថាជាការតម្រូវឱ្យផ្តល់ចម្លើយលម្អិតចំពោះគ្រប់ទឡ្ហីករណ៍ឡើយ")។

[298] *សូមមើល រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ កថាខណ្ឌ ៣០៦ (សេចក្តីពិចារណារបស់ចៅក្រម Baik និង ចៅក្រម Bauvallet) ដែលដកស្រង់ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Zigiranyirazo* សំណុំរឿងលេខ ICTR-01-73-A សាលក្រម ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៤៥។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Perišić* សំណុំរឿងលេខ IT-04-81-

ហេតុ”[299]។ ដោយហេតុថា ស.ច.ស. មានឯករាជ្យភាព និង ឋានៈស្មើគ្នា[300] ស.ច.ស.ជ. មិនត្រូវបានបង្ខំឱ្យយល់ស្របតាមកិច្ចស៊ើបសួរ ការរកឃើញអំពីអង្គហេតុ ឬ ការវិភាគតាមផ្លូវច្បាប់របស់ ស.ច.ស.អ. ឡើយ[301]។

៦១. មានតែ ស.ច.ស.អ. ប៉ុណ្ណោះ ដែលត្រូវរៀបរាប់អំពីអង្គហេតុ និង កំណត់ប្រភេទបទល្មើសជាមួយនឹងបទប្បញ្ញត្តិព្រហ្មទណ្ឌដែលពាក់ព័ន្ធ និង ប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់លោក មាស មុត ដូចដែលតម្រូវសម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយវិធាន ៦៧(២)[302]។ វិធានផ្ទៃក្នុងមិនតម្រូវឱ្យមានភាពលម្អិតក្នុងកម្រិតដូចគ្នា សម្រាប់ដីកាលើកលែងចោទប្រកាន់

---

A សាលក្រម ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៩២។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krajišnik* សំណុំរឿងលេខ IT-00-39-A សាលក្រម ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០០៩ កថាខណ្ឌ ១៩។

[299] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ៦៧១។

[300] កិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ចែងឱ្យមាន ស.ច.ស. ពីររូបគឺ ចៅក្រមជាតិមួយរូប និង ចៅក្រមអន្តរជាតិមួយរូបដែល “មានឋានៈស្មើគ្នា”។ មាត្រា ៥(១) នៃកិច្ចព្រមព្រៀង។ មាត្រា ២៧ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[301] *សូមមើល* សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ប្រតិចារឹកសំណុំរឿង ០០២ ចូលទៅក្នុងសំណុំរឿង ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D53/2 កថាខណ្ឌ ៥៖ “យោងតាមវិធានផ្ទៃក្នុង ៦៦(១) សហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិសម្រេចដោយឯករាជ្យថាតើនៅពេលណាដែលខ្លួនយល់ឃើញថា ការស៊ើបអង្កេតត្រូវបានបញ្ចប់” (សេចក្តីយោងខាងក្នុងត្រូវបានលុបចោល)។

[302] វិធាន ៦៧(២) តម្រូវថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ “ត្រូវបញ្ជាក់អំពី ... ការបង្ហាញអំពីអង្គហេតុ និង ការកំណត់ប្រភេទបទល្មើស ... ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និង ប្រភេទនៃទទួលខុសត្រូវព្រហ្មទណ្ឌ បើពុំនោះសោត ដីកានេះត្រូវចាត់ទុកជាមោឃៈដោយកំហុសនីតិវិធី”។ *សូមមើលផងដែរ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៧០-៥៧៧ ដែលនៅក្នុងនោះ ស.ច.ស.អ. បានកំណត់ប្រភេទបទល្មើស និង ទម្រង់នៃការទទួលខុសត្រូវ។ *សូមមើលផងដែរ* មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ មាត្រា ១៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ។ យោងតាមមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ “ត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និង ឈ្មោះបទល្មើសតាមច្បាប់”។ យោងតាមមាត្រា ១៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវទុកជាមោឃៈដោយមានកំហុសនីតិវិធីប្រសិនបើមិនមានការរៀបរាប់ពីអង្គហេតុសម្ភារៈដែលជនត្រូវចោទត្រូវបានបញ្ជូនទៅជំនុំជម្រះ ការកំណត់ប្រភេទបទល្មើស និង អត្តសញ្ញាណរបស់ជនជាប់ចោទ [« L’ordonnance de mise en accusation contient, à peine de nullité, l’exposé et la qualification légale des fait[s], objet[s] de l’accusation, et précise l’identité de l’accusé. »]។

ឡើយ[303]។ គោលបំណងនៃលក្ខខណ្ឌតម្រូវស្មុគស្មាញជាងនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺដើម្បីការពារសិទ្ធិជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ នៅពេលដែលរឿងក្តីបន្តកិច្ចដំណើរការនីតិវិធីទៅជំនុំជម្រះ ពោលគឺ ដើម្បី "ជូនដំណឹងដល់ [ជនជាប់ចោទ] ឱ្យបានច្បាស់លាស់អំពីបទចោទមកលើគាត់ ដើម្បីអាចឱ្យគាត់រៀបចំខ្លួនការពារក្តី"[304] និង ដោយសារថាបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានអាននៅពេលបើកសវនាការ[305]។ ការការពារបែបនេះពុំចាំបាច់ឡើយ នៅក្នុងករណីលើកលែងចោទប្រកាន់។ អ.ប.ជ. បានសម្រេចដោយមានកំហុសនៅក្នុងរឿងក្តី ០០៤/១ ថា ដីកាលើកលែងចោទប្រកាន់ត្រូវមានការរកឃើញទាក់ទងនឹង

---

303 យោងតាមវិធាន ៦៧(៣) ស.ច.ស. ត្រូវចេញដីកាលើកលែងចោទប្រកាន់ក្នុងករណីដូចខាងក្រោម "ក-អំពើដែលចោទប្រកាន់មិនរាប់ចូលជាបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ។ ខ-ជនប្រព្រឹត្តបទឧក្រិដ្ឋនោះមិនទាន់កំណត់អត្តសញ្ញាណនៅឡើយ ឬ គ-ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ"។ វិធាន ៦៧(៣) មិនតម្រូវឱ្យកំណត់ប្រភេទបទល្មើសនៃអង្គហេតុសម្ភារៈទេ។ *សូមមើលផងដែរ* មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ មាត្រា ១៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។ យោងតាមមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់ ប្រសិនបើ៖ "១-អំពើប្រព្រឹត្តិមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ។ ២-ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់។ [ឬ] ៣-គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ"។ ក្រោមមាត្រា ១៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់ ប្រសិនបើ៖ **ក.** អង្គហេតុមិនបង្កើតជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ។ **ខ.** ចារីនៅតែគេមិនស្គាល់។ ឬ **គ.** គ្មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកជនត្រូវចោទ [« Si le juge d'instruction estime que les faits ne constituent ni crime, ni délit, ni contravention, ou si l'auteur est resté inconnu, ou s'il n'existe pas de charges suffisantes contre la personne mise en examen, il déclare, par une ordonnance, qu'il n'y a lieu à suivre. »]។

304 *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០២) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ ៤៧។

305 វិធាន ៨៩*ស្ទួន*(១)៖ "ប្រធានអង្គជំនុំជម្រះសាលាដំបូង ប្រកាសបើកសវនាការលើអង្គសេចក្តី។ ប្រធានអង្គជំនុំជម្រះសាលាដំបូង បង្គាប់អោយក្រឡាបញ្ជីអានបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ និង អាចបង្គាប់ អោយក្រឡាបញ្ជី អាននូវការវិភាគអង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"។ *សូមមើលផងដែរ* មាត្រា ៣២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។ យោងតាមមាត្រា ៣២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ប្រធានសាលាដំបូងព្រហ្មទណ្ឌ អានសេចក្តីសង្ខេបនៃបទចោទដាក់បន្ទុកជនជាប់ចោទ ដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ [« Le président de la cour d'assises présente, de façon concise, les faits reprochés à l'accusé tels qu'ils résultent de la décision de renvoi. »]។

អត្ថិភាពនៃបទល្មើស និង ភវនីយភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនត្រូវចោទ[306]។ ប្រសិនបើអ្នកព្រាងវិធានផ្ទៃក្នុងមានបំណងចង់ឱ្យ វិធានអនុវត្តចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចទៅនឹងវិធានអនុវត្តចំពោះដីកាលើកលែងចោទប្រកាន់នោះ ពួកគេគួរតែបានប្រើពាក្យសរុប "ដីកាដំណោះស្រាយ" នៅក្នុងវិធានផ្ទៃក្នុងទាំងមូល ជាជាងប្រើពាក្យ "ដីកាលើកលែងចោទប្រកាន់" និង "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ដែលមានការកំណត់និយមន័យផ្សេងគ្នានៅក្នុងសទ្ទានុក្រម[307]។

**៣. ក្នុងករណីគ្មានកំហុស ឬ ការរំលោភបំពានដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ ស.ច.ស.ជ. ដែលអាចរារាំងការអនុវត្តគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ ដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ**

៦២. មុនពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ស.ច.ស.អ. បានដឹងថា សហសេវិករបស់គាត់ គឺ ស.ច.ស.ជ. អាចចេញដីកាលើកលែងចោទប្រកាន់[308]។ តាមតែអាចដឹងបាន ស.ច.ស. ក្នុងភាព

---

[306] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆ័ន្ទ) កថាខណ្ឌ ២៦។

[307] *សូមមើល* សទ្ទានុក្រមនៃវិធានផ្ទៃក្នុង។ ពាក្យថា៖ ""ដីកាសម្រេចលើកលែងចោទប្រកាន់" ... សំដៅលើដីកាដំណោះស្រាយដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើកលែងចោទប្រកាន់ចំពោះជនត្រូវចោទ"។ ""ដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ... សំដៅលើដីកាដំណោះស្រាយដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ បញ្ជូនជនត្រូវចោទទៅជំនុំជម្រះ"។ *សូមមើលផងដែរ* វិធាន ៦៧(៣), ៦៧(៥), ៦៩(២)(ខ), ៧០, ៧៦(៤)(ច), ៧៦(១៥) ដែលទាក់ទងនឹង "ដីកាសម្រេចលើកលែងចោទប្រកាន់" និង វិធាន ២៩(៣), ៦៧(២), ៦៨(២), ៦៩(២)(ក), ៧៧(១៣)(ក)-(ខ), ៧៩(១)-(២), ៨០(១), ៨០(៣)(ក)(ii), ៨៧(៦), ៨៩(១)(គ), ៨៩*ស្ទួន*(១), ៨៩*ស្ទួនពីរ*(១), ៨៩*ស្ទួនបី*(១), ៩៨(២), ៩៨(៦) ដែលទាក់ទងនឹង "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ"។

[308] មុនពេលចេញដីកាដំណោះស្រាយ ស.ច.ស. បានចុះបញ្ជីករណីខ្វែងយោបល់មួយពាក់ព័ន្ធនឹងការចេញដីកាដំណោះស្រាយផ្ទុយគ្នាដែលតម្រូវឱ្យចៅក្រមទាំងពីររូបលើកឡើងពី "លក្ខណៈពិតប្រាកដ" នៃករណីខ្វែងយោបល់នោះ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ២៧។ វិធាន ៧២(១)៖ "ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតណាម្នាក់ ឬ ទាំងពីរអាចធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដនៃការខ្វែងយោបល់គ្នានេះដោយមានហត្ថលេខា និង ចុះកាលបរិច្ឆេទដែលត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដោយឡែក ដែលរក្សាទុកដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត"។

ជាសហសេវិក និង ភាពសុទ្ធចិត្ត អាចបានពិភាក្សាអំពីទស្សនៈផ្ទុយគ្នាលើយុត្តាធិការបុគ្គល[309] នៅមុនពេលធ្វើកំណត់ហេតុពី "លក្ខណៈពិតប្រាកដ" នៃការខ្វែងគំនិតគ្នារបស់ពួកគេ[310]។ ស.ច.ស. អាចបានបន្តពិភាក្សា និង "ស្វែងរកការឯកភាពគ្នា" ក្រោយពីធ្វើកំណត់ហេតុខ្វែងយោបល់គ្នា ដូចដែលតម្រូវដោយវិធាន ៧២(៣)។ ដោយហេតុថា **ក.** ស.ច.ស. បានចុះកំណត់ហេតុខ្វែងយោបល់គ្នា និង អាចបានបន្តការពិភាក្សាគ្នាអំពីការខ្វែងយោបល់គ្នានោះ **ខ.** ស.ច.ស.ជ. បានរក្សាជំហរថា កិច្ចស៊ើបសួរត្រូវបានបញ្ចប់នៅឆ្នាំ ២០១១ នៅពេលដែលគាត់ និង ស.ច.ស.អ. Blunk បានព្រាងដីកាបញ្ជូនរឿងទៅពិនិត្យ[311] **គ.** ស.ច.ស. ទាំងពីររូប បានចូលពិនិត្យសំណុំរឿងដូចគ្នា **ឃ.** ស.ច.ស. ទាំងពីររូបបានសហការគ្នាលើបញ្ហាសំខាន់ៗ[312] **ង.** ស.ច.ស. បានយល់ស្របលើកត្តានានា សម្រាប់កំណត់យុត្តាធិការបុគ្គល (ក្នុងនោះរួមមានគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ)[313] វិធីសាស្ត្រប្រមូលភស្តុតាង[314] និង ការកំណត់និយម

---

[309] *សូមមើល* វិធាន ៧២(៣)។ ស.ច.ស.ជ. បានពិគ្រោះយោបល់ជាមួយសមភាគីបរទេសក្នុងអំឡុងពេលកិច្ចស៊ើបអង្កេតក្នុងរឿងក្តី ០០៣។ សូម្បីតែនៅពេលដែល ស.ច.ស.អ.ប. Kasper-Ansermet មិនទទួលបានការតែងតាំងជាផ្លូវការជា ស.ច.ស.អ. ក៏ដោយ ក៏ ស.ច.ស.ជ. បានពិគ្រោះយោបល់ជាមួយគាត់ដែរ ដោយជូនដំណឹងដល់គាត់ថា ដំបូងគាត់ត្រូវរង់ចាំការតែងតាំងជាចៅក្រមស៊ើបអង្កេតជាផ្លូវការជាមុនសិន ទើប ស.ច.ស.ជ. អាច "ពិភាក្សាអំពីសំណុំរឿង ឬ ធ្វើចំណាត់ការនីតិវិធីណាមួយ" ជាមួយគាត់បាន។ ក្រោយពេល ស.ច.ស.អ. Harmon ចូលកាន់ដំណែង ស.ច.ស.ជ. បានទទួលស្គាល់គាត់ថាមាន "នីតិសម្បទាគ្រប់គ្រាន់" ហើយសហចៅក្រមទាំងពីររូបបានចុះបញ្ជីរួមគ្នានូវករណីខ្វែងយោបល់ផ្ទៃក្នុងមួយ។ *សូមមើល* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក. *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតជាតិ* ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១២ គេហទំព័រ៖ https://www.eccc.gov.kh/km/articles/17495។ សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក. *សេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងរឿងក្តី ០០៣* ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០១៣ គេហទំព័រ៖ https://www.eccc.gov.kh/km/articles/secktiiprkaas-rps-shcaukrm-soepqngket-daakdng-nyng-smnnumryang-003។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ប្រតិចារឹកសំណុំរឿង ០០២ ចូលទៅក្នុងសំណុំរឿង ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D53/2 កថាខណ្ឌ ១០។ *សូមមើលផងដែរ* ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២, ៤៤។

[310] *សូមមើល* មាត្រា ៥(៤), ៧(១) នៃកិច្ចព្រមព្រៀង។ វិធាន ៧២(១)។

[311] *សូមមើល* ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៥៩។ សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក. *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតជាតិ* ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១២ គេហទំព័រ៖ https://www.eccc.gov.kh/km/articles/17495។

[312] *សូមមើល ឧទា.* សំណើសុំមតិយោបល់ អំពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D249។

[313] *សូមមើល* កថាខណ្ឌ ២១ *ខាងលើ*។

[314] *សូមមើល* កថាខណ្ឌ ២១ *ខាងលើ*។

ន័យបទល្មើស និង ទម្រង់នៃការទទួលខុសត្រូវ[315] ជាការសមហេតុផលដែល ស.ច.ស.អ. អាចមានលទ្ធភាពវាយតម្លៃលើរបៀបដែល ស.ច.ស.ជ. បកស្រាយពាក្យថាទទួលខុសត្រូវខ្ពស់បំផុតដែលអាចនាំឱ្យមានការសន្និដ្ឋានផ្ទុយគ្នាលើយុត្តាធិការបុគ្គលលើលោក មាស មុត។

៦៣. ខណៈដែលវាមិនមែនជាភារកិច្ចរបស់ ស.ច.ស.អ. ក្នុងការពិនិត្យ និង វាយតម្លៃលើការរកឃើញអង្គហេតុរបស់ ស.ច.ស.ជ. និង ការសន្និដ្ឋានអង្គច្បាប់ដែលនាំដល់ការចេញដីកាសម្រេចលើកលែងចោទប្រកាន់ តាមរយៈការស្នើថា បើគ្មានសំឡេងភាគច្រើនលើសលប់នៅ អ.ប.ជ. ដីកាដំណោះស្រាយទាំងពីរ ឬ មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ប៉ុណ្ណោះ ដែលមានអានុភាពអនុវត្ត[316] ស.ច.ស.អ. បង្កប់ន័យដោយមិនសមហេតុផលថា គោលការណ៍វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនត្រូវចោទ គឺគ្មានផលវិបាកនៅក្នុងករណីនេះទេ ដោយស្នើថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ មានអានុភាពខ្ពស់ជាងដីកាសម្រេចលើកលែងចោទប្រកាន់ ឬ ថាដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសណាមួយ។ ក្រៅពីការណ៍ដែលថា ស.ច.ស.អ. មិនបានបង្ហាញឱ្យឃើញថា គាត់បានវិភាគលើសុពលភាពនៃការស៊ើបអង្កេត ការវាយតម្លៃលើអង្គហេតុ ការយកច្បាប់មកអនុវត្ត ឬ ដីកាសម្រេចលើកលែងចោទប្រកាន់របស់ ស.ច.ស.ជ. គាត់មិនមានសិទ្ធិអំណាចបែបនេះទេ។ មានតែ អ.ប.ជ. តែប៉ុណ្ណោះ ដែលអាចពិនិត្យលើការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ ស.ច.ស. នៅក្នុងការធ្វើសេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គលបាន[317]។

---

[315] *សូមមើល* ដីកាដំណោះស្រាយរឿងក្តី ០០៤/១ កថាខណ្ឌ ៤២-១០២។

[316] នៅក្នុងប្រវត្តិនីតិវិធីនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួន ស.ច.ស.អ. បានបញ្ចូលមតិយោបល់របស់ ស.ច.ស. ដែលថាដីកាដំណោះស្រាយទាំងពីរ "មានអានុភាពអនុវត្ត" នៅក្រោមវិធាន ៧៧(១៣) ដោយបានដកស្រង់ដីកាសម្រេចមួយដែលពួកគាត់បានជូនដំណឹងដល់ភាគីអំពីផលវិបាកដែលអាចមាន ចំពោះកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ ដោយសារការចេញដីកាដំណោះស្រាយផ្ទុយគ្នា។ *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៩ ជើងទំព័រលេខ ២៦ ដែលដកស្រង់ *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D262.2 កថាខណ្ឌ ១៦។ ផ្ទុយទៅវិញ នៅក្នុងផ្នែកនេះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួនទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន ស.ច.ស.អ. បានពិចារណាឃើញថា វា "មិនច្បាស់" ថាតើ ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួននឹងមានអនុភាពអនុវត្ត អនុលោមតាមវិធាន ៧៧ (១៣) ឬយ៉ាងណា។ *សូមមើល ដូចយោងខាងលើ* កថាខណ្ឌ ៥៧៩។

[317] *សូមមើល* កថាខណ្ឌ ៦-១០ *ខាងលើ*។

៦៤. ស.ច.ស.អ. បានយល់ឃើញថា ស.ច.ស. "មានការវាយតម្លៃទូលំទូលាយក្នុងការកំណត់យុត្តាធិការ ហើយការវាយតម្លៃនេះអាចត្រួតពិនិត្យឡើងវិញបានតែក្នុងករណីដែលមានការរំលោភបំពានប៉ុណ្ណោះ"[318]។ ក្នុងករណីគ្មានកំហុស ឬ ការរំលោភបំពានអំណាចឆន្ទានុសិទ្ធិដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ ស.ច.ស. ណាម្នាក់ ការស៊ើបអង្កេត ការវាយតម្លៃលើអង្គហេតុ ការយកច្បាប់មកអនុវត្ត ឬ ការចេញដីកាដំណោះស្រាយរបស់ ស.ច.ស. ម្នាក់មិនមានអានុភាពខ្ពស់ជាង ឬ ទាបជាងការស៊ើបអង្កេត ការវាយតម្លៃលើអង្គហេតុ ការយកច្បាប់មកអនុវត្ត ឬ ការចេញដីកាដំណោះស្រាយរបស់ ស.ច.ស. ម្នាក់ទៀតឡើយ[319]។ គ្រាន់តែដោយសារ អ.ប.ជ. មិនយល់ស្របជាមួយការរកឃើញផ្នែកអង្គហេតុ ឬ សេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គលរបស់ ស.ច.ស. ណាម្នាក់ មិនមែនមានន័យថា អង្គជំនុំជម្រះអាចផាត់ចោលសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិរបស់ ស.ច.ស. ឡើយ[320]។ ដើម្បីអាចឱ្យ អ.ប.ជ. ផាត់ចោលដីកាសម្រេចលើកលែងចោទប្រកាន់ អ.ប.ជ. ត្រូវរកឱ្យឃើញថា ស.ច.ស.ជ. បានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដោយផ្អែកលើកំហុសអង្គច្បាប់ "ដែលនាំឱ្យសេចក្តីសម្រេចនោះគ្មានសុពលភាព" កំហុសអង្គហេតុ "ដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌" ឬ ថា ដីកាលើកលែងចោទប្រកាន់របស់គាត់ "មិនយុត្តិធម៌ ឬមិនសមហេតុផល" ដែលបង្កើតបានជាការរំលោភបំពានឆន្ទានុសិទ្ធិ[321]។ និយាយម្យ៉ាងទៀត អ.ប.ជ. ត្រូវតែរកសំឡេងភាគច្រើនលើសលប់ដែលរកឃើញថា ស.ច.ស.ជ. បាន

---

[318] ដីកាសម្រេចរួមលើសំណើរបស់ មាស មុត ស្តីពីយុត្តាធិការបុគ្គល ចុះថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D181 កថាខណ្ឌ ២៩។

[319] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆ័ន្ទ) កថាខណ្ឌ ២១ (ដែលសម្រេចថា សេចក្តីសម្រេចតាមឆន្ទានុសិទ្ធិរបស់ ស.ច.ស. អាចត្រូវបានបដិសេធចោល នៅពេលដែលសេចក្តីសម្រេចទាំងនោះផ្អែកទៅលើកំហុសអង្គច្បាប់ ដែលធ្វើឱ្យសេចក្តីសម្រេចនោះគ្មានសុពលភាព ផ្អែកលើកំហុសអង្គហេតុដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌ និង/ឬ សេចក្តីសម្រេចរបស់ខ្លួន "មានភាពអយុត្តិធម៌ ឬ មិនសមហេតុសមផល" ដែលជាការបំពានលើឆន្ទានុសិទ្ធិ)។

[320] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆ័ន្ទ) កថាខណ្ឌ ២១។

[321] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆ័ន្ទ) កថាខណ្ឌ ២១។

ប្រព្រឹត្តកំហុស ឬ ការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិ ក្នុងការសន្និដ្ឋានថា លោក មាស មុត មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុត[322]។ ក្នុងករណីដែលរកមិនឃើញបែបនេះ ត្រូវអនុវត្តគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ។ បើទោះបីជា ដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវផាត់ចោលដោយមតិភាគច្រើនលើសលប់ក៏ដោយ ក៏ អ.ប.ជ. នៅតែចាំបាច់ត្រូវតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយសំឡេងភាគច្រើនលើសលប់ដដែល ហើយសម្រេចថា រឿងក្តីគួរបន្តទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ[323]។

៦៥. ស.ច.ស.ជ. មិនបានប្រព្រឹត្តកំហុស ឬ ការរំលោភបំពានដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិក្នុងការស៊ើបអង្កេតលើលោក មាស មុត ការធ្វើសេចក្តីសម្រេចលើយុត្តាធិការបុគ្គលរបស់គាត់ និង ការធ្វើសេចក្តីព្រាងដីកាលើកលែងចោទប្រកាន់នោះឡើយ។ គាត់បានស៊ើបអង្កេត វាយតម្លៃ និង កំណត់អង្គហេតុនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ព្រមទាំងបញ្ជាក់ច្បាស់ពីសំអាងហេតុរបស់គាត់ថាហេតុអ្វីបានជាគាត់រកឃើញថា លោក មាស មុត មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក.[324] ដោយប្រើកត្តាដូចគ្នាក្នុងការវាយតម្លៃយុត្តាធិការបុគ្គល និង វិធីសាស្ត្រភស្តុតាងដូចនឹង ស.ច.ស.អ.

---

[322] ដូចដែល អ.ប.ជ. បានសម្រេចថា "មិនមែនគ្រប់កំហុសទាំងអស់នឹងនាំឱ្យខ្លួនបដិសេធចោលសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតឡើយ"។ *សូមមើល* *រឿងក្តី ខួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៦២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ" ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១០ ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D353/2/3 កថាខណ្ឌ ៨។ *រឿងក្តី ខួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៦៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូ នៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ A371/2/12 កថាខណ្ឌ ២២។ *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២១។

[323] *សូមមើល* កថាខណ្ឌ ៤៦ *ខាងលើ*។

[324] *សូមមើល* កថាខណ្ឌ ២២, ២៤-២៧, ៥៤-៦០ *ខាងលើ*។

ដែរ[325]។ តាមគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ ភាពមន្ទិលសង្ស័យ ទាំងចំពោះអង្គហេតុ និង ការបកស្រាយច្បាប់ ដែលក្នុងនោះរួមមានការកម្រិតយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ត្រូវតែដោះស្រាយជាប្រយោជន៍ដល់លោក មាស មុត[326]។ ដោយគិតពី "ភាពបត់បែន" នៃពាក្យថា ទទួលខុសត្រូវខ្ពស់បំផុត[327] ផលវិបាកនៃការសន្និដ្ឋានមិនត្រឹមត្រូវរបស់ ស.ច.ស.អ. ដែលថា ដីកាដំណោះស្រាយទាំងពីរត្រូវតម្កល់ទុកជាបានការ (ជាស្ថានភាពមួយដែល ស.ច.ស. ទាំងពីរបានពិចារណាថាមិនស្របទៅនឹងតម្រូវការជាមូលដ្ឋាននៃនីតិរដ្ឋ)[328] ហើយផលវិបាកនៃការសន្និដ្ឋានមិនត្រឹមត្រូវរបស់ ស.ច.ស.អ. ដែលថា មានតែដីកាចោទប្រកាន់របស់គាត់ប៉ុណ្ណោះដែលមានអានុភាពអនុវត្ត(ជាការរំលោភលើរដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខ័ណ្ឌ អ.វ.ត.ក.)[329] គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ ត្រូវតែយកមកដោះស្រាយបណ្តឹងឧទ្ធរណ៍នេះ។

### ៤. សេចក្តីសន្និដ្ឋាន

៦៦. ក្នុងការស្នើឡើងដោយមិនសមហេតុផលថា ដីកាដំណោះស្រាយទាំងពីរ ឬ មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់តែមួយប៉ុណ្ណោះ ដែលមានអានុភាពអនុវត្ត នៅពេលគ្មានសំឡេងភាគច្រើនលើសលប់នៅ អ.ប.ជ. ស.ច.ស.អ. មានកំហុសអង្គច្បាប់ដោយខកខានមិនបានសន្និដ្ឋានថាប្រសិនបើ អ.ប.ជ. មិនអាចសម្រេចដោយសំឡេងភាគច្រើនលើសលប់ថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស ឬ ការរំលោភបំពានដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់គាត់ទេនោះ ដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំ

---

[325] *សូមមើល* កថាខណ្ឌ ២២ *ខាងលើ*។

[326] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(០៤) សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១។ *សូមមើលផងដែរ* កថាខណ្ឌ ៥០-៥១ *ខាងលើ*។

[327] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 កថាខណ្ឌ ២១។

[328] សំណើសុំមតិយោបល់ អំពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D249 កថាខណ្ឌ ៥៤។

[329] *សូមមើល* កថាខណ្ឌ ៤៥-៤៦ *ខាងលើ*។

ជម្រះ អនុលោមតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ*។ ការសន្និដ្ឋានដែលមិនអាចពន្យល់បានរបស់ ស.ច.ស.អ. ដាក់ដីកាសម្រេចលើកលែងចោទប្រកាន់ឱ្យនៅក្រោមដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ មិនគោរពគោលការណ៍ជាមូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខ័ណ្ឌ អ.វ.ត.ក. ដែលកំណត់ថា ភាពមន្ទិលសង្ស័យទាំងអស់ត្រូវតែដោះស្រាយជាប្រយោជន៍ដល់លោក មាស មុត។ ស.ច.ស. ទាំងពីររូបបានធ្វើអ្វីតាមការតម្រូវក្នុងការស៊ើបអង្កេត និង ព្រាងដីកាដំណោះស្រាយ។ គំនិតសមហេតុផលចំនួនពីរអាចបង្កើតដោយសមហេតុផល នូវសេចក្តីសន្និដ្ឋានដែលមិនស្របគ្នា ផ្អែកលើការវាយតម្លៃដោយឯករាជ្យភាពទៅលើអង្គហេតុ។ ចំណោទចំពោះមុខ អ.ប.ជ. គឺមិនមែនថា តើខ្លួនយល់ស្របនឹងសេចក្តីសន្និដ្ឋានរបស់ ស.ច.ស. ម្នាក់ណានោះទេ ប៉ុន្តែថាតើ ស.ច.ស. បានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនត្រឹមត្រូវតាមច្បាប់ឬយ៉ាងណា។ គ្រាន់តែដោយសារ អ.ប.ជ. មិនយល់ស្របនឹងការរកឃើញ ឬ សេចក្តីសន្និដ្ឋានរបស់ ស.ច.ស. ណាម្នាក់ មិនមានន័យថា អ.ប.ជ. អាចជំនួសការយល់ឃើញរបស់ខ្លួនឡើយ។ ក្នុងករណីគ្មានការសម្រេចមួយដោយសំឡេងភាគច្រើនលើសលប់ថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស ឬ ការរំលោភបំពានដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ដែលអាចរារាំងដល់ការអនុវត្តគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ ពោលគឺគ្មានចំណុចណាមួយមានអត្ថិភាពនោះ ដីកាសម្រេចលើកលែងចោទប្រកាន់មិនអាចត្រូវបានផាត់ចោលឡើយ។ អ.ប.ជ. គួរសម្រេចថា ស.ច.ស.អ. មានកំហុសអង្គច្បាប់ដែលស្នើថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់មានអានុភាពខ្ពស់ជាង ដោយមិនបានផ្តល់ហេតុផលបដិសេធដីកាសម្រេចលើកលែងចោទប្រកាន់។ ដោយមាន ស.ច.ស. ចំនួនពីររូប មានឋានៈស្មើគ្នា និង មានឯករាជ្យភាព ចេញដីកាដំណោះស្រាយដែលមានអានុភាពគតិយុត្តស្មើគ្នា ដីកាដំណោះស្រាយដែលស្នើឱ្យលើកលែងការចោទប្រកាន់ មានអានុភាពលើដីកាដំណោះស្រាយដែលស្នើឱ្យមានការបញ្ជូនរឿងទៅជំនុំជម្រះ។

## V. សេចក្តីសន្និដ្ឋាន និង ដំណោះស្រាយដែលស្នើសុំ

៦៧. ផ្ទុយទៅនឹងសេចក្តីថ្លែងការណ៍ដ៏មិនសមរម្យរបស់ Benedict Carpzov ដែលថា "នៅក្នុងរឿងក្តីជំនុំជម្រះលើបទល្មើសធ្ងន់ធ្ងរបំផុត ព្រំដែននៃច្បាប់អាចត្រូវបានច្រានចោល ដោយសារលក្ខណៈ

ព្រៃផ្សៃនៃឧក្រិដ្ឋកម្ម”[330] ឥឡូវនេះមិនមែនជាពេលសម្រាប់ អ.ប.ជ. មិនគោរពខ្លឹមសារ និង ស្មារតីនៃកិច្ចព្រមព្រៀងឡើយ។ ក្របខ័ណ្ឌ អ.វ.ត.ក. គឺជាលទ្ធផលនៃការចរចាដ៏យូរអង្វែង សេចក្តីសម្រេចចិត្តដែលមានការគិតគូរ និង ពិចារណា និង បទប្បញ្ញត្តិដែលប្រើពាក្យពេចន៍ដោយប្រុងប្រយ័ត្ន។ អស់រយៈពេលជិតបួនឆ្នាំ ភាគីនៃកិច្ចព្រមព្រៀងបានពិភាក្សា ខ្វែងគំនិតគ្នា និង ប្តេជ្ញាចិត្តលើជំហររៀងៗខ្លួន មុនពេលសម្រេចឯកភាពគ្នាថា៖ “មានតែមនុស្សមួយក្រុមតូចប៉ុណ្ណោះ ដែលនឹងត្រូវកាត់សេចក្តីនៅក្នុងតុលាការកម្ពុជា សម្រាប់អំពើឃោរឃៅដែលបានកើតឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ”[331] ពោលគឺ មេដឹកនាំជាន់ខ្ពស់ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទូទាំងប្រទេសកម្ពុជា ក្នុងអំឡុងថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ ១៩៧៩[332]។ ខណៈដែលវាអាចជាការមិនពេញចិត្តសម្រាប់មនុស្សមួយចំនួន ដែលមិនមែនជនទាំងអស់ដែលបានចូលរួមនៅក្នុងឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនឹងត្រូវកាត់សេចក្តីនោះ កិច្ចព្រមព្រៀងឆ្លុះបញ្ចាំងនូវជម្រើសនយោបាយដោយមានមនសិការ ដែលថ្លឹងថ្លែងរវាង *សន្តិភាព និង យុត្តិធម៌*៖ “សមាហរណកម្មខ្មែរក្រហមដែលនៅសេសសល់ ចូលមករួមរស់ក្នុងសង្គមជាតិកម្ពុជា ជាមួយនឹងគោលបំណងចង់បានការបញ្ចប់តាមផ្លូវតុលាការសម្រាប់ការឈឺចាប់ខ្លោចផ្សារបស់ជនរងគ្រោះ”[333]។

៦៨. ដោយមានរចនាសម្ព័ន្ធ “សហ” ដែលមានការចរចាដ៏ពិសេស ចែងឱ្យ ស.ច.ស. មានឋានៈស្មើគ្នា និង សិទ្ធិអំណាចឯករាជ្យលើការស៊ើបអង្កេត គេរំពឹងទុកថា ការខ្វែងយោបល់គ្នាអាចកើតឡើងទៅលើការកម្រិតយុត្តាធិការរបស់ អ.វ.ត.ក.។ ជាលទ្ធផល យន្តការដោះស្រាយវិវាទត្រូវបានបង្កើតឡើង ដើម្បីធានាថា ការស៊ើបអង្កេតលើជនសង្ស័យនឹងមិនត្រូវបានជាប់គាំង ដោយភាពទាល់ច្រករវាង ស.ច.ស.៖ ក្នុងករណីខ្វែងយោបល់គ្នា ការស៊ើបសួរនឹងត្រូវបន្ត។ ប៉ុន្តែនៅពេលបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួន ស.ច.ស. ត្រូវបានផ្តល់សិទ្ធិអំណាចឆន្ទានុសិទ្ធិដ៏ទូលំទូលាយ ក្នុងការបង្ហាញអំពីទស្សនៈផ្ទាល់របស់ខ្លួននៅក្នុងដីកាដំណោះស្រាយ។ ការណ៍ដែលថា ស.ច.ស. ម្នាក់អាចបញ្ជូន

[330] *Notissimum est, quod in delictis atrocissimis propter criminis enormitatem jura transgredi liceat.* Benedict Carpzov, Practica nova imperalis Saxonica rerum criminalium, 1652, Pars III, Quaestio C II ត្រូវបានដកស្រង់នៅក្នុងដីកាដំណោះស្រាយរឿងក្តី ០០៤/១ កថាខណ្ឌ ៣០។

[331] ដីកាដំណោះស្រាយរឿងក្តី ០០៤/១ កថាខណ្ឌ ៣១។

[332] មាត្រា ១, ២(១) នៃកិច្ចព្រមព្រៀង។ មាត្រា ១, ២ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[333] ដីកាដំណោះស្រាយរឿងក្តី ០០៤/១ កថាខណ្ឌ ៣២។

រឿងក្តីទៅជំនុំជម្រះ នៅពេលដែល ស.ច.ស. ម្នាក់ទៀតអាចនឹងលើកលែងការចោទប្រកាន់ គឺត្រូវបានប្រមើលមើលឃើញជាមុនរួចហើយ។ ភាគីនៃកិច្ចព្រមព្រៀងមិនដែលបានចែង ឬ ចៅក្រមដែលធ្វើសេចក្តីព្រាងវិធានផ្ទៃក្នុង ក៏មិនដែលបានចែងថា រឿងក្តីអាចបន្តទៅដំណាក់កាលជំនុំជម្រះដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលដែលដីកាលើកលែងចោទប្រកាន់ត្រូវបានចេញដំណាលគ្នានោះឡើយ។ ក្នុងកំឡុងពេលមួយទសវត្សរ៍នៃការចរចាលើច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. កិច្ចព្រមព្រៀង និង ចុងក្រោយបំផុត វិធានផ្ទៃក្នុងទាក់ទងនឹងនីតិវិធីនៅ អ.វ.ត.ក. ប្រសិនបើភាគីនៃកិច្ចព្រមព្រៀង និង អ្នកព្រាងវិធានផ្ទៃក្នុង មានបំណងចង់ឱ្យមានលទ្ធផលបែបនេះនោះ ម្ល៉េះសមពួកគេបានព្រមព្រៀងគ្នាលើបទប្បញ្ញត្តិច្បាស់លាស់មួយទៅហើយ។ ប៉ុន្តែភាគីនៃកិច្ចព្រមព្រៀង និង អ្នកព្រាងវិធានផ្ទៃក្នុង មិនបានឯកភាពគ្នាលើដំណោះស្រាយនៃយន្តការដោះស្រាយវិវាទប្រភេទនេះទេ។ បើទោះជាពួកគេចង់ធ្វើដូច្នេះ ក៏មិនអាចដែរ។ គ្មាននរណាម្នាក់ ដូចជា អ.ប.ជ. អាចដកហូតគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ ពីកិច្ចដំណើរការនីតិវិធី អ.វ.ត.ក. បានឡើយ ជាគោលការណ៍មូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ដែលត្រូវបានផ្តល់ឱ្យប្រជាពលរដ្ឋខ្មែរនៅក្នុងគ្រប់តុលាការទាំងអស់របស់ប្រទេសកម្ពុជា ក្នុងនោះរួមទាំង អ.វ.ត.ក. ផងដែរ។

៦៩. ស.ច.ស.អ. បានសន្និដ្ឋានមិនត្រឹមត្រូវ ដោយគ្មានសំអាងហេតុថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ មានអានុភាពអនុវត្ត ដោយមិនគិតពីសុពលភាពនៃដីកាសម្រេចលើកលែងចោទប្រកាន់របស់ ស.ច.ស.ជ.។ ដោយ ស.ច.ស. ដែលមានហេតុផលចំនួនពីររូប អាចដោយសមហេតុផលធ្វើសេចក្តីសន្និដ្ឋានមិនស្របគ្នាលើយុត្តាធិការបុគ្គល ផ្អែកលើការស៊ើបអង្កេតដោយឯករាជ្យរបស់ខ្លួននោះ តួនាទីរបស់ អ.ប.ជ. ក្នុងការដោះស្រាយបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយផ្ទុយគ្នាបែបនេះ គឺមិនមែនជាការកំណត់ថា តើខ្លួនយល់ស្របជាមួយសេចក្តីសន្និដ្ឋានរបស់ ស.ច.ស. ណាម្នាក់នោះឡើយ ប៉ុន្តែថា តើ ស.ច.ស. បានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនត្រឹមត្រូវឬយ៉ាងណា នៅក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួនលើយុត្តាធិការបុគ្គល។ ក្នុងករណីគ្មានកំហុស ឬ ការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ ស.ច.ស. ណាម្នាក់ ការស៊ើបអង្កេត ការវាយតម្លៃអង្គហេតុ ការយកច្បាប់មកអនុវត្ត ឬ ការចេញដីកាដំណោះស្រាយរបស់ ស.ច.ស. ម្នាក់ គឺមិនមានអានុភាពខ្ពស់ជាង ឬ ទាបជាង ការស៊ើបអង្កេត ការវាយតម្លៃអង្គហេតុ ការយកច្បាប់មកអនុវត្ត ឬ ការចេញដីកាដំណោះស្រាយរបស់ ស.ច.ស. ម្នាក់ទៀតឡើយ។

៧០. បើទោះបីជា អ.ប.ជ. មិនយល់ស្របជាមួយនឹងការរកឃើញផ្នែកអង្គហេតុរបស់ ស.ច.ស.ជ. ក៏ដោយ ក៏ អ.ប.ជ. មិនត្រឹមតែត្រូវរកឱ្យឃើញថា គ្មាន ស.ច.ស. ដែលមានហេតុផលណាផ្សេងទៀត អាចឈានទៅរកការរកឃើញបែបនេះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរកឱ្យឃើញថា ការកំណត់អង្គហេតុទាំងនោះគឺមានលក្ខណៈសំខាន់ចំពោះសេចក្តីសន្និដ្ឋានដែលបានធ្វើរួចមកហើយ ដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌។ ហើយបើទោះជា អ.ប.ជ. ផាត់ចោលដីកាសម្រេចលើកលែងចោទប្រកាន់ ដោយសំឡេងភាគច្រើនលើសលប់ ដោយឈរលើមូលដ្ឋានថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស ឬ ការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់គាត់ក៏ដោយ ក៏ អ.ប.ជ. នៅតែត្រូវការតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយសំឡេងភាគច្រើនលើសលប់ដដែល ដើម្បីឱ្យរឿងក្តីអាចបន្តទៅជំនុំជម្រះបាន។

៧១. ដីកាដំណោះស្រាយដែលស្នើលើកលែងចោទប្រកាន់ មានអានុភាពលើដីកាដំណោះស្រាយដែលស្នើឱ្យបញ្ជូនរឿងក្តីទៅជំនុំជម្រះ។ គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ មិនអាចអនុញ្ញាតឱ្យមានប្រព័ន្ធមួយដែលបណ្តាយឱ្យភាពទាល់ច្រក បន្តរហូតដល់ការកាត់សេចក្តីជនត្រូវចោទបានទេ។ នៅពេលដែលមានដីកាដំណោះស្រាយចំនួនពីរផ្ទុយគ្នាត្រូវបានចេញក្នុងពេលដំណាលគ្នាដោយ ស.ច.ស.ជ. និង ស.ច.ស.អ. ចំណោទលើយុត្តាធិការទៅលើជនត្រូវចោទគឺមានទម្ងន់ស្មើគ្នា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនអាចមានអានុភាពអនុវត្ត ហើយការជំនុំជម្រះមិនអាចដំណើរការទៅមុខបានឡើយ។

៧២. ត្រូវច្រានចោលរឿងក្តីប្រឆាំងនឹងលោក មាស មុត។

**អាស្រ័យហេតុនេះ** យោងតាមសំអាងហេតុដូចបានជម្រាបជូនខាងលើ លោក មាស មុត សូមគោរពស្នើសុំឱ្យ អ.ប.ជ. មេត្តា៖

ក. **សម្រេច** ថា បណ្តឹងឧទ្ធរណ៍នេះទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ក) និង វិធាន ២១។

ខ. **ប្រកាស** ថា ស.ច.ស.អ. មានកំហុសអង្គច្បាប់ក្នុងការបកស្រាយវិធាន ៧៧(១៣) ក្នុងរបៀបមួយដែលស្នើថា ប្រសិនបើ អ.ប.ជ. មិនអាចសម្រេចតម្កល់ដីកាដំណោះស្រាយមួយក្នុងចំណោមដីកាដំណោះស្រាយទាំងពីរទេនោះ ដីកាដំណោះស្រាយទាំងពីរ ឬ មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ប៉ុណ្ណោះ ដែលមានអានុភាពអនុវត្ត។

គ. **ប្រកាស** ថា ស.ច.ស.អ. មានកំហុសអង្គច្បាប់ដោយខកខានមិនបានសន្និដ្ឋានថា ប្រសិនបើ អ.ប.ជ. មិនអាចសម្រេចដោយសំឡេងភាគច្រើនលើសលប់ថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស ឬ ការរំលោភបំពានដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់គាត់ទេនោះ ដីកាសម្រេចលើកលែងចោទប្រកាន់ មានអនុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

ឃ. **ប្រកាស** ថា គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ ត្រូវអនុវត្ត។ និង

ង. **ប្រកាស** លើកលែងចោទប្រកាន់។

សូមលោកចៅក្រមមេត្តាទទួលយកបណ្តឹងឧទ្ធរណ៍នេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី **៨** ខែ **មេសា** ឆ្នាំ **២០១៩**។

សហមេធាវីការពារក្តីលោក មាស មុត

________________ ________________

អាង ឧត្តម Michael G. KARNAVAS